**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Économiques

Royal University of law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិជនជាប់ចោទ និងផលប៉ះពាល់ ក្នុងការមិនគោរពសិទ្ធិ

ស្រាវជ្រាវថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២២ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ    កញ្ញា **ឆ្មួង សុផាន់នី**

លោក **អ៊ុន ភាន់យ៉ា**

ណែនាំដោយ

លោក **ឆឹង ស៊ីនៀង**


**ថ្នាក់បរិញ្ញាបត្រផ្នែក នីតិសាស្ត្រ**

**ឆ្នាំចូលសិក្សា ២០១៩**

**ជំនាន់ទី ២៣**

**ឆ្នាំសរសេរសារណា ២០២៣**

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **គួង សុផាន់នី** និងឈ្មោះ **អ៊ិន ភាន់យ៉ា** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២៣ **ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។**

**សូមថ្លែងអំណរគុណ និងសំដែងនូវកតញ្ញូតាធម៌ចំពោះ**

លោកឪពុក **ភយ ច្រឹក** លោកឪពុក **ទេព ម៉ុនធី**

អ្នកម្ដាយ **ឈឹម ចាន់ដា** អ្នកម្ដាយ **ម្លូវ ភូឡាប**

ជាកិច្ចបឋមកូនៗសូមឱនកាយថ្វាយបង្គំប្រណិបតន៍ និងសម្ដែងនូវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់ចំពោះអ្នកមានគុណទាំងបួនដែលបានផ្ដល់នូវកំណើតចិញ្ចឹមបីបាច់ថែរក្សាខិតខំលះបង់កម្លាំងកាយ និងកម្លាំងចិត្តព្រមទាំងសម្ភារៈសព្វបែបយ៉ាងក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនៗទាំងអស់ដោយដៃផ្ទាល់ជាមួយ និងក្ដីស្រលាញ់ប្រកបដោយព្រហ្មវិហារធម៌ចាប់តាំងពីកំណើតរហូតដល់កូនបានធំពេញវ័យ និងថែមទាំងបានជួយឧបត្ថម្ភដល់កូនទទួលបានការអប់រំចាប់តាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ ហើយពេលនេះរូបកូនទាំងពីរនាក់ក៏ជិតបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក្នុងរយៈពេលដ៏ខ្លីខាងមុននេះ។ លទ្ធផលដែលទទួលបានកន្លងមក និងរួមទាំងការជិតឈានដល់ការបញ្ចប់ការសិក្សាថ្នាក់ឧត្តមសិក្សាទាំងអស់នេះ គឺកើតចេញពីកម្លាំងញើសឈាមរបស់លោកអ្នកមានគុណទាំងបួនក្នុងការតស៊ូជម្នះនូវភាពលំបាកគ្រប់បែបយ៉ាងដើម្បីអោយកូនៗបានសម្រេចនូវក្ដីស្រម៉ៃរបស់ខ្លួនទៅថ្ងៃអនាគត។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ** ទាំងអស់ដែលបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយពន្យល់ និងផ្ដល់ការអប់រំល្អៗ កាលពីឆ្នាំសិក្សាកន្លងទៅ។ ជាពិសេសយើងខ្ញុំក៏សូមថ្លែងអំណរគុណដ៏ឧត្ដុងឧត្ដមចំពោះ**លោកគ្រូ នឹង ស៊ីនៀង** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណានេះចំពោះប្រធានបទ **សិទ្ធិជនជាប់ចោទ និងផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិ** ដោយលោកសាស្ត្រាចារ្យបានចំណាយពេលដ៏មានតម្លៃដើម្បីជួយផ្ដល់ជាគំនិតយោបល់ល្អៗ រហូតសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត។

ជាចុងបញ្ចប់យើងខ្ញុំទាំងអស់គ្នាសូមប្រសិទ្ធិពរជ័យជូន មាតាបិតា លោកសាស្ត្រាចារ្យ សូមឲ្យមានសុខភាពល្អ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងពុទ្ធពរទាំងបួនប្រការគឺ **អាយុវណ្ណៈ សុខៈ ពលៈ** កុំបីឃ្លាងឃ្លាតឡើយ។

# **អារម្ភកថា**

យើងខ្ញុំទាំងពីរនាក់ ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ដោយកាលពីឆ្នាំកន្លងទៅយើងខ្ញុំធ្លាប់បានសិក្សាអំពីសិទ្ធិនានាដែលសាលាបានរៀបចំ និងបានសិក្សាអំពីច្បាប់នានាដែលមានចែងក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិមួយចំនួននិងយល់ឃើញថាសិទ្ធិមនុស្សគឺមានសារៈសំខាន់ណាស់មិនថាស្ថិតនៅទីណា ឬក្នុងដំណាក់កាលណានោះទេ គឺត្រូវតែទទួលបានសិទ្ធិគ្រប់ពេលវេលាជាពិសេសគឺការអនុវត្តចំពោះជនជាប់ចោទ។ ក្នុងរយៈកាលចុងក្រោយនេះសង្កេតឃើញថាការអនុវត្តការការពារសិទ្ធិមនុស្ស និងសិទ្ធិជនជាប់ចោទនៅកម្ពុជា មួយចំនួនមានភាពល្អប្រសើរជាមុន ប៉ុន្តែក្នុងនោះយើងឃើញថាចំណុចមួយចំនួនមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយនោះទេពោល គឺមានភាពខ្វះចន្លោះមិនទាន់បានពេញលេញនោះទេ។ ហេតុដូចនេះយើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសយកនូវប្រធានបទ"**សិទ្ធិជនជាប់ចោទ និងផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិ**" នេះមកស្រាវជ្រាវសរសេរចងក្រងជាសារណាបញ្ចប់ការសិក្សា។ សារណានេះគឺមានគោលបំណង អោយអ្នកសិក្សាក៏ដូចជាពលរដ្ឋទាំងអស់បានស្វែងយល់អំពីសិទ្ធិរបស់ខ្លួនដែលមាននៅពេលជាប់ខ្លួនជាជនជាប់ចោទនៅក្នុងដំណើរការនីតិវិធីរបស់តុលាការ និងដើម្បីជៀសវាងនូវការរំលោភបំពានសិទ្ធិពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងស្ថាប័នតុលាការ។

យើងខ្ញុំទាំងពីរនាក់ សូមអភ័យទោសជាមុនចំពោះការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំដែលបានចងក្រងជាសារណានេះ ប្រាកដជាមានចំណុចខ្វះចន្លោះមិនទាន់គ្រប់គ្រាន់នៅត្រង់ចំណុចណាមួយជាមិនខានឡើយប៉ុន្តែក្រុមខ្ញុំរីករាយ និងទទួលយកការរិះគន់ដើម្បីស្ថាបនាពីសំណាក់អ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូអ្នកគ្រូសាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនានូវពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ ទាំងផ្នែកខ្លឹមសារ អក្ខរាវិរុទ្ធ និងវិធីសាស្ត្រក្នុងការសរសេរ។

សូមអ្នកសិក្សា ក៏ដូចជានិស្សិតមេត្តាអភ័យទោសនូវរាល់កំហុសឆ្គងរបស់យើងខ្ញុំទាំងពីរនាក់ និងសូមមិត្តនិស្សិតធ្វើការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីបំពេញចំណុចខ្វះខាតរបស់ពួកយើងខ្ញុំទាំងពីរនាក់ដើម្បីទុកជាឯកសារដល់អ្នកមិត្តនិស្សិតជំនាន់ក្រោយ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការអនុវត្តសិទ្ធិជនជាប់ចោទ**

**ផ្នែកទី១៖ សិទ្ធិជនជាប់ចោទមុនពេលសវនាការ** ........ ៤

១. សិទ្ធិមុនពេលចាប់ខ្លួន ........ ៤

១.១.សិទ្ធិដឹងពីបទចោទ ........ ៤

១.២.សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន(ដីកា) ........ ៥

២. សិទ្ធិមានមេធាវី ឬពឹងពាក់មេធាវី ........ ៥

៣. សិទ្ធិក្នុងការបង្ហាញភស្តុតាង ........ ៧

៤. សិទ្ធិក្នុងការស្នើសុំនៅក្រៅឃុំ ........ ៨

៥. សិទ្ធិស្នើសុំឲ្យតុលាការបំពេញកិច្ចស៊ើបសួរ ........ ៨

៦. សិទ្ធិត្រូវបានសន្មត់ជាមុនថាគ្មានទោស ........ ៩

៧. សិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ ........ ១០

៨. សិទ្ធិមិនត្រូវបានគេបង្ខំឲ្យឆ្លើយសារភាពពីពិរុទ្ធភាព និងផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ........ ១១

៩.សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ........ ១២

១០.សិទ្ធិទទួលបានការព្យាបាល និងពិនិត្យសុខភាព ........ ១២

១១.សិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យាពេលយូរ ........ ១៣

**ផ្នែកទី២៖សិទ្ធិជនជាប់ចោទក្នុងពេលសវនាការ** ........ ១៤

១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ ១៤

២. សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ........ ១៥

៣. សិទ្ធិការពារខ្លួនក្នុងពេលសវនាការ ........ ១៦

៤. សិទ្ធិមានវត្តមានក្នុងពេលសវនាការ ........ ១៧

៥. សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ........ ១៨

៦. សិទ្ធិស្នើសុំឲ្យមានអ្នកបកប្រែ ........ ១៩

៧. សិទ្ធិស្នើសុំផ្លាស់ប្តូរមេធាវី ........ ២០

៨.សិទ្ធិស្នើសុំផ្លាស់ប្តូរចៅក្រម ........ ២០

៩.សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈនិងមានសំអាងហេតុ..................២២
**ផ្នែកទី៣៖ សិទ្ធិជនជាប់ចោទក្រោយពេលសវនាការ**........................................២២
១.សិទ្ធិរបស់ពិរុទ្ធជន........................................................................................២៣
១.១.សិទ្ធិធ្វើបណ្តឹងទាស់ ....................................................................................២៤
១.២.សិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍....................................................................................២៥
១.៣.សិទ្ធិធ្វើបណ្តឹងសាទុក្ខ ....................................................................................២៦
២. សិទ្ធិរបស់ទណ្ឌិត ........................................................................................២៧
២.១.សិទ្ធិធ្វើបណ្តឹងសើរើ....................................................................................២៨
២.២.សិទ្ធិទទួលបានផ្នែកថែទាំសុខភាព ....................................................................២៩
២.៣.សិទ្ធិទទួលបានសិក្សាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ.........................................៣០
២.៤.សិទ្ធិទទួលបានការសួរសុខទុកពីក្រុមគ្រួសារ និងមិត្តភក្តិ ................................... ៣១
២.៥.សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ..............................................៣២
២.៥.១.លក្ខខណ្ឌទាក់ទងនឹងកិរិយាមារយាទ ..............................................................៣៣
២.៥.២.លក្ខខណ្ឌតាក់ទងនឹងថរវេលានៃការអនុវត្តទោស ...............................................៣៣
២.៥.៣.នីតិវិធីក្នុងការដោះលែងដោយមានលក្ខខណ្ឌ ....................................................៣៣
២.៦.សិទ្ធិទទួលបានការលើកលែងទោស និងបន្ធូរបន្ថយទោស ................................. ៣៥
២.៦.១.លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងលើកលែងទោស.......................................៣៦
២.៦.២.នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស ........................................៣៧

## ជំពូកទី២

## ការអនុវត្តសិទ្ធិជនជាប់ចោទជាអនីតិជន វិធានការ និងនីតិវិធីក្នុងការអនុវត្ត ចំពោះអនីតិជន

**ផ្នែកទី១៖  សិទ្ធិជនជាប់ចោទជាអនីតិជន**..........................................................៤០
១. សិទ្ធិឯកជនភាព ........................................................................................ ៤០
២. សិទ្ធិមិនផ្តល់ចម្លើយនៅពេលមាន ឬគ្មានវត្តមានមេធាវី ..............................................៤១
៣.សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី...........៤១
៤. សិទ្ធិទទួលបានសាវាថែទាំសុខភាព និងព្យាបាល ....................................................៤២
៥.សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ........................................................................ ៤៣
៦.សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ ..........................................៤៥

៧.សិទ្ធិជាមូលដ្ឋានរបស់អនីតិជននៅក្នុងឃុំ ........ ៤៧
**ផ្នែកទី២៖ វិធានការ និងនីតិវិធីក្នុងការអនុវត្តលើអនីតិជន** ........ ៤៨
១.វិធានការអនុវត្តចំពោះអនីតិជន ........ ៤៨
២.ការរក្សាទុកនូវអនីតិជន ........ ៤៨
៣.ការចុះបញ្ជីឈ្មោះអនីតិជន ........ ៤៩
៤.ការបែងចែក និងគ្រប់គ្រង់អនីតិជនក្នុងមណ្ឌលនីតិសម្បទា ........ ៥០
៥.ការថែទាំអនីតិជនក្នុងមណ្ឌលនីតិសម្បទា ........ ៥០
**ផ្នែកទី៣៖សិទ្ធិទទួលបានការដោះលែង ការផ្តល់ និងការស្តារនីតិសម្បទាឡើងវិញ** ........ ៥១
១.ការដោះលែងដោយមានលក្ខខណ្ឌ ........ ៥១
២.នីតិវិធីក្នុងការដោះលែងដោយមានលក្ខខណ្ឌ ........ ៥២
៣.ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ ........ ៥៣

## ជំពូកទី៣

## ផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិជនជាប់ចោទ

១.មិនទទួលបានភាពយុត្តិធម៌ ........ ៥៤
២.ខាតបង់ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ ........ ៥៥
៣.បាត់បង់សេរីភាព ........ ៥៦
៤.ទទួលរងនូវបញ្ហាផ្លូវចិត្ត និងផ្លូវកាយ ........ ៥៧
៥.ប៉ះពាល់ដល់កិត្តិយសគ្រួសារ ........ ៥៧
៦.បែកបាក់គ្រួសារ និងបាត់បង់ប្រាក់ចំណូល ........ ៥៨
៧.ទទួលរងនូវការរើសអើងពីសង្គម ........ ៥៨
៨.ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះប្រទេសជាតិ ........ ៥៩
៩.បាត់បង់តម្លៃនៃច្បាប់ការពារសិទ្ធិ និងប្រព័ន្ធច្បាប់នៅក្នុងប្រទេសមានភាពចុះខ្សោយ ........ ៦០
១០.ប្រជាពលរដ្ឋលែងជឿជាក់ទៅលើប្រព័ន្ធតុលាការ ........ ៦១
**សេចក្តីសន្និដ្ឋាន** ........ ៦៣
**អនុសាសន៍** ........ ៦៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. បុព្វហេតុនៃការស្រាវជ្រាវ

ដំណើរការប្រកបដោយឯករាជ្យ និងប្រសិទ្ធិភាពនៃស្ថាប័នតុលាការ គឺជាចំណុចសំខាន់ដ៏មួយក្នុងកិច្ចការពារ និងការគោរពសិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលជាច្បាប់កំពូលរបស់ប្រទេសក៏បានទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសលកស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាទាំងឡាយណាដែលទាក់ទងជាមួយនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារជាដើម។ ប្រជាពលរដ្ឋត្រូវតែមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងមានករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតមានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ អាយុ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ មនុស្សគ្រប់រូបទាំងអស់កើតមានសេរីភាព សមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរ និងសិទ្ធិក្នុងន័យនេះបានន័យថាជនគ្រប់រូបទាំងអស់ មិនថាជនធម្មតា ឬក៏ជនល្មើស ឬជនជាប់ចោទក្តី ដែលជាប់ចោទក្នុងរឿងក្តីព្រហ្មទណ្ឌត្រូវទទួលបាននូវសិទ្ធិរបស់ខ្លួន។ ក្នុងករណីដែលជននោះបានជាប់ចោទពីបទល្មើសព្រហ្មទណ្ឌយើងត្រូវចាត់ទុកពួកគេជាមនុស្សគ្មានទោសរហូតទាល់តែសាលក្រម ឬសាលដីកាតុលាការចូលជាស្ថាពរ និងប្រកបដោយយុត្តិធម៌ថាពួកគេពិតជាមានកំហុសពិតមែន។ គោលបំណងនៃការការពារសិទ្ធិរបស់ជនជាប់ចោទ គឺសំដៅទៅលើការធានាការពារសិទ្ធិទាំងឡាយដែលជនជាប់ត្រូវតែទទួលបានក្នុងអំឡុងពេលខាត់ខ្លួន រហូតដល់តុលាការចេញសេចក្តីសម្រេចទៅលើជននោះ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

បើទោះបីជាសិទ្ធិរបស់ជនជាប់ចោទ នៅក្នុងពន្ធនាគារទទួលបានការការពារពីច្បាប់ជាតិ និងអន្តរជាតិយ៉ាងណាក្តី ក៏នៅមានតែមានសិទ្ធិមួយចំនួនរបស់ពួកគេត្រូវបានដកហូតជាបណ្តោះអាសន្ន។ ដូចនេះដើម្បីជាចង្កៀងបំភ្លឺផ្លូវក្នុងការបកស្រាយនូវសិទ្ធិទាំងឡាយរបស់ជនជាប់ចោទនៅកម្ពុជា ក្នុងនាមជាអ្នកអានគួរគប្បីយល់ដឹងពីចំណោទបញ្ហាដែលបានចោទឡើងថា: ***តើសិទ្ធិជនជាប់ចោទជានីតិជននៅពេលសវនាការ ក្នុងពេលសវនាការ និងក្រោយពេលសវនាការមានសិទ្ធិអ្វីខ្លះ? តើសិទ្ធិជនជាប់ចោទជាអនីតិជនមានអ្វីខ្លះ? តើមានវិធានការអ្វីខ្លះសម្រាប់អនុវត្តទៅលើអនីតិជន? តើការរក្សាទុកនៅអនីតិជន ដូចគ្នាទៅនឹងការរក្សាទុកនៅជនជាប់ចោទជានីតិជនដែរ ឬទេ? ហើយតើការមិនគោរពសិទ្ធិជនជាប់ចោទជានីតិជន និងអនីតិជនមានផលប៉ះពាល់អ្វីខ្លះ?***

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់ពីភាពមិនច្បាស់លាស់មួយចំនួននៅក្នុងប្រព័ន្ធច្បាប់សម្រាប់ការអនុវត្តសិទ្ធិរបស់ជនជាប់ចោទ ក៏ដូចជាចង់ស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តិដូចដែលបានលើកឡើងពីខាងលើ។ មិនត្រឹមតែប៉ុណ្ណោះគឺដើម្បីពង្រឹងពង្រីកនូវសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទងទៅនឹងវិស័យព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជាផងដែរ ចំពោះសមិទ្ធផលដែលបានមកពីការសិក្សាស្រាវជ្រាវនេះ ក៏ជាផ្នែកមួយនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍនូវវិស័យព្រហ្មទណ្ឌ និងការអនុវត្តសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាថែមទៀតផង។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ចាប់ផ្តើមតាំងពីការជ្រើសរើសប្រធានបទការស្រាវជ្រាវ ការរកឯកសារដែលពាក់ព័ន្ធរហូតដល់ការសរសេរសារណានេះឡើង គឺក្នុងគោលបំណងធ្វើការរៀបរាប់ឱ្យកាន់តែលំអិតពាក់ព័ន្ធនិងប្រធានបទមួយនេះ។ ជាពិសេសសិទ្ធិដែលជាប់ពាក់ព័ន្ធទៅនិងជនជាប់ចោទនូវប្រទេសកម្ពុជា។ ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ ផ្អែកទៅលើបញ្ញត្តិច្បាប់ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ច្បាប់ស្តីពីពន្ធនាគារ និងច្បាប់ផ្សេងៗទៀតដែលជាប់ពាក់ព័ន្ធទៅនឹងជនជាប់ចោទ ក្នុងនោះដែរក៏មានការចូលរួមពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូក្នុងការជួយជ្រោមជ្រែងផ្តល់គំនិតយោបល់ល្អៗ និងចង្អុលបង្ហាញទិសដៅដល់សិស្សក្នុងការស្រាវជ្រាវឲ្យចំគោលដៅដែលការសិក្សាទៅលើប្រធានបទមួយនេះបានធ្វើឲ្យខ្ញុំផ្ទាល់ ក៏ដូចជាមិត្តរួមក្រុមមានការយល់ដឹងកាន់តែច្បាស់ពាក់ព័ន្ធ និងក្រមនីតិវិធីព្រហ្មទណ្ឌតាំងពីចាប់ផ្តើមរហូតដល់បញ្ចប់។ ចំពោះការស្រាវជ្រាវក្រុមយើងខ្ញុំបានលើកយកច្បាប់ដែលជាប់ពាក់ព័ន្ធជាច្រើន ក៏ដូចជាមាត្រាសម្រាប់បកស្រាយលម្អិតឲ្យកាន់តែស៊ីជម្រៅផងដែរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

កន្លងមកយើងតែងតែឃើញសៀវភៅបោះពុម្ពទាក់ទងនឹងសិទ្ធិផ្សេងៗជាច្រើន។ ប៉ុន្តែយើងកម្រឃើញគេនិយាយបកស្រាយលម្អិតពាក់ព័ន្ធ និងសិទ្ធិរបស់ជនជាប់ចោទនោះណាស់។ ហេតុដូចនេះបានជាក្រុមខ្ញុំសម្រេចជ្រើសរើសប្រធានបទ ***សិទ្ធិជនជាប់ចោទ និងផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិជនជាប់ចោទ*** មកបកស្រាយលម្អិត ដោយសារប្រជាពលរដ្ឋមួយចំនួនតូចនៅក្នុងសង្គមបច្ចុប្បន្នមានការយល់ដឹងពុំស៊ីជម្រៅគ្រប់ជ្រុំ និងប្រទេសកម្ពុជាយើងស្ថិតនៅក្នុងស្ថានភាពកំពុងអភិវឌ្ឍន៍ ជាពិសេសពាក់ព័ន្ធនឹងផ្លូវច្បាប់ក៏នៅមានកម្រិតទោះបុគ្គលទាំងនោះពុំបានប្រព្រឹត្តអំពើដែលនាំផលវិបាកដល់សង្គមក៏ពួកគេគួរ ប៉ុន្តែចូលរួមក្នុងការស្វែងយល់ពាក់ព័ន្ធនឹងច្បាប់នានាពិសេសអំពីសិទ្ធិរបស់ជនដែលជាប់ក្នុងពន្ធនាគារ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពិពណ៌នា វិភាគ ហើយយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយធ្វើការប្រមូលផ្តុំនូវព័ត៌មានទាំងឡាយណា ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីឲ្យកាន់តែមានភាពត្រឹមត្រូវច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។ ព័ត៌មានទាំងឡាយណាដែលត្រូវបានជ្រើសរើស និងដកស្រង់ចេញពីប្រភពល្អ ក៏ដូចជាការបកស្រាយរបស់នីតិករ អ្នកមានបទពិសោធន៍នៅក្នុងវិស័យច្បាប់នេះផ្ទាល់តែម្តង មតិយោបលរបស់អ្នកជំនាញខាងច្បាប់ព្រហ្មទណ្ឌ នីតិវិធីនៅក្នុងច្បាប់ព្រហ្មទណ្ឌ និងច្បាប់សំខាន់របស់ប្រទេសកម្ពុជា ព្រមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតរួមមានទាំងឯកសាររបស់ជាតិ និងអន្តរជាតិ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជាបន្តទៅទៀត ដើម្បីឆ្លើយតបទៅនឹងប្រធានបទខាងលើនេះ ក្រុមយើងខ្ញុំសូមធ្វើការបែងចែកចេញជា ៣ ជំពូកធំៗរួមមានគឺៈ

**ជំពូកទី១ ការអនុវត្តសិទ្ធិជនជាប់ចោទ។**

**ជំពូកទី២ ការអនុវត្តសិទ្ធិជនជាប់ចោទជាអនីតិជន វិធាន និងនីតិវិធីអនុវត្តចំពោះអនីតិជន។**

**ជំពូកទី៣ ផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិជនជាប់ចោទ។**

# ជំពូកទី១
# ការអនុវត្តសិទ្ធិជនជាប់ចោទ

# ជំពូកទី១
# ការអនុវត្តសិទ្ធិជនជាប់ចោទ

## ផ្នែកទី១៖ សិទ្ធិជនជាប់ចោទមុនពេលសវនាការ

### ១. សិទ្ធិមុនពេលចាប់ខ្លួន

ជនជាប់ចោទ ឬជនត្រូវចោទមានសិទ្ធិការពារខ្លួននៅក្រោមច្បាប់ជាតិ និងអន្តរជាតិ។ ដោយគ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬឃាត់ខ្លួនទៅតាមអំពើចិត្តនោះឡើយ លើកលែងតែមានភស្តុតាងបញ្ជាក់ត្រឹមត្រូវទៅតាមផ្លូវច្បាប់ចំពោះការចាប់ខ្លួនជនជាប់ចោទ ដែលជាទូទៅនៅក្នុងនីតិវិធីនៃការឃាត់ខ្លួនមានរយៈពេល ៤៨ ម៉ោង ។ ដោយឡែកនៅពេលដែលជនជាប់ចោទត្រូវបានឃាត់ខ្លួននោះក្នុងរយៈ ២៤ ម៉ោង ទើបជនជាប់ចោទមានសិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយមេធាវី ឬសាច់ញាតិបាន[1]។ ប៉ុន្តែជាក់ស្តែងជនដែលត្រូវបានគេឃាត់ខ្លួនភាគច្រើន ឬចាប់ខ្លួន តែងតែត្រូវបានគេឃាត់ខ្លួនលើសពីការកំណត់ដោយច្បាប់ទើបជនទាំងនោះអាចជួបប្រាស្រ័យទាក់ទងជាមួយនឹងមេធាវី ឬសាច់ញាតិបាន។ ចំណែកការឃុំខ្លួនបណ្តោះអាសន្នវិញច្បាប់បានកំណត់ក្នុងការឃុំខ្លួនមុនពេលសវនាការមានរយៈពេលត្រឹមតែ ៦ ខែតែប៉ុណ្ណោះ ចំពោះបទល្មើសដែលជាបទមជ្ឈិម និងរយៈពេល ១៨ ខែ ចំពោះបទល្មើសជាបទឧក្រិដ្ឋ។

ដូច្នេះយើងគួរគម្បីយល់ដឹងពីសិទ្ធិសំខាន់ៗរបស់ជនជាប់ចោទមុនពេលសវនាការរួមមាន សិទ្ធិត្រូវបានគេសន្មតថាមិនមានកំហុសរហូតទាល់តែត្រូវបានតុលាការកាត់សេចក្តីថាមានទោស សិទ្ធិដឹងពីបទចោទ សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន សិទ្ធិមានមេធាវី ឬសិទ្ធិពឹងពាក់មេធាវី សិទ្ធិក្នុងការស្នើសុំនៅក្រៅឃុំ សិទ្ធិស្នើសុំឲ្យតុលាការបំពេញកិច្ចស៊ើបសួរ សិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ សិទ្ធិក្នុងការបង្ហាញភស្តុតាង សិទ្ធិមិនឆ្លើយនឹងសំណួរ សិទ្ធិមិនត្រូវបានគេបង្ខំឲ្យឆ្លើយ ឬសារភាព សិទ្ធិទទួលបានការព្យាបាល និងពិនិត្យសុខភាពក្នុងពេលឃុំខ្លួន សិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យាពេលយូរ សិទ្ធិមិនត្រូវបានគេធ្វើទារុណកម្ម និងសិទ្ធិផ្សេងៗជាច្រើនទៀតក្នុងដំណាក់កាលមុនពេលចាប់ខ្លួន។

### ១.១ សិទ្ធិដឹងពីបទចោទ

សិទ្ធិដឹងពីបទចោទ គឺជាសិទ្ធិមួយមានសារៈសំខាន់ណាស់ដែលជនជាប់ចោទទាំងអស់មានសិទ្ធិដឹងពីបទចោទ ដែលមន្ត្រីនគរបាលយុត្តិធម៌បានចោទប្រកាន់មកលើខ្លួន។ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចក្នុងការប្រាប់ពីបទចោទប្រកាន់ទៅលើជនជាប់ចោទ ការប្រាប់ពីបទចោទនេះអាចធ្វើទៅបានដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ។ មិនត្រឹមតែមន្ត្រីនគរបាលយុត្តិធម៌ប៉ុណ្ណោះទេដែលមានកាតព្វកិច្ចប្រាប់ពីបទចោទទៅ

[1] មាត្រា ៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជនជាប់ចោទ សូម្បីតែចៅក្រមក៏មានកាតព្វកិច្ចប្រាប់ពីបទចោទទៅជនជាប់ចោទផងដែរ ដែលចៅក្រមត្រូវតែរំលឹកដល់ជនជាប់ពីបទចោទនៅគ្រប់តំណាក់កាលនីតិវិធីទាំងអស់។ សិទ្ធិដឹងពីបទចោទ សិទ្ធិនេះពិតជាមានសារៈសំខាន់ណាស់ព្រោះវាអាចធ្វើឲ្យជនជាប់ចោទមានពេលវេលាគ្រប់គ្រាន់ និងងាយស្រួលក្នុងការរៀបចំភស្តុតាងក្នុងការការពារខ្លួន។

## ១.២.សិទ្ធិដឹងពីមូលហេតុនៃការចាប់ខ្លួន

នៅពេលដែលត្រូវបានចាប់ខ្លួនជនជាប់ចោទចាំបាច់ត្រូវដឹងពីមូលហេតុនៃការចាប់ (ជាពិសេសមានដីកាចាប់ខ្លួនដែរឬទេ) ការចាប់ខ្លួននេះបណ្តាលមកពីមូលហេតុអ្វី ហើយខ្លួនបានប្រព្រឹត្តអំពើល្មើសច្បាប់អ្វីខ្លះ និងមានសំណៅឯកសារភស្តុតាងគ្រប់គ្រាន់ដែរ ឬទេក្នុងការចាប់ខ្លួន។ ដូច្នេះមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់លំអិតដល់សាមីខ្លួន និងភស្តុតាងនានាដែលបង្កឲ្យមានការចាប់ខ្លួននេះឡើង។ ចំណែកឯច្បាប់លក្ខន្តិកៈ ទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិមាត្រា **៦៦** ចែងថាក្នុងកំឡុងពេលមួយសមស្របមុនសវនាការជននោះត្រូវទទួលបាននូវរាល់សំណុំឯកសារស្តីពីការចោទប្រកាន់ ដែលតំណាងអយ្យការនឹងនាំយកមកក្នុងពេលជំនុំជម្រះ[2] ដូច្នេះជនសង្ស័យ ឬជនជាប់ចោទមានសិទ្ធិគ្រប់បែបយ៉ាងក្នុងការទាមទារឲ្យគេប្រាប់ភ្លាមៗនូវមូលហេតុ និងប្រភេទបទល្មើសដែលបានចោទប្រកាន់មកលើខ្លួន។ ការការពារខ្លួននៅពេលចាប់ខ្លួនត្រូវបានការពារដោយរដ្ឋធម្មនុញ្ញកម្ពុជា និងលិខិតតូបករណ៍អន្តរជាតិដូចជា៖ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានចែងថាជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ជនជាប់ចោទអាចលើកយកភស្តុតាងសាក្សីទាំងឡាយណាដែលមានប្រយោជន៍ក្នុងការដោះបន្ទុក ដើម្បីឲ្យរួចផុតពីការចោទប្រកាន់របស់ព្រះរាជអាជ្ញា មិនតែប៉ុណ្ណោះជនជាប់ចោទក៏មានសិទ្ធិក្នុងការស្វែងរកមេធាវី ឬទីប្រឹក្សាដើម្បីធ្វើជាជំនួយការខាងផ្លូវច្បាប់ក្នុងការដោះបន្ទុក[3]។ ស្របគ្នានេះដែរជនជាប់ចោទក៏មានសិទ្ធិបង្ហាញជូននូវភស្តុតាង និងការបកស្រាយច្បាប់ដល់តុលាការក្នុងកិច្ចការពារខ្លួនដោយខ្លួនឯង ឬតាមរយៈជំនួយផ្នែកច្បាប់តាមរយៈការជ្រើសរើសរបស់ជនជាប់ចោទនោះ។ ដូច្នេះសិទ្ធិការពារខ្លួនជាសិទ្ធិមួយដែលមានប្រយោជន៍ និងមានសារៈសំខាន់បំផុតពីព្រោះវាអាចជួយជនជាប់ចោទមានឱកាសកាន់តែច្រើនដើម្បីឲ្យខ្លួនរួចពីការចោទប្រកាន់ ជាពិសេសការដោះស្រាយតាមប្រព័ន្ធផ្លូវច្បាប់ និងទទួលបានជំនួយពីមេធាវីបន្ថែមទៀត ។

[2] មាត្រា ៦៦ ច្បាប់ស្តីពីលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

[3] មាត្រា ៣៨ (៨) រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

## ២.សិទ្ធិមានមេធាវី ឬសិទ្ធិពឹងពាក់មេធាវី

សិទ្ធិមានមេធាវី ជាទូទៅនៅក្នុងដំណើរការនីតិវិធីតុលាការភាគីទំនាស់តែងតែមានមេធាវីការពារសិទ្ធិរៀងខ្លួន ប៉ុន្តែក្នុងដំណាក់កាលនៃការឃាត់ខ្លួនដំបូងមានករណីខ្លះជនសង្ស័យពុំមានមេធាវីការពារសិទ្ធិនោះទេ សិទ្ធិមានមេធាវី គឺជាសិទ្ធិមួយយ៉ាងសំខាន់របស់ជនជាប់ចោទជាគោលការណ៍នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងជាបន្ទាន់អំពីការសម្រេចឃាត់ខ្លួននោះទៅបុគ្គលដែលត្រូវបានឃាត់ខ្លួននោះ និងមូលហេតុនៃការឃាត់ខ្លួន ហើយការឃាត់ខ្លួនមានរយៈពេល **៤៨** ម៉ោង ក្នុងករណីពិសេសអាចស្នើសុំបន្ថែម **២៤** ម៉ោង[4]។ ជនដែលត្រូវបានឃាត់ខ្លួនក្នុងរយៈ **២៤** ម៉ោង កន្លងផុតជននោះមានសិទ្ធិស្នើសុំជួបបានគ្រប់បុគ្គល (មេធាវី ឬអាណាព្យាបាល) លើកលែងតែជនដែលមានការពាក់ពន្ធ័ក្នុងព្រឹត្តិហេតុនោះ ក្នុងករណីដែលជនជាប់ចោទស្នើសុំជួបមេធាវីដើម្បីឲ្យមេធាវីការពារសិទ្ធិរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងពីការស្នើសុំជ្រើសរើសនេះតាមគ្រប់មធ្យោបាយជាបន្ទាន់ ទៅកាន់មេធាវីដែលជនជាប់ចោទបានជ្រើសរើសជួប។ ជនជាប់ចោទមានសិទ្ធិស្វែងរកមេធាវីដែលខ្លួនពេញចិត្តប្រកបដោយសមត្ថភាព និងបទពិសោធន៍ច្បាស់លាស់ដើម្បីទទួលខុសត្រូវក្នុងការការពាររឿងក្ដីរបស់ខ្លួន។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានជំនាញពិសេសក្នុងការការពារក្តីនៅពេលជនជាប់ចោទត្រូវបានគេនាំយកមកនៅមុខចៅក្រមស៊ើបអង្កេត ក្នុងកាលៈទេសៈដែលមិនមានមេធាវីអមជាមួយជនជាប់ចោទនោះមានសិទ្ធិជ្រើសរើសមេធាវីណាម្នាក់សម្រាប់ការពារខ្លួនបាន។ ដោយហេតុថាជនជាប់ចោទស្ថិតនៅក្រោមការឃុំខ្លួនរបស់តំណាងអយ្យការ ហេតុដូចនេះតំណាងអយ្យការមានកាតព្វកិច្ចជួយដល់ជនជាប់ចោទក្នុងការផ្តល់ព័ត៌មានទាក់ទង និងការជ្រើសរើសមេធាវីដោយឲ្យតំណាងអយ្យការធ្វើការទាក់ទងមេធាវីណាម្នាក់ ឬស្នើសុំទៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាត់តាំងមេធាវីម្នាក់ឲ្យមកការពារក្តីដល់ជនជាប់ចោទ។ បន្ទាប់មកទៀតតំណាងអយ្យការត្រូវពន្យាពេលការសួរចម្លើយដល់ជនជាប់ចោទ រហូតដល់មានវត្តមានមេធាវីអមជាមួយគ្រប់សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋ នីតិជនក្តី ឬអនីតិជនក្តី សុទ្ធតែមានសិទ្ធិរកមេធាវីទាំងអស់នៅពេលដែលទទួលបានការចាត់តាំងរួចហើយ មេធាវីមានសិទ្ធិពេញលេញក្នុងការទំនាក់ទំនងជាមួយកូនក្តីដោយសេរី និងទទួលបានព័ត៌មានពីតុលាការដើម្បីធ្វើការទាក់ទងក្នុងសំណុំរឿងរបស់កូនក្តីខ្លួន រួមទាំងសិទ្ធិក្នុងការថតចម្លងរាល់ឯកសារទាំងឡាយណាដោយ ផ្អែកលើច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា[5]។ មិនត្រឹមតែនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះទេ ដែលបានកំណត់អំពីសិទ្ធិមានមេធាវី លិខិតលេខ**១៦១៧ ស.ជ.ណ** ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃពាក់ព័ន្ធនឹងការណែនាំ

[4] មាត្រា ៩៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[5] មាត្រា ១៤៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អនុញ្ញាតឲ្យមេធាវីអាចអមកូនក្តី នៅគ្រប់ដំណាក់កាលនីតិវិធីទាំងអស់រួមទាំងការស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿងផងដែរ។ ហេតុនេះជនដែលត្រូវបានឃាត់ខ្លួនមានសិទ្ធិពឹងពាក់មេធាវីដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របទៅតាមផ្លូវច្បាប់សម្រាប់ខ្លួន និងអាចស្នើសុំសន្ទនាជាមួយមេធាវីបានរយៈពេល **៣០ (សាមសិប)** នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនា បន្ទាប់ពីរយៈពេល **២៤ (ម្ភៃបួន)** ម៉ោងបានកន្លងផុតទៅគិតចាប់ពីពេលនៃការឃាត់ខ្លួន[6]។

### ៣.សិទ្ធិក្នុងការបង្ហាញភស្តុតាង

ជាទូទៅតុលាការសម្រេចសេចក្តីដោយផ្អែកទៅលើភស្តុតាង ដូច្នេះហើយវាពិតជាមានសារៈសំខាន់ណាស់ដែលភាគីនៅក្នុងរឿងព្រហ្មទណ្ឌ ឬក៏ជនចាប់ចោទខ្លួនឯងផ្ទាល់ត្រូវបង្ហាញភស្តុតាង (ជាឯកសារ ឬក៏សាក្សី) ដើម្បីគាំទ្រដល់ការដោះបន្ទុករបស់ខ្លួន។ សិទ្ធិក្នុងការបង្ហាញភស្តុតាងរួមមាន៖ សិទ្ធិក្នុងការបង្ហាញភស្តុតាងជាឯកសារ សិទ្ធិហៅ និងសាកសួរសាក្សី ដោយការកោះហៅសាក្សីអាចត្រូវបានហៅដោយតុលាការផ្ទាល់ ឬតាមរយៈការស្នើសុំរបស់ជនជាប់ចោទ ឬក៏ភាគីពាក់ព័ន្ធផ្សេងទៀត។ ចំពោះការសាកសួរសាក្សីវិញ តុលាការអាចសាកសួរដោយមិនគិតថានរណាជាអ្នកហៅសាក្សីនោះទេ ដោយភាគីនីមួយៗរួមទាំងជនចាប់ផ្ទាល់ក៏មានសិទ្ធិក្នុងការសាកសួរតទល់ជាមួយសាក្សីបានដែរ។ សិទ្ធិបង្ហាញភស្តុតាងនេះបានផ្តល់ឲ្យភាគីជនជាប់ចោទនៅអំណាចស្របច្បាប់មួយក្នុងការបង្ហាញភស្តុតាង ក៏ដូចជាសាក្សីជាដើម។ សិទ្ធិក្នុងការបង្ហាញភស្តុតាងនេះ ត្រូវបានធានាដោយកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅក្នុងមាត្រា១៤ បានចែងថា "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិសួរឆ្លើយ ឬសុំឲ្យសួរឆ្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក[7]" មិនត្រឹមតែប៉ុណ្ណោះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក៏បានចែងយ៉ាងច្បាស់ផងដែរថា "ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ"[8]។ សរុបមកសិទ្ធិក្នុងការបង្ហាញភស្តុតាងនេះ ពិតជាមានសារៈសំខាន់ណាស់ដែលអាចធ្វើឲ្យតុលាការមានឱកាសក្នុងការស្វែងរកនៅភាពពិតនៅក្នុងរឿងក្តី ហើយសិទ្ធិនេះបានជួយធ្វើឲ្យតុលាការវាយតម្លៃការដេញដោលផ្សេងៗដែលត្រូវបានបង្ហាញក្នុងពេលសវនាកា ដើម្បីធ្វើការសម្រេចសេចក្តីមួយដែលត្រឹមត្រូវដោយផ្អែកទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង។ ជាចុងក្រោយសិទ្ធិក្នុងការបង្ហាញភស្តុតាងនេះ ជាធាតុផ្សំសំខាន់មួយនៃគោលការណ៍ភាពស្មើគ្នា ក្នុងគោលបំណងធានាដល់សមភាពរវាងគូភាគីនៅក្នុងដំណាក់កាលទាំងអស់នៃ

[6] មាត្រា ៩៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[7] មាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ

[8] មាត្រា ៣៨ (៨) រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

រឿងក្តី ដោយគ្មានភាគីណាមួយត្រូវបានកេងប្រយោជន៍ពីភាគីដទៃក្នុងការបង្ហាញភស្តុតាងក្នុងរឿងក្តីនោះទេ ប៉ុន្តែប្រសិនបើតុលាការមិនអនុញ្ញាតឲ្យភាគីជនជាប់ចោទនៅក្នុងសំណុំធ្វើការបង្ហាញភស្តុតាង ឬកោះហៅសាក្សីសាកសួរតទល់នោះទេ បញ្ហានេះនឹងធ្វើឲ្យខូចប្រយោជន៍របស់ភាគីជនចាប់ចោទនៅក្នុងពេលសវនាការ។

## ៤.សិទ្ធិស្នើសុំនៅក្រៅឃុំ

គ្រប់ជនដែលបានប្រព្រឹត្តបទល្មើសទាំងអស់ ដែលត្រូវបានមន្ត្រីនគរបានយុត្តិធម៌ឃាត់ខ្លួន ជានីតិវិធីមន្ត្រីនគរបាលយុត្តិធម៌ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការ ហើយដំណាក់កាលដំបូងបំផុតដែលត្រូវឆ្លងកាត់នោះ គឺត្រូវឆ្លងកាត់ការសាកសួររបស់ព្រះរាជអាជ្ញា បន្ទាប់ពីព្រះរាជអាជ្ញាធ្វើការសាកសួរ និងចោទប្រកាន់រួចព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ (តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) ដើម្បីចោទប្រកាន់ថាតើគួរឃុំខ្លួនបណ្តោះអាសន្ន ឬមិនគួរឃុំខ្លួន។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចចិត្តឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ដំណាក់កាលនេះហើយដែលជនត្រូវចោទអាចដាក់ពាក្យស្នើសុំនៅក្រៅឃុំបាន ការដាក់ពាក្យស្នើសុំនៅក្រៅឃុំអាចធ្វើឡើងដោយជនត្រូវចោទខ្លួនឯងផ្ទាល់ ឬក៏តាមរយៈមេធាវី ដោយត្រូវដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់ចៅក្រមស៊ើបសួរ។ នៅពេលដែលចៅក្រមស៊ើបសួរទទួលបានពាក្យស្នើសុំនៅក្រៅឃុំរួចហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីធ្វើការពិនិត្យ ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត ហើយចៅក្រមស៊ើបសួរត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល **៥** ថ្ងៃបន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចបដិសេធការស្នើសុំជនត្រូវចោទអាចអាចដាក់ពាក្យស្នើសុំជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល **១** ខែបន្ទាប់ពីមានសេចក្តីសម្រេចបដិសេធកាលពីលើកមុន[៩]។

## ៥. សិទ្ធិស្នើសុំឱ្យតុលាការបំពេញកិច្ចស៊ើបសួរ

ជនត្រូវចោទមានសិទ្ធិសុំឲ្យតុលាការបំពេញកិច្ចស៊ើបសួរនៅគ្រប់ពេលវេលាទាំងអស់ នៃការស៊ើបសួរមិនត្រឹមតែប៉ុណ្ណោះ អាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង។ ដែលក្នុងនោះផងដែរពាក្យស្នើសុំឲ្យបំពេញកិច្ចនេះជនជាប់ចោទត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ[10]។ ក្នុងករណីដែលជនជាប់បានដាក់ពាក្យស្នើសុំ ហើយចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា **១** ខែ បន្ទាប់ពីពេលដែលចៅក្រមបានទទួលពាក្យរួច ដីកានេះចៅក្រមត្រូវតែបញ្ជាក់ឲ្យបានច្បាស់លាស់អំពីសំអាងហេតុ និងជូន

---

[9] មាត្រា ២១៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[10] មាត្រា ១៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដំណឹងទៅជនជាប់ចោទក្នុងករណីដែលចៅក្រមមិនបានសម្រេចក្នុងរយៈពេល ១ ខែ ជនជាប់ចោទមានសិទ្ធិប្តឹងដោយផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរបាន ហើយរាល់ពាក្យសុំឲ្យតុលាការបំពេញកិច្ច ជនជាប់ចោទត្រូវតែបញ្ជាក់ពីការសុំឲ្យប្រមូលនូវភស្តុតាងដែលមានប្រយោជន៍នៅក្នុងការស្វែងរកភាពពិតដើម្បីដោះបន្ទុកបរបស់ខ្លួន ហើយត្រូវតែពន្យល់ពីមូលហេតុដែលខ្លួនយល់ថាចាំបាច់ត្រូវតែស៊ើបសួរក្នុងករណីដែលជនជាប់ចោទមិនពន្យល់បញ្ជាក់ឲ្យបានច្បាស់ពីភាពពាក់ព័ន្ធនោះទេ នោះចៅក្រមអាចបដិសេធបានកាលណាកិច្ចនោះវាមានភាពដូចគ្នាទៅ និងបញ្ហាដែលបានស៊ើបសួររួចហើយ។

## ៦.សិទ្ធិត្រូវបានសន្មត់ជាមុនថាគ្មានទោស

សិទ្ធិត្រូវបានសន្មត់ជាមុនថាគ្មានទោស ជាសិទ្ធិមូលដ្ឋានមួយដែលមានការទទួលស្គាល់ទាំងច្បាប់ជាតិ និងអន្តរជាតិ រាល់ជនត្រូវចោទទាំងអស់ត្រូវចាត់ទុកថាគ្មានទោស កាលណាតុលាការមិនទាន់សម្រេចផ្តន្ទាទោសជាស្ថាពរ។ ការអនុវត្តគោលការណ៍នេះមិនត្រឹមតែជាលក្ខខណ្ឌចាំបាច់ ដើម្បីធានាដោយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ ប៉ុន្តែសិទ្ធិនេះក៏ជាស្ថានមួយសម្រាប់ជម្រុញឲ្យមានភាពជឿជាក់នៅក្នុងនីតិរដ្ឋផងដែរ។ គោលការណ៍នេះមាននៅក្នុងច្បាប់ជាតិត្រង់មាត្រា **៣៨** នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដោយបញ្ញត្តិថា ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ បានន័យថាបុគ្គលគ្រប់រូបត្រូវចាត់ថាគ្មានទោសនោះទេដោយរង់ចាំសេចក្តីសម្រេចរបស់តុលាការសិន[11]។ នៅក្នុងករណីនេះផងដែរទាំងច្បាប់ជាតិ និងអន្តរជាតិរ៉ាប់រងមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ដោយច្បាប់ទាំងអស់នោះបានការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋទាំងអស់។ ម៉្យាងទៀតក្នុងករណីដែលរឿងនោះនៅមានវិមតិសង្ស័យ ត្រូវបានប្រើជាប្រយោជន៍ដល់ជនជាប់ចោទមានន័យថា រឿងមួយពុំទាន់មានអង្គហេតុច្បាស់លាស់ ហើយស្ថិតនៅក្នុងការសង្ស័យត្រូវបានប្រយោជន៍ទៅជនជាប់ចោទ។ មិនត្រឹមតែមានកំណត់នៅក្នុងច្បាប់ជាតិប៉ុណ្ណោះទេ ប៉ុន្តែមាត្រា **១៤ កថាខណ្ឌទី១** នៃកតិសញ្ញាអន្តរស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ " ***ក៏បានបញ្ញតិយ៉ាងជាក់ច្បាស់ផងដែរថា រាល់ជនជាប់ចោទ ពីបទល្មើសព្រហ្មទណ្ឌត្រូវសន្មតជាមុនថា គ្មានទោសរហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់***" [12]។ ការសន្មតជាមុនថាគ្មានទោស ជាសិទ្ធិមួយដើម្បីការពារដល់ជាប់ចោទនៅក្នុងការបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងរូបភាពមានសេចក្តីថ្លៃថ្នូរក្នុងនាមជាពលរដ្ឋធម្មតា និងគ្មានទោសសោះឡើយ ហើយជនជាប់ចោទមិនត្រូវបានដាក់ខ្នោះដាក់ច្រវ៉ុង ឬតម្រូវឲ្យស្លៀកពាក់ឯកសណ្ឋានពន្ធនាគារឡើយ។ ប៉ុន្តែជាក់ស្តែងនៅពេលដែលជនជាប់ចោទ ចូលខ្លួនក្នុងសវនាការបានពាក់ឯកសណ្ឋានជាអ្នកទោសរួចហើយ ដែលនេះទាក់ទងនឹងការ

[11] មាត្រា ៣៨ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[12] មាត្រា ១៤ កថាខណ្ឌទី១ កតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិយោបាយ

យល់ឃើញជាមុនថាជនជាប់ចោទ ជាអ្នកមានទោសរួចទៅហើយដែលវានឹងនាំឲ្យជះឥទ្ធិពល (ដោយចេតនា ឬអចេតនាក្តី ដល់ការវិនិច្ឆ័យរបស់ក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមហើយអាចប៉ះពាល់ដល់ដំណើរការនីតិវិធី និងលទ្ធផលចុងក្រោយនៃរឿងក្តីថែមទៀតផង។

នៅប្រទេសកម្ពុជា រាល់ឯកសណ្ឋានរបស់ជាប់ចោទត្រូវបានកំណត់ដោយនីតិវិធីពន្ធនាគារលេខ ៥ របស់ក្រសួងមហាផ្ទៃស្តីពី "ឯកសណ្ឋានជនជាប់ឃុំ និងបរិក្ខានៅក្នុងបន្ទាប់ឃុំឃាំង មន្ត្រីទទួលបន្ទុកយកអ្នកទោសចូលត្រូវធានានៅពេលទទួលយកអ្នកទោសចូលក្នុងពន្ធនាគារ ត្រូវដល់ឲ្យអ្នកទោសនូវឯកសណ្ឋាន និងសម្ភារៈបរិក្ខាដូចជា៖ អាវអំបោះពណ៌ខៀវផ្ទូតពីរ ខោអំបោះពណ៌ខៀវផ្ទូតពីរ ចំណែកបុគ្គលដែលតុលាការមិនទាន់បានកាត់ទោស ឬការកាត់ទោសមិនទានចូលជាស្ថាពរ តែអ្នកទាំងអស់ត្រូវបានអាជ្ញាធរឃុំខ្លួន នឹងតម្រូវឲ្យស្លៀកពាក់ឯកសណ្ឋានពណ៌ទឹកក្រូចចាស់។ ក្នុងករណីនេះផងដែរ ដើម្បីធានាដោយសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ត្រូវបានគោរពយ៉ាងពេញលេញនោះ ជនជាប់ចោទទាំងអស់ដែលមិនទាន់បានតុលាការកាត់ទោសរួចជាស្ថាពរនោះទេ គួរតែឲ្យពួកគាត់ស្លៀកសម្លៀកបំពាក់ផ្ទាល់ខ្លួនរបស់ពួកគាត់នៅពេលដែលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ប្រសិនបើជនជាប់ចោទទាំងអស់ រាល់ពេលដែលបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានជាអ្នកទោស ឬឯកសណ្ឋានជាអ្នកជាប់ឃុំដែលមិនទាន់ទទួលបានសេចក្តីសម្រេចជាស្ថាពរពីតុលាការនោះទេ នេះបញ្ជាក់ឲ្យឃើញថាការអនុវត្តទទួលបានការសន្មតទុកជាមុនថាគ្មានទោសមិនត្រូវបានគោរព និងអនុវត្តពេញលេញនៅឡើយទេហើយការបង្ហាញខ្លួនចំពោះមុខតុលាការក្នុងឯកសណ្ឋានជាទណ្ឌិតពណ៌ខៀវ គឺបានផ្ទុយនឹងរដ្ឋធម្មនុញ្ញ និងនីតិវិធីលេខ៥ ហើយបញ្ហានេះផងដែរក៏មិនស្របទៅនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលធានានូវសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស និងបទដ្ឋានអន្តរជាតិផងដែរ។

## ៧.សិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ

ជាធម្មតាជនជាប់ចោទទាំងអស់ មានសិទ្ធិសេរីភាពជួបប្រាស្រ័យទាក់ទងជាមួយសាច់ញាតិ សិទ្ធិនេះផងដែរមានការទទួលស្គាល់សឹងតែគ្រប់បណ្តាប្រទេសទាំងអស់ នៅលើសកលលោកមិនថាប្រទេសនោះប្រកាន់យកនៅរបបគោលនយោបាយអ្វីក៏ដោយ។ បើទោះបីជាជនជាប់ទោសត្រូវបានធ្វើការដកហូតនៅសិទ្ធិសំខាន់ៗមួយចំនួនក៏ដោយ តែសិទ្ធិក្នុងការជួបប្រាស្រ័យទាក់ទងជាមួយញាតិ គ្រួសារ បងប្អូន ឪពុកម្តាយ មិត្តភក្តិ ឬមនុស្សជាទីស្រឡាញ់មិនបានច្បាប់ហាមឃាត់នោះទេ ពោលការជួបប្រាស្រ័យទាក់ទងទាំងនេះគឺធ្វើឡើងដោយមន្ត្រីពន្ធនាគារជាអ្នកកំណត់។ ការផ្តល់សិទ្ធិឲ្យជនជាប់ចោទ មានសិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយសាច់ញាតិពិតជាមានសារៈសំខាន់ ជួនកាលពេលដែលសាច់ញាតិបានមកសួរសុខទុក្ខគាត់អាចនាំយកនូវចំណុចសំខាន់ដំណឹងសំខាន់ៗ ឬភស្តុតាងផ្សេងៗដែលមានប្រយោជន៍ដោយជនជាប់ចោទពោលគឺអាចឲ្យជនជាប់ចោទយក

មកធ្វើជាសំអាងហេតុក្នុងពេលសវនាការបាន។ ហេតុដូចនេះហើយមន្ត្រីពន្ធនាគារទាំងអស់ត្រូវបានប្រគល់សិទ្ធិនេះយ៉ាងពេញលេញ ក្នុងការអនុញ្ញាតឲ្យជនទាំងនោះជួបប្រាស្រ័យជាសាច់ញាតិ និងមិត្តភក្តិមិនថាតាមរយៈដោយផ្ទាល់ក្តីតាមរយៈសំបុត្រឆ្លើយឆ្លងក្តី ឬក៏តាមរយៈទូរស័ព្ទក្តី ប៉ុន្តែបើទោះបីជាសិទ្ធិជួបប្រាស្រ័យទាក់ទងជាមួយសាច់ញាតិរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតក្តី ក៏ជាការជួបនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យជាចាំបាច់របស់មន្ត្រីពន្ធនាគារ ។

## ៨.សិទ្ធិមិនត្រូវបានបង្ខំឱ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សក្ខីកម្មប្រឆាំងនិងខ្លួនឯង

បុគ្គលគ្រប់រូប ដែលរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិមិនត្រូវបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព ឬផ្តល់សាក្ខីកម្មប្រឆាំងនឹងខ្លួនឯងនោះទេ ដែលសិទ្ធិនេះផងដែរត្រូវបានការពារដោយច្បាប់ជាតិ និងអន្តរជាតិថែមទៀតផង។ ជាការអនុវត្តសិទ្ធិនេះមានន័យថានៅពេលដែលជនជាប់ចោទបានឆ្លើយសារភាព ជននោះត្រូវឆ្លើយនៅក្នុងស្ថានភាពដែលគ្មានការបង្ខិតបង្ខំ គំរាមកំហែងមិនថាដោយផ្ទាល់ក្តី ឬដោយប្រយោល ក្តីទាំងលើរូបរាងកាយ និងផ្លូវចិត្ត សិទ្ធិនេះផងដែរវាបានជាប់ពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងការហាមឃាត់ពីការធ្វើទារុណកម្ម និងអំពើប្រព្រឹត្តដ៏ឃោឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មឯទៀត ដើម្បីទទួលបាននៅចម្លើយសារភាព ។ ភាគច្រើននៅក្នុងការអនុវត្តជាក់ស្តែង មន្ត្រីតែងតែប្រើប្រាស់មធ្យោបាយបង្ខិតបង្ខំទៅលើរូបរាងកាយរបស់ជនជាប់ចោទក្នុងបំណងស្វែងរកនៅការពិត ក៏ប៉ុន្តែគាត់ពុំបានគិតនោះទេថាភាគច្រើននៅពេលដែលមនុស្សទទួលរងនៅការបង្ខិតបង្ខំទាំងផ្លូវកាយ ផ្លូវចិត្តការទទួលរងនៅទណ្ឌកម្មទោះបីជាអំពើនោះពួកគេមិនបានប្រព្រឹត្តិក្តីក៏ត្រូវសារភាពថាខ្លួនបានប្រព្រឹត្តិដែរដើម្បីជៀសផុតពីការធ្វើបាប[13] ក្នុងករណីនេះផងដែរបើសិនរាល់ការសារភាព ឬចម្លើយណាមួយរបស់ជនជាប់ចោទដែលឆ្លើយទៅដោយមានការបង្ខិតបង្ខំ ការធ្វើទារុណកម្ម ឬអំពើផ្សេងៗទៀតមិនត្រូវបានរាប់បញ្ចូលជាភស្តុតាងនោះទេ[14]។ មិនត្រឹមតែប៉ុណ្ណោះទេ ជនជាប់ចោទដែលទទួលរងនៅការចោទប្រកាន់មិនអាចត្រូវបាននរណាម្នាក់បង្ខំឲ្យឆ្លើយសារភាពដាក់បន្ទុកលើខ្លួនឯង តាមរយៈការផ្តល់សាក្ខីកម្មប្រឆាំងនឹងខ្លួនឯងនោះឡើយ សិទ្ធិនេះផងដែរគឺជាធាតុផ្សំដ៏សំខាន់មួយនៃដំណើរការនីតិវិធីតុលាការ បើទោះបីជាបានភាពពិបាកក្នុងការជឿជាក់ថាការជំនុំជម្រះដោយយុត្តិធម៌ដែលក្នុងនោះជនជាប់ចោទត្រូវបង្ខំឲ្យផ្តល់ភស្តុតាងដាក់បន្ទុកលើខ្លួន។ សិទ្ធិនេះផងដែរផ្តល់ឲ្យជនជាប់ចោទនូវសិទ្ធិមិនផ្តល់ភស្តុតាងទាំងឡាយណាដែលអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងខ្លួនឯង ដើម្បីធានាបានជាការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌត្រូវបានការពារ ឬមិនមានការបង្ខិតបង្ខំដោយអាជ្ញាធរមានសម្ថកិច្ច នៅក្នុងដំណាក់កាលស៊ើបអង្កេតនោះ ចាំបាច់ត្រូវតែមានមេធាវីការពារសិទ្ធិឲ្យជននោះ នៅក្នុងអំឡុងពេលស្តាប់ចម្លើយវត្តមានរបស់មេធាវីនៅ

[13] មាត្រា ៣៨ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[14] មាត្រា ៣២១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងដំណាក់កាលនេះអាចារាំង មន្ត្រីនគរបាលពីការមិនគោរពសិទ្ធិរបស់ជនជាប់ចោទយើងគួរកត់សម្គាល់បានទៀតថា ប្រសិនបើបុគ្គលណាម្នាក់សម្រេចចិត្តអនុវត្តសិទ្ធិមិនត្រូវបានគេបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាពរបស់ខ្លួន ឬផ្តល់សាក្សីកម្មប្រឆាំងនឹងខ្លួនឯង កាលៈទេសៈនេះហាមឃាត់ដល់ចៅក្រម ក្នុងការទាញយកសេចក្តីសន្និដ្ឋានអវិជ្ជមានពីការនៅស្ងៀមរបស់បុគ្គលនោះ។

## ៩.សិទ្ធិរួចផុតពីការធ្វើទារុណកម្ម

គ្មានជនណាម្នាក់ត្រូវបានគេរំលោភបំពានសិទ្ធិ នឹងធ្វើទារុណកម្មទៅតាមអំពើចិត្តនោះឡើយ ទារុណកម្ម គឺជាអំពើមួយដែលធ្វើឲ្យមានការឈឺចាប់ ឬការទទួលរងធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តឡើងដោយចេតនាទៅលើបុគ្គលណាម្នាក់ក្នុងគោលបំណងដូចជាទទួលបានពីបុគ្គលនោះ ដើម្បីទទួលនូវព័ត៌មាន ឬចម្លើយសារភាព ដើម្បីផ្តន្ទាទោសបុគ្គលនោះចំពោះអំពើដែលគាត់បានប្រព្រឹត្តនោះឡើយ ដែលបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរផ្លូវកាយ និងផ្លូវចិត្ត។ សិទ្ធិរួចផុតពីការធ្វើទារុណកម្មបានផ្សារភ្ជាប់យ៉ាងសំខាន់ទាក់ទងទៅដល់សេចក្តីសុខផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ក្នុងករណីដែលមន្ត្រីនគរបាលមួយចំនួនមិនយល់ដឹងពីច្បាប់ តែងតែប្រព្រឹត្តនៅអំពើទារុណកម្មទៅលើជនជាប់ចោទ ដែលកំពុងតែឃុំខ្លួនរងចាំការជំនុំជម្រះការធ្វើឲ្យមានការឈឺចាប់ទាំងផ្លូវកាយ នឹងផ្លូវចិត្តដល់ជនជាប់ចោទនេះត្រូវបានចាត់ទុកថាជាការធ្វើទារុណកម្ម ដូចនេះរាល់សកម្មភាពទាំងឡាយដែលប្រព្រឹត្តទៅលើជនជាប់ចោទដូចជាការដាក់គុកងងឹត ការបង្អត់អាហារឲ្យជនជាប់ចោទ និងទណ្ឌកម្មផ្សេងៗទៀត ដែលមានលក្ខណៈឃោឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នាំឲ្យបាត់បង់តម្លៃជាមនុស្សត្រូវបានហាមឃាត់ជាដាច់ខាត់។ ដែលការហាមឃាត់នេះផងដែរបានចែងយ៉ាងជាក់ច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រា ៣៨ បានចែងថាការបង្ខិតបង្ខំការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តអំពើណាមួយដែលបន្ថែមទម្ងន់ទោសទៅលើជនដែលជាប់ចោទត្រូវហាមឃាត់មិនឲ្យធ្វើឡើយ[15]។

## ១០.សិទ្ធិទទួលបានការព្យាបាល និងពិនិត្យសុខភាព

ជនជាប់ចោទ ទាំងអស់ដែលកំពុងស្ថិតនៅក្នុងដំណាក់កាលឃុំខ្លួនបណ្តោះអាសន្ន មានសិទ្ធិទទួលបានសេវាថែទាំសុខភាពជាប្រចាំដោយមន្ត្រីពេទ្យពន្ធនាគារ។ ក្នុងករណីដែលជនជាប់ចោទមានជម្ងឺធ្ងន់ដែលតម្រូវឲ្យមានការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យខាងក្រៅ ប្រធានពន្ធនាគារត្រូវបញ្ជូនអ្នកជម្ងឺទៅមន្ទីរពេទ្យជាបន្ទាន់តាមសំណើរមន្ត្រីពេទ្យពន្ធនាគារ ហើយត្រូវជូនដំណឹងដល់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ព្រះរាជអាជ្ញាក្នុងដែនសមត្ថកិច្ចត្រូវជូនដំណឹងដល់គ្រួសារសាច់ញាតិ ឬមិត្តភក្តិជិតស្និទ្ធបំផុតតាមសំណើរបស់ជនជាប់ចោទ។ មណ្ឌលអប់រំកែប្រែ និងពន្ធនាគាររបស់កម្ពុជានាពេលបច្ចុប្បន្នមាន

---

[15] មាត្រា ៣៨ រដ្ឋធម្មនុញ្ញា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ជនជាប់ចោទ ជាច្រើនដែលកំពុងជួបប្រទះនិងបញ្ហាសុខភាពដែលបញ្ហានេះបណ្តាលមកពីកត្តាជាច្រើន ប៉ុន្តែក្នុងនោះយើងសង្កេតឃើញថាមានកត្តាពីរជាសំខាន់គឺ **កត្តាបរិយាកាស និងកត្តាបរិស្ថាន** ។

**បរិយាកាស៖** នៅក្នុងបន្ទប់ពន្ធនាគារនៅប្រទេសកម្ពុជាភាគច្រើន គឺផ្ទុកជនជាប់ចោទលើសចំនួនដោយសារចំនួនជាប់ឃុំ ចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំឥតឈប់ឈរធ្វើឲ្យពន្ធនាគារខ្លះមានជនជាប់ឃុំលើសទ្វេដង។ បន្ទប់ពន្ធនាគារដែលមានជនជាប់ឃុំច្រើន នេះហើយដែលបណ្តាលឲ្យបរិយាកាសនៃការរស់នៅរបស់ជនជាប់ឃុំមានការលំបាកដែលជួបប្រទះទៅនិងបញ្ហាខ្យល់ដកដង្ហើម បញ្ហាអនាម័យក្នុងការរស់នៅផងដែរ។

**បរិស្ថាន៖** ចំពោះបញ្ហានេះវិញគឺជាបញ្ហាធំដែលកើតមានផងដែរដូចជា កង្វះទឹកស្អាត បរិភោគមិនគ្រប់គ្រាន់ ។

ចំពោះបញ្ហាទាំងពីរ ខាងលើកំពុងតែប្រឈមយ៉ាងខ្លាំងនៅក្នុងពន្ធនាគារដែលធ្វើឲ្យជនជាប់ចោទចេះតែមានជម្ងឺញឹកញាប់ ហើយចំពោះប្រភេទជម្ងឺដែលបានកើតមានឡើងនៅក្នុងមណ្ឌលអប់រំកែប្រែក៏ដូចជាពន្ធនាគារគឺមានដូចជា៖ ផ្តាសាយ រាគ គ្រុនក្តៅ របេង ជម្ងឺផ្លូវចិត្ត ជម្ងឺលើសឈាម ឈឺក្រពះ រមាស់ រោគស្ត្រី ជាដើម។ បញ្ហាទាំងអស់ខាងលើយើងសង្កេតឃើញថារដ្ឋាភិបាល ក៏បានយកចិត្តទុកដាក់ដោយបានបង្កើតប៉ុស្តិ៍សុខភាព ឬអាគារសុខាភិបាលនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារដើម្បីព្យាបាលថែទាំសុខភាពដល់ជនជាប់ឃុំ។ ចំពោះការព្យាបាលជម្ងឺនៅពន្ធនាគារ គឺពន្ធនាគារមានអាគារសុខាភិបាលមួយសម្រាប់ទទួលអ្នកជម្ងឺដែលជាជនជាប់ឃុំ ក៏ប៉ុន្តែទោះបីជាមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារមានអាគារសុខាភិបាលសម្រាប់មើលថែរក្សាអ្នកជម្ងឺពិតមែនតែការព្យាបាល គឺមិនបាន១០០ភាគរយនោះទេដោយសារតែមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារគ្មានឱសថគ្រប់គ្រាន់អាគារសម្រាកព្យាបាលកំណត់ចំនួនអ្នកជម្ងឺ។ ចំពោះការថែទាំអ្នកជម្ងឺវិញ ក៏មិនសូវបានដិតដល់ដែរដោយសារបញ្ហាដូចដែលបានរៀបរាប់ខាងលើគឺការកង្វះទាំងសម្ភារៈ និងឱសថសម្រាប់ព្យាបាល ការកង្វះខាតបែបនេះធ្វើឲ្យអង្គការសប្បុរសធម៌ ដែលមិនមែនជាអង្គការរបស់រដ្ឋាភិបាលបានចុះជួយព្យាបាលជនជាប់ឃុំក្រៅពីអង្គការដែលបានជួយក៏មានមន្ត្រីពន្ធនាគារ ក៏បានខ្នះខ្នែងជួយទំនុកបម្រុងផងដែរ មន្ត្រីទាំងនោះបានធ្វើកំណត់ហេតុជម្ងឺរបស់ជនជាប់ឃុំចូលថ្មី ប្រសិនបើពិនិត្យឃើញថាមានជម្ងឺត្រូវដាក់ដាច់ដោយឡែកពីជនជាប់ឃុំដើម្បីងាយស្រួលក្នុងការថែទាំ និងព្យាបាលហើយបង្ការកុំឲ្យឆ្លងទៅអ្នកដទៃបាន។

### ១១.សិទ្ធិទទួលបានការជំនុំជម្រះដោយមិនពន្យារពេលយូរ

សិទ្ធិនេះ គឺជាគោលការណ៍មួយនៃនីតិវិធីព្រហ្មទណ្ឌដែលចេញពីការសន្មត់ទុកជាមុនថាគ្មានទោសរហូតដល់មានសាលក្រមចូលជាស្ថាពរ និងជាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះនៅក្នុងរយៈពេលដ៏សមរម្យមួយដែលមិនពន្យាពេលយូរ ហើយការជំនុំជម្រះជនជាប់ចោទក្រោមច្បាប់នៃព្រះរាជាណា

ចក្រកម្ពុជាយើងនេះត្រូវធ្វើឡើងក្នុងអំឡុងពេល ៦ ខែ ចាប់តាំងពីថ្ងៃចាប់ខ្លួន[16]។ ដូចនេះប្រសិនបើមានការពន្យាពេលក្នុងការការស៊ើបអង្កេត ឬការឃុំខ្លួនហួសកំណត់ដោយមិនបានបើកសវនាការ គឺជាការរំលោភបំពានមួយដែលមិនសមហេតុផលក៏ដូចជាការរំលោភសិទ្ធិរបស់បុគ្គលផងដែរ ដោយសារការពន្យាពេលយូរក្នុងការនាំខ្លួនជនជាប់ចោទមកសវនាការជាការរំលោភសិទ្ធិ ជាមូលដ្ឋានរបស់បុគ្គលដល់ដំណើរការសវនាការដោយយុត្តិធម៌ ព្រោះវាអាចមានបុរេវិនិច្ឆ័យចំពោះសមត្ថភាពជនជាប់ចោទក្នុងការបង្ហាញនូវការការពារឲ្យមានប្រសិទ្ធិភាព ព្រោះថាសាក្សីសំខាន់ៗអាចនឹងត្រូវបាត់ខ្លួន ឬស្លាប់ចំណែកឯភស្តុតាងសំខាន់ៗក៏អាចប្រឈមនឹងការបាត់បង់បានដែរ ដោយសារការពន្យាពេលយូរអាចធ្វើឲ្យការជំនុំជម្រះមិនអាចប្រកបដោយភាពយុត្តិធម៌បាន។ ក្នុងនោះដែរជនជាប់ចោទក៏មានសិទ្ធិទទួលបានដំណឹងពីថ្ងៃជំនុំជម្រះ ដែលតុលាការមានសមត្ថកិច្ចត្រូវជូនដំណឹងពីថ្ងៃជំនុំជម្រះនេះឲ្យបានមុនរយៈពេល ១៥ ថ្ងៃមុន។ ការជូនដំណឹងនេះគឺដើម្បីឲ្យជនជាប់ចោទមានពេលវេលាគ្រប់គ្រាន់សម្រាប់ជួបទីប្រឹក្សា ឬមេធាវីរបស់ខ្លួន ដើម្បីឲ្យពួកគេអាចធ្វើការរៀបចំពិនិត្យឯកសារផ្សេងៗ ជាពិសេសពិនិត្យរកភស្តុតាង និងសាក្សីនានាសម្រាប់ការពារខ្លួនចំពោះមុខ ព្រះរាជអាជ្ញានៅពេលសវនាការ។

## ផ្នែកទី២. សិទ្ធិជនជាប់ចោទក្នុងពេលសវនាការ

### ១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាគោលការណ៍មូលដ្ឋានមួយនៃនីតិរដ្ឋនៅក្នុងសង្គមប្រជាធិបតេយ្យ និងសំដៅធានាដល់សិទ្ធិទទួលបានការគ្រប់គ្រងត្រឹមត្រូវលើយុត្តិធម៌[17]។ ការគ្រប់គ្រងត្រឹមត្រូវលើយុត្តិធម៌អាចសំដៅលើនីតិរដ្ឋបាល ឬតុលាការគ្រប់គ្រងនេះសំដៅការការពារបុគ្គល ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌពីការបន្ថយ ឬការដកសិទ្ធិ និងសេរីភាពមូលដ្ឋានតាមអំពើចិត្ត ដូច្នេះហើយសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កាភាពអយុត្តិធម៌នៅក្នុងសង្គមតាមរយៈការការពារអ្នកគ្មានកំហុសពីការផ្តន្ទាទោសខុស និងការធានាថាភាពជាប់ពិរុទ្ធត្រូវទទួលទោសតាមបទល្មើសដែលបានប្រព្រឹត្តិ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានទទួលស្គាល់ជាសកល និងត្រូវបានសម្រេចក្រោមលិខិតតូបករណ៍អន្តរជាតិសំខាន់ៗជាច្រើន សិទ្ធិនេះមានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៩ និងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិអ្នកនយោបាយដែលបានចែងថាបុគ្គលណាដែលបានចាប់ខ្លួននិងត្រូវបាននាំយកទៅចំពោះមុខចៅក្រម និងជនគ្រប់រូបត្រូវមានសិទ្ធិជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈ[18]។ ដើម្បីធានាថាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវតែតាមដាន

[16] មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[17] មាត្រា ៦ នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស

[18] មាត្រា ៩ មាត្រា១៥ កតិសញ្ញាអន្តរចាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

នៅគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ ចាប់តាំងពីពេលចាប់ខ្លួនរហូតដល់ដំណាក់កាលចេញសាលក្រមចុងក្រោយ ការវិភាគគ្រប់ទិដ្ឋភាពនីមួយៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌អាចអនុវត្តបានគ្រប់ដំណាក់កាលទាំងអស់ ហើយការរំលោភបំពានសិទ្ធិនេះមាននៅក្នុងដំណាក់កាលណាមួយវាអាចប៉ះពាល់ដល់ដំណាក់កាលផ្សេងទៀត។

## ២.សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការកំណត់ថាមានទោស ឬគ្មានទោសនៅក្នុងការជំនុំជម្រះ។ ដោយការជំនុំជម្រះ ជាគោលការណ៍ត្រូវធ្វើឡើងជាសាធារណៈលើកលែងតែក្នុងកាលៈទេសៈមួយចំនួន ចំណុចនេះមានន័យថាដំណើរការជំនុំជម្រះតម្រូវឲ្យធ្វើឡើងជាសាធារណៈ និងផ្ទាល់មាត់ស្របតាមគោលការណ៍ ដើម្បីធានាឲ្យបាននូវតម្លាភាពនៃដំណើរការកាត់ក្តី សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ ត្រូវអនុវត្តនៅគ្រប់កិច្ចដំណើរការជំនុំជម្រះរឿងព្រហ្មទណ្ឌទាំងអស់ ឬបញ្ហាពាក់ព័ន្ធនឹងបណ្តឹងផ្លូវច្បាប់។ ដើម្បីធានាឲ្យមានការគោរពសិទ្ធិរបស់ជនជាប់ចោទ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈនេះផងដែរ ត្រូវតែធ្វើឡើងដោយបើកចំហរសម្រាប់សាធារណៈជនដោយក្នុងនោះរួមមាន៖ អ្នកសារព័ត៌មាន សាធារណៈជនត្រូវតែបានទទួលដំណឹងអំពីទីកន្លែង និងកាលបរិច្ឆេទជំនុំជម្រះបើទោះបីជាការជំនុំជម្រះត្រូវធ្វើឡើងជាសាធារណៈ តែក្នុងករណីនៃកាលៈទេសៈ លើកលែងមួយចំនួនផងដែរមិនតម្រូវអនុញ្ញាតឲ្យសាធារណៈជនចូលរួមក្នុងដំណើរការជំនុំជម្រះសាលក្រមដែលរួមមានទាំងលទ្ធផលរកឃើញនូវភ័ស្តុតាងសំខាន់ៗផងដែរ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានការពារដោយកតិកាសញ្ញាអន្តរជាតិ ហើយត្រូវបានអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់កម្ពុជាតាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣[19] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈជាមូលដ្ឋានគ្រឹះមួយក្នុងការធានានូវតម្លាភាព និងគណនេយ្យភាពនៃដំណើរការកាត់ក្តីនៅក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ហើយសិទ្ធិនេះក៏បានការពារប្រយោជន៍យ៉ាងសំខាន់សម្រាប់ជនជាប់ចោទខ្លួនឯងផ្ទាល់ និងសង្គមថែមទៀតផងការធ្វើសវនាការជាសាធារណៈបានផ្តល់ឲ្យជនជាប់ចោទក្នុងការចូលរួមពិនិត្យពិច័យជាសាធារណៈ អាចជួយដល់ការត្រួតពិនិត្យទៅលើការធ្វើការសម្រេចចិត្តតាមអំពើចិត្តការបំពានអំណាច និងការបំពាននីតិវិធីរួមទាំងការជ្រៀតជ្រែក និងការជះឥទ្ធិពលពីខាងក្រៅ។ ការបើកសវនាការជាសាធារណៈដែលអនុញ្ញាតឲ្យអ្នកសារព័ត៌មាន និងសាធារណៈជនធ្វើការតាមដាននិងស្វែងយល់ថាតើដំណើរការ និងសេចក្តីសម្រេចដែលតុលាការបានចេញមានយុត្តិធម៌កម្រិតណានៅក្នុងស្ថាប័នតុលាការ ក្នុងករណីដែលមានការរារាំងមិនឲ្យសាធារណជនតាមដានដំណើរការយុត្តិធម៌ គឺជាអំពើគំរាមកំហែងមួយទៅលើនីតិរដ្ឋ ហើយនាំឲ្យមានអំពើពុករលួយដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំ

[19] មាត្រា ៣១ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ ព្រោះពួកគេអាចនឹងត្រូវប្រឈមជាមួយនឹងការផ្តន្ទាទោសមិនត្រឹមត្រូវ និងការសម្រេចទោសដោយអយុត្តិធម៌។ ក្នុងនេះផងដែរច្បាប់បានរឹតត្បិតលើសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈនៅក្នុងលក្ខខណ្ឌជាក់លាក់មួយចំនួនដូចជា៖

- សីលធម៌ (ប្រសិនបើសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសផ្លូវភេទ)
- សណ្តាប់ធ្នាប់សាធារណៈ
- សន្តិសុខជាតិនៅក្នុងសង្គមប្រជាធិបតេយ្យ
- ការជំនុំជម្រះទៅលើអនីតិជន
- ក្នុងស្ថានភាពពិសេសនៅពេលតុលាការយល់ឃើថា ការធ្វើជាសាធារណៈនឹងនាំឲ្យខូចដល់ប្រយោជន៍យុត្តិធម៌។

## ៣.សិទ្ធការពារខ្លួនក្នុងពេលសវនាការ

ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទាំងអស់ មានសិទ្ធការពារខ្លួនក្នុងពេលសវនាការ ជនជាប់ចោទទាំងអស់ត្រូវដឹងពីបទល្មើសព្រហ្មទណ្ឌ និងសិទ្ធិការពារខ្លួនឯងដោយផ្ទាល់ ឬទទួលបានការការពារពីមេធាវីដែលមានជំនាញ និងមានបទពិសោធក្នុងការការពារក្តីតាមការជ្រើសតាំងរបស់ខ្លួន[20]។ ក្នុងការការពារខ្លួនក្នុងសវនាការ និងសិទ្ធិមានមេធាវីក្នុងករណីជនជាប់ចោទសម្រេចចិត្តសុំពឹងពាក់មេធាវីឲ្យការពារក្តីឲ្យខ្លួននោះ មេធាវីមានសិទ្ធិក្នុងការសិក្សាពីសំណុំរឿងក្នុងការអនុវត្តសំណុំរឿងរបស់ ជនជាប់ចោទ ដែលស្ថិតនៅក្នុងដែនកំណត់នៃការទទួលខុសត្រូវរបស់វិជ្ជាជីវៈខ្លួន។ ដោយឡែកក្នុងករណីដែលជនជាប់ចោទសម្រេចចិត្តក្នុងការការពារខ្លួនឯងដោយផ្ទាល់ ពួកគេមានសិទ្ធិបដិសេធមិនទទួលជំនួយពីមេធាវីក្នុងវិសាលភាពជាក់លាក់ណាមួយ ដើម្បីមានលទ្ធភាពការពារខ្លួនដោយផ្ទាល់ ឬណែនាំមេធាវីចំពោះការការពារក្តីរបស់ខ្លួន ជនជាប់ចោទទាំងអស់ត្រូវតែអនុញ្ញាតឲ្យមានវត្តមាននៅក្នុងពេលសវនាការ។ ដើម្បីធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនក្នុងសវនាការ (ការពារខ្លួនឯង ឬមានមេធាវី)។ មន្ត្រីនគរបាលយុត្តិធម៌ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះត្រូវប្រាប់ទៅជនជាប់ចោទទាំងអស់ឲ្យបានទទួលដំណឹងអំពីសិទ្ធិរបស់ខ្លួន ដើម្បីឲ្យពួកគេមាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តីដោយខ្លួនឯង ឬពឹងពាក់មេធាវី។ យោងតាមសិទ្ធការពារខ្លួនដោយខ្លួនឯង សិទ្ធិមានមេធាវីត្រូវបានលះបង់ប្រសិនបើជនជាប់ចោទមានបំណងការពារក្តីដោយខ្លួនឯង ដែលការលះបង់សិទ្ធិនេះត្រូវធ្វើឡើងដោយជនជាប់ចោទខ្លួនឯងផ្ទាល់ និងតម្រូវឲ្យមានសមត្ថភាពច្បាស់លាស់ជាពិសេស ចំណុចនេះត្រូវយល់ដឹងថានៅពេលដែលសម្រេចចិត្តលះបង់ សិទ្ធិមានមេធាវីវាមានផលវិបាកយ៉ាងណាខ្លះ។

[20] មាត្រា ១៤ កតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ប៉ុន្តែក្នុងករណីដែលជនជាប់ចោទយល់ថាការការពារខ្លួនដោយខ្លួនឯងមានផលវិបាកជនជាប់ចោទ ក៏អាចស្នើសុំលុបចោលសិទ្ធិការពារខ្លួនដោយខ្លួនឯងបានដែរ នៅគ្រប់ដំណាក់កាលនៃនីតិវិធីទាំងអស់ ប្រសិនបើជនជាប់ចោទខ្លួនឯងផ្ទាល់ផ្លាស់ប្តូរចិត្ត។ បើទោះបីជាជនជាប់ចោទមានសិទ្ធិនៅក្នុងការការពារខ្លួនឯង ក៏ពិតមែនក៏មានករណីមួយចំនួនផងដែរដែលជនជាប់ចោទមិនអាចការពារខ្លួនឯងដោយផ្ទាល់បាន៖ ប្រសិនបើជនជាប់ចោទទទួលរងនូវការចោទប្រកាន់ធ្ងន់ធ្ងរ ហើយតុលាការសម្រេចថាជនជាប់ចោទមិនអាចបំពេញតួនាទីស្របតាមឧត្តមប្រយោជន៍របស់ខ្លួនបានទេ។

- ប្រសិនបើជនជាប់ចោទតែងតែរារាំង ឬរំខានដល់ដំណើរការនៃនីតិវិធី
- ឬជនជាប់ចោទណា ដែលងាយទទួលរងការបំភិតបំភ័យនៃការសាកសួរ ការតទល់គ្នាដោយជនជាប់ចោទ
- ក្នុងករណីជនជាប់ចោទជាអនីតិជន ឬជនដែលបានប្រព្រឹត្តបទឧក្រិដ្ឋមិនថាជនជាប់ចោទសម្រេចចិត្តការពារខ្លួនឯងដោយផ្ទាល់ ឬតាមរយៈមេធាវីប៉ុន្តែសិទ្ធិក្នុងការការពារខ្លួននេះពិតជាមានសារៈសំខាន់ក្នុងការធានាឲ្យបាននូវការជំនុំជម្រះដោយយុត្តិធម៌[21]។

## ៤.សិទ្ធមានវត្តមានក្នុងសវនាការ

សវនាការក្នុងរឿងក្តីព្រហ្មទណ្ឌដាច់ខាតត្រូវតែមានវត្តមានរបស់ជនជាប់ចោទ ប្រសិនបើដំណើរការសវនាការមិនមានវត្តមានរបស់ជនជាប់ចោទនោះទេ វាគឺជាការរំលោភបំពានទៅលើគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ដូចបានរៀបរាប់ខាងលើ ក្នុងករណីដែលជនជាប់ចោទមិនមានវត្តមានក្នុងសវនាការនោះទេ ជនជាប់ចោទពុំអាចផ្តល់ជាសំអាងហេតុ ឬក៏ជាសំណូមពរចុងក្រោយទៅកាន់តុលាការបាននោះទេ វត្តមានរបស់ជនជាប់ចោទនៅក្នុងពេលសវនាការ អាចអនុញ្ញាតឲ្យជនជាប់ចោទបានដឹងបានឮអំពីការចោទប្រកាន់របស់តំណាងអយ្យការមកលើខ្លួន និងតទល់ទៅនឹងការចោទប្រកាន់របស់តំណាងអយ្យការតាមរយៈការលើកយកភស្តុតាងមកការពារខ្លួន ដើម្បីធានាថាសិទ្ធិមានវត្តមានលើកពេលសវនាការត្រូវបានគោរព និងអនុវត្តដោយអាជ្ញាធររដ្ឋ មន្ត្រីនគរបាល មន្ត្រីពន្ធនាគារត្រូវជូនដំណឹងដល់ជនជាប់ចោទ និងមេធាវីការពាររបស់ពួកគេព្រមទាំងបញ្ជាក់ឲ្យបានច្បាស់លាស់អំពីកាលបរិច្ឆេទ និងទីកន្លែងសវនាការទៅកាន់ពួកគេដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៣០០ បានចែងថា ជនជាប់ចោទត្រូវតែចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់ ជនជាប់ចោទអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើស[22]។ វត្តមានរបស់ជនជាប់ចោទនៅក្នុងពេលសវនាការអាចធ្វើឲ្យជនជាប់ចោទបានដឹងបានឮ និងលើកយកភស្តុតាងមកតទល់ដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់

[21] មាត្រា ៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[22] មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មកលើខ្លួន និងបង្ហាញនូវភស្តុតាងសម្រាប់ការពារក្តីព្រមទាំងផ្តល់នូវសក្ខីកម្មដល់ខ្លួនឯងនៅក្នុងពេលសវនាការ ក្នុងករណីបើកសវនាការកំបាំងមុខជនជាប់ចោទត្រូវបានអនុញ្ញាតថតនៅក្នុងករណីមួយចំនួនតែប៉ុណ្ណោះ។

**៥.សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង**

ជនណាដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិទទួលបានការជំនុំជម្រះលើសំណុំរឿងរបស់ខ្លួនដោយសាលាជម្រះក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់ សាលាជម្រះក្តីមានន័យថា ជាស្ថាប័នមួយដែលបង្កើតឡើងដោយច្បាប់ ឯករាជ្យ មិនលម្អៀង ទៅខាងស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ ឬមិនលម្អៀងទៅខាងយុត្តាធិការថ្នាក់លើនោះទេ។ សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ មិនលម្អៀងមានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលរួមបញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់ជាតិនៃប្រទេសកម្ពុជា។ ជនជាប់ចោទទាំងអស់មានសិទ្ធិស្មើគ្នា សិទ្ធិពេញលេញដើម្បីសុំឲ្យតុលាការឯករាជ្យ មិនលម្អៀង និងពិនិត្យមើលរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ក្នុងការសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទល្មើសព្រហ្មទណ្ឌ។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ផ្សេងជាច្រើនទៀតបានកំណត់អំពីលក្ខខណ្ឌតម្រូវនៃសមត្ថកិច្ចតុលាការឯករាជ្យ និងមិនលម្អៀងដូចខាងក្រោម៖

- មាត្រា **១២៨** នៃរដ្ឋធម្មនុញ្ញ៖ អំណាចតុលាការជាអំណាចឯករាជ្យ អំណាចតុលាការ ធានារក្សា អនាគតិ និងការពារសិទ្ធិអំណាចតុលាការជាអំណាចឯករាជ្យ សេរីភាពរបស់ប្រជាពលរដ្ឋ[23]។

- មាត្រា **១២៩** នៃរដ្ឋធម្មនុញ្ញ៖ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយតគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន[24]។

- មាត្រា **១** នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ៖ ច្បាប់នេះមានគោលបំណង ធានាឯករាជ្យនៃអំណាចតុលាការ ធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការលើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធិភាព និងឆាប់រហ័សធានាដល់ការផ្តល់យុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹងសុវត្ថិភាពសង្គម[25]។

---

[23] មាត្រា ១២៨ រដ្ឋធម្មនុញ្ញា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[24] មាត្រា ១២៩ រដ្ឋធម្មនុញ្ញា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[25] មាត្រា ១ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

- មាត្រា **៦** នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ៖ មានតែចៅក្រមទេដែលមានសិទ្ធិជម្រះក្តី។ ចៅក្រមត្រូវបំពេញភារកិច្ចនេះ ដោយឯករាជ្យ ដោយគោរពយ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន[26] ។

ជារួមសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ពិតជាមានសារៈសំខាន់ណាស់ក្នុងការធានានូវការគ្រប់គ្រងយុត្តិធម៌ត្រឹមត្រូវ និងនីតិរដ្ឋ។ លក្ខខណ្ឌតម្រូវរបស់តុលាការមានសមត្ថកិច្ច មន្ត្រីតុលាការ ដែលជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌមានជំនាញផ្នែកច្បាប់ និងសុចរិតភាពគ្រប់គ្រាន់ដើម្បីធ្វើការសម្រេចសេចក្តីដោយសត្យានុម័ត និងអព្យាក្រឹតផ្អែកទាំងស្រុងទៅលើភស្តុតាង និងស្របតាមច្បាប់ដែលបានកំណត់តែប៉ុណ្ណោះ។ ចំពោះតុលាការឯករាជ្យត្រូវធានាឲ្យបានថាសេចក្តីសម្រេចដែលចេញដោយតុលាការគឺមិនទទួលរងនៅឥទ្ធិពលពីអ្នកណាមិនថាជាមូលហេតុនយោបាយ ឬមូលហេតុផ្ទាល់ខ្លួន ដែលនេះជាការធានានូវឯករាជ្យភាពនៃអំណាចតុលាការរវាងអង្គការនីតិបញ្ញត្តិ អង្គការនីតិប្រតិបត្តិ និងតុលាការខ្លួនឯងផ្ទាល់ ហេតុដូច្នេះចំពោះការមិនគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង វានាំឲ្យមានផលប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។

## ៦.សិទ្ធិស្នើសុំឲ្យមានអ្នកបកប្រែ

នៅក្នុងពេលសវនាការ ក្នុងករណីដែលជនជាប់ចោទទាំងអស់ជាជនបរទេស ត្រូវទទួលបានអ្នកបកប្រែដោយឥតគិតថ្លៃឈ្នួលនោះទេ ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនចេះភាសាផ្លូវការដែលប្រើប្រាស់នៅក្នុងសវនាការ ដែលជាទូទៅភាសាដែលប្រើប្រាស់នៅក្នុងតុលាការបច្ចុប្បន្នជាភាសាខ្មែរ ដូច្នេះហើយតុលាការត្រូវផ្តល់សិទ្ធិដល់ជនចាប់ចោទក្នុងការស្វែងរកអ្នកបកប្រែដោយខ្លួនឯងផ្ទាល់ ឬតាមរយៈការស្នើសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ប៉ុន្តែក្នុងករណីដែលជនជាប់ចោទពុំមានលទ្ធភាពទេគឺតុលាការត្រូវផ្តល់ជំនួយដោយឥតគិតថ្លៃនូវអ្នកបកប្រែផ្ទាល់មាត់ ដែលមានសមត្ថភាពហើយការបកប្រែនោះចាំបាច់ដើម្បីបំពេញបានតាមលក្ខខណ្ឌតម្រូវការនៃភាពយុត្តិធម៌ សិទ្ធិមានអ្នកបកប្រែនេះភាគច្រើនសំដៅលើជនបរទេស ឬជាជនដែលមិនចេះអក្សរ ហេតុនេះហើយទើបតម្រូវឲ្យមានអ្នកបកប្រែភាសាសម្រាប់ជួយដោយឥតគិតថ្លៃឈ្នួលប្រសិនបើសាមីជននោះមិនចេះស្តាប់ភាសា ដែលប្រើក្នុងការកាត់ក្តីនោះដូចនេះនៅក្នុងសវនាការត្រូវតែរកអ្នកបកប្រែជូនភាគីនៅក្នុងរឿងក្តីដែលមិនចេះភាសា ឬជាជន គ ថ្លង់ តាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ មាត្រា **១៣៦** បានចែងថាបើជនជាប់ចោទ ឬសាក្សីជាមនុស្ស គ ថ្លង់ ប៉ុន្តែចេះសរសេរអក្សរនោះក្រឡាបញ្ជីត្រូវសរសេរសំណួរ

[26] មាត្រា ៦ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

និងការកត់សម្គាល់ផ្សេងៗទៅឲ្យជនជាប់ចោទ ឬសាក្សី គ ថ្លង់ នោះដើម្បីធ្វើការឆ្លើយមកវិញដោយលាយលក្ខណ៍អក្សរ[27]។ បើជន គ ថ្លង់មិន ចេះសរសេរអក្សរចៅក្រមត្រូវតែងតាំងដោយឯកឯងនូវ ជនណាម្នាក់ដែលចេះភាសាកាយវិកាសម្រាប់ធ្វើការឆ្លើយឆ្លងជាមួយមនុស្ស គ ថ្លង់ ដោយកាយវិការ។ ដូច្នេះយើងឃើញថានៅប្រទេសកម្ពុជាយើងក៏មានការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ផងដែរ នូវសិទ្ធិមានអ្នកបកប្រែភាសាសម្រាប់ផ្តល់ជូនភាគី ឬក៏សម្រាប់ជនជាប់ចោទដូចជាតាមរយៈលិខិតតូបករណ៍អន្តរជាតិ សិទ្ធិមនុស្សអន្តរជាតិដែលបានរៀបរាប់ខាងលើ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ក៏បានប្រកាសយ៉ាងទូលំទូលាយក្នុងការស្គាល់នូវលិខិតតូបករណ៍សិទ្ធិមនុស្សអន្តរជាតិទាំងអស់នេះ។

## ៧.សិទ្ធិស្នើសុំផ្លាស់ប្តូរមេធាវី

មេធាវី ត្រូវបានគេចាត់ទុកជាបុគ្គលម្នាក់ដែលត្រូវបានគេដឹងថាមានទេពកោសល្យក្នុងការការពារក្តីទោះបីជារឿងនោះជារឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីក៏ដោយ។ ជាទូទៅនៅពេលដែលជនណាម្នាក់ត្រូវបាន ជាប់ចោទថាបានប្រព្រឹត្តបទល្មើសអ្វីមួយ (ខ្លួនរមែងតែងតែចង់ទទួលបាននូវទីប្រឹក្សា ឬមេធាវីដែលមានបទពិសោធន៍ច្រើនក្នុងការការពារក្តីដើម្បីជួយឲ្យខ្លួនរួចផុតពីការចោទប្រកាន់)។ ប៉ុន្តែក្នុងករណីដែលយល់ឃើញថាកាលបើទីប្រឹក្សា ឬមេធាវីដែលការពារសិទ្ធិឲ្យខ្លួននោះគ្មានសមត្ថភាពគ្រប់គ្រាន់ពោលគឺពុំសូវមានជំនាញក្នុងការការពារក្តីវាជាហេតុផលមួយដែលធ្វើឲ្យជនជាប់ចោទ ដែលជាកូនក្តីរបស់ខ្លួនប្រាកដជាប្រឈមមុខនិងការទទួលទោស ដូច្នេះហើយជនជាប់ចោទមានសិទ្ធិសុំធ្វើការផ្លាស់ប្តូរមេធាវីបានចំពោះមេធាវីថ្មីដែលខ្លួនបានជ្រើសរើសសម្រាប់ការពារនេះត្រូវធ្វើការទំនាក់ទំនងជាមួយមេធាវីចាស់ ក្នុងគោលដៅដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់អំពីសំណុំរឿងទាំងឡាយដែលជាប់ពាក់ព័ន្ធទៅ នឹងកូនក្តីខ្លួនដើម្បីចាប់ផ្តើមនីតិវិធីការពារជាថ្មីម្តងទៀត។

## ៨.សិទ្ធិស្នើសុំផ្លាស់ប្តូរចៅក្រម

ជនជាប់ចោទទាំងអស់នៅក្នុងបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិក្នុងការស្នើសុំផ្លាស់ប្តូរចៅក្រមមិនថានៅក្នុងដំណាក់កាលស៊ើបសួរ ឬដំណាក់កាលជំនុំជម្រះនោះទេ ជនជាប់ចោទអាចធ្វើបានតាមរយៈបណ្តឹងជិតចិត្តចៅក្រម ក្នុងករណីដែលយល់ឃើញថាចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះនោះមានភាពលម្អៀង និងមិនអាចផ្តល់នៅភាពយុត្តិធម៌ឲ្យខ្លួនបាន។ បណ្តឹងជិតចិត្តចៅក្រម គឺជានីតិវិធីមួយដែលអនុញ្ញាតឲ្យភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ អាចធ្វើការស្នើសុំឲ្យចៅក្រមដកខ្លួនចេញពីសំណុំរឿងដែលខ្លួនកំពុងកាន់ក្នុងករណីដែលរកឃើញថាចៅក្រមនោះមានជាប់ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយភាគី។ ទំនាក់ទំនងនេះអាចនឹងនាំឲ្យប៉ះពាល់លើទំនុកចិត្ត

[27] មាត្រា ១៣៦ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣

របស់ភាគីចំពោះចៅក្រមអំពីការសម្រេចសេចក្តី ដែលនឹងជះឥទ្ធិពលដល់ការស្វែងរកយុត្តិធម៌ជូនភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ។ ក្នុងនោះផងដែរបណ្តឹងជិតចិត្តចៅក្រមអាចធ្វើទៅបានក្នុងមូលហេតុដូចខាងក្រោម៖

១. កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី

២. កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី **៦** ឬញាតិពន្ធរហូតដល់ថ្នាក់ទី **៣** ឬអតីត ញាតិពន្ធរហូតដល់ថ្នាក់ទី **៣** របស់ភាគីណាមួយ។

៣. កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ។

៤. កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ។

៥. កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្តី។

៦. កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្តីឬ។

៧. កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្តី ឬបានចូលរួមក្នុងការសម្រេចសេចក្តីនៅសាលាដំបូងដែលបានប្តឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី[28]។

កាលណាជនជាប់ចោទបានរកឃើញថា ចៅក្រមមានចំណុចទាំងអស់ខាងលើនេះ គឺជាមូលហេតុដែលនាំឲ្យចៅក្រមអាចត្រូវបានប្តឹងជិតចិត្ត ហើយករណីទាំងអស់ខាងលើគឺផ្តោតជាសំខាន់ទៅលើទំនាក់ទំនងរវាងចៅក្រម និងភាគីដែលបញ្ជាក់ថាចៅក្រមគឺជាភាគី ឬជាសាច់ញាតិរបស់ភាគី ឬក៏ធ្លាប់មានប្រវត្តិជាប់ពាក់ព័ន្ធនឹងសំណុំរឿងកន្លងមកជាដើម។ ការកំណត់ជាមូលហេតុដូចបានកំណត់ក្នុងមាត្រា **៥៥៦** នៃក្រមនីតិវិធីព្រហ្មទណ្ឌខាងលើសបញ្ជាក់អំពីការធានាដល់ប្រសិទ្ធភាពនៃការជម្រះក្តី ឬដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ប៉ុន្តែមិនមែនមានន័យថាឲ្យតែមានមូលហេតុហើយនោះ នឹងបង្កើតជាសិទ្ធិដែលនាំឲ្យធ្វើបណ្តឹងជិតចិត្តនោះបានឡើយ ពោលគឺត្រូវពិនិត្យលើលក្ខខណ្ឌផងដែរ ដែលលក្ខខណ្ឌក្នុងនោះរួមមាន៖

១. ត្រូវធ្វើបណ្តឹងជិតចិត្តតាំងពីពេលដែលបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត៖ មានន័យថានៅពេលដែលភាគីនៃរឿងក្តីបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត នោះត្រូវតែប្តឹងជិតចិត្ត ដោយហេតុថា ដំណើរការរឿងក្តីព្រហ្មទណ្ឌគឺបន្តរហូត ដូចនេះបើទុកពេលយូរ ឬអូសបន្លាយពេលវេលានោះអាចនឹងបណ្តាលឲ្យនីតិវិធីនៃរឿងក្តីត្រូវបញ្ចប់ហើយការធ្វើប្តឹងជិតចិត្ត និងលែងមានប្រយោជន៍សម្រាប់ភាគី។ ករណីនេះមាត្រា **៥៥៧** កថាខណ្ឌទី១ ចែងថា "ភាគីដែល ចង់ប្តឹងជិតចិត្តចៅក្រមអសនៈណាមួយត្រូវតែជូនពាក្យប្តឹងតាំងពីខ្លួនបានដឹងពីមូលហេតុនៃការប្តឹងជិតចិត្ត បើពុំដូច្នេះនោះទេ មិនអាចទទួលបានឡើយ[29]។

[28] មាត្រា ៥៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29] មាត្រា ៥៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

២. ត្រូវធ្វើនៅមុនពេលបិទការពិភាក្សាដេញដោលៈ ចំណុចនេះមានភាពប្រហាក់ប្រហែលនឹងករណីខាងលើដែរ មាននន័យថាប្រសិនបើនីតិវិធីបានដើរដំណាក់កាលបិទការពិភាក្សាដេញដោលហើយនោះមានន័យថា ដំណើររឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងស្ទើតែចប់ទៅហើយ ពោលគឺរងចាំតែការប្រកាសសាលក្រមតែប៉ុណ្ណោះ ព្រោះវាក៏គ្មានផលប្រយោជន៍សម្រាប់ភាគី ក្នុងធ្វើបណ្តឹងដិតចិត្តដែរ ហើយបើមូលហេតុចៅក្រមជាភាគីនៃរឿងក្តីក៏ប្រធានតុលាការមិន អនុញ្ញាឲ្យចៅក្រមនោះកាន់សំណុំរឿងរបស់ខ្លួននោះដែរ។ ដូចនេះហើយទើបមាត្រា **៥៥៧** កថាខណ្ឌទី២ចែងថា **ក្នុងករណីណាក៏ដោយ ពាក្យប្តឹងដិតចិត្តចៅក្រមមិនអាចធ្វើបានឡើយ នៅក្រោយពេលបិតការពិភាក្សាដេញដោល**”។

៣. ពាក្យប្តឹងដិតចិត្តត្រូវមានបញ្ជាក់មូលហេតុ និងភស្តុតាងច្បាស់លាស់ៈ ជាលក្ខខណ្ឌចាំបាច់ណាស់សម្រាប់ភាគីដែលបានធ្វើពាក្យប្តឹងដិតចិត្ត មានន័យថាមិនមែនមានត្រឹមតែមូលហេតុ ដោយគ្រាន់តែលើកឡើងដោយគ្មានភស្តុតាងបញ្ជាក់នោះអាចទទួលពាក្យប្តឹងដិតចិត្តបានឡើយ ដូចនេះក្រៅពីរៀបចំពាក្យប្តឹងតាមទម្រង់ត្រឹមត្រូវ ដោយមានមូលហេតុតាមច្បាប់កំណត់ហើយ គឺត្រូវបញ្ជាក់បន្ថែមដោយភស្តុតាងថែមទៀត ព្រោះវាពាក់ព័ន្ធនឹងវិជ្ជាជីវៈ និងការអនុវត្តការងារ របស់ចៅក្រម[30]។

## ៩.សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុ

គ្រប់ជនជាប់ចោទទាំងអស់មានសិទ្ធិទទួលបានការសម្រេចសេចក្តីជាសាធារណៈ និងមានសំអាងហេតុគ្រប់គ្រាន់នៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងរឿងក្តីរដ្ឋប្បវេណី បើទោះបីជារឿងនោះត្រូវបានធ្វើសវនាការជាអសាធារណៈក៏ដោយ ហើយសាធារណៈជនមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសវនាការក៏ដោយប៉ុន្តែតុលាការមានកាតព្វកិច្ចចេញសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុគ្រប់គ្រាន់។ សេចក្តីសម្រេចត្រូវចាត់ទុក ជាសាធារណៈ នៅពេលដែលសេចក្តីសម្រេចនោះត្រូវបានប្រកាសដោយផ្ទាល់មាត់តុលាការក្នុងពេលសវនាការ ឬផ្តល់ទៅឲ្យគូភាគីដែលពាក់ពន្ធចំពោះការសម្រេចសេចក្តីដោយមានសំអាងហេតុ គឺតម្រូវឲ្យតុលាការពិនិត្យទៅលើការចោទប្រកាន់ និងអំណះអំណាងនីមួយៗដែលបានដាញដោលនៅក្នុងពេលសវនាការដែលភាគីនីមួយៗបានលើកឡើងក្នុងនោះផងដែរ សេចក្តីសម្រេចរបស់តុលាការត្រូវពន្យល់ទាំងមូលនៅ អង្គហេតុ និងអង្គច្បាប់ដែលជាមូលដ្ឋាននៃការសម្រេចសេចក្តី។ សិទ្ធិទទួលបានការសម្រេចសេចក្តីជាសាធារណៈ និងមានសំអាងហេតុ មានចែងយ៉ាងជាក់ច្បាស់នៅក្នុងមាត្រា **១៤** កតិកាសញ្ញាសអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ “**ការចេញសាលក្រមទាំងអស់អំពីរឿងក្តីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ**”[31] មិនត្រឹមតែប៉ុណ្ណោះមាត្រា **៧** នៃច្បាប់ស្តីពីការរៀបចំអង្គការ

[30] មាត្រា ៥៥៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[31] មាត្រា ១៤ កតិសញ្ញាសអន្តជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

តុលាការបានចែងថា “**គ្រប់សាលក្រមទាំងអស់សាលក្រមត្រូវប្រកាសជាសាធារណៈ**”[32]។ ការគោរពសិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងមានសំអាងហេតុរបស់ជនជាប់ចោទវាពិតជាមានសារៈសំខាន់ណាស់ក្នុងការធានាថាប្រព័ន្ធយុត្តិធម៌បើចំហរមានតម្លាភាព និងមានការទទួលខុសត្រូវដែលធ្វើឲ្យប្រជាពលរដ្ឋជឿជាក់។

## ផ្នែកទី៣.សិទ្ធិជនជាប់ចោទក្រោយសវនាការ

ជាទូទៅនៅក្នុងដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ នីតិវិធីនៃការជំនុំជម្រះគឺជានីតិវិធីចុងក្រោយគេដែលអាចនិយាយបានថាចប់សព្វគ្រប់នៃដំណើរការនីតិវិធី និងការបង្ហាញអំពីពិរុទ្ធភាពរបស់បុគ្គលម្នាក់ៗដែលជាជនប្រព្រឹត្តបទល្មើស។ ក៏ប៉ុន្តែបើបញ្ចប់នីតិវិធីឲ្យបុគ្គលនោះទទួលនូវទណ្ឌកម្មដោយបិទផ្លូវតវ៉ាត្រឹមនោះវាហាក់ដូចជាមានភាពចង្អៀតចំពោះបុគ្គលដែលជារងទណ្ឌកម្មនោះ ដូចនេះហើយទើបក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិជាច្រើនចំពោះបុគ្គលដែលជាជនត្រូវបានផ្តន្ទានទោស ក្រោយពីការជំនុំជម្រះនោះ ហើយការផ្តល់សិទ្ធិនោះទៀតសោតក៏ត្រូវបានអនុវត្តយ៉ាងពេញលេញ និងខ្ជាប់ខ្ជួនផងដែរក្រោមការយកចិត្តទុក្ខដាក់ពីថ្នាក់ដឹកនាំ នីតិវិធីចំពោះជនទាំងនោះបានយ៉ាងគ្រប់ជ្រុងជ្រោយ។ មិនតែប៉ុណ្ណោះនៅក្នុងកំឡុងពេលក្រោយសាវនាការនៅក្នុងការប្រើប្រាស់ពាក្យកំណត់ចំពោះបុគ្គលទាំងនោះ ក៏ត្រូវបានកំណត់យ៉ាងត្រឹមត្រូវដោយក្រោយពីបញ្ចប់នីតិវិធីជំនុំជម្រះ កាលណាបានប្រកាសសាលក្រមថាបុគ្គលនោះមានពិរុទ្ធ ហើយសាលក្រមនោះពុំទាន់បានចូលជាស្ថាពរនោះទេ បុគ្គលនោះត្រូវមានឋានៈជាពិរុទ្ធជនប៉ុណ្ណោះ លើកលែងតែសាលក្រមនោះបានចូលជាស្ថាពរ ក្នុងរយៈពេលដែលច្បាប់បានកំណត់ចំណុចនេះនឹងបញ្ជាក់បន្តនៅចំណុចខាងក្រោម។ ដូចគ្នាផងដែលចំពោះជនដែលទទួលស្គាល់សាលក្រម ហើយសាលក្រមនោះត្រូវបានចូលជាស្ថាពរ និងកំពុងតែអនុវត្តទោសនៅក្នុងពន្ធានាគារដែលមានឈ្មោះថាជាទណ្ឌិតនោះក៏ត្រូវបានផ្តល់ សិទ្ធិជាច្រើនដែលជាគោលការណ៍មួយហៅថា គោលការណ៍មនុស្សធម៌ដែលការអនុវត្តបែបនេះ គឺមានគោលបំណងធំក្នុងការអប់រំកែប្រែបុគ្គលទាំងនោះឲ្យធ្វើសមាហរណកម្មជាមួយសង្គមវិញក្នុងនាមជាពលរដ្ឋល្អ។

### ១.សិទ្ធិពិរុទ្ធជន

ជាទូទៅពិរុទ្ធជន ជាពាក្យមួយដែលត្រូវបានគេយកទៅប្រើដើម្បីសម្គាល់ដល់ជនជាប់ចោទទាំងឡាយដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោស។ វាក្យស័ព្ទ ពិរុទ្ធជន ក៏ត្រូវបានយកទៅប្រើផងដែរ ចាប់ពីពេលដែលជនជាប់ចោទត្រូវបានតុលាការសម្រេចធ្វើការផ្តន្ទាទោសរហូតដល់ពេលដែលជននោះបានធ្វើការប្តឹងតវ៉ា នឹងសាលក្រម ឬសាលដីកាដែលផ្តន្ទាទោសនោះ ឬរហូតដល់ពេលដែលសាលក្រម ឬសាលដីកានោះបានចូលជា

[32] មាត្រា ៧ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

ស្ថាពរ។ ជាទូទៅនៅក្រោយពេលដែលបញ្ចប់នូវនីតិវិធីប្រកាសសាលក្រមអំពីពិរុទ្ធភាពរបស់ជនដែលជាប់ចោទ រួចដរាបណាសាលក្រមនោះពុំចូលជាស្ថាពរនូវឡើយ នោះច្បាប់បានផ្តល់សិទ្ធិទៅកាន់បុគ្គលនោះឲ្យធ្វើការអនុវត្តនូវសិទ្ធិរបស់ខ្លួនធំៗ ៣ គឺ៖ ការធ្វើបណ្តឹងទាស់ ការធ្វើបណ្តឹងឧទ្ធរណ៍ និងការធ្វើនៅបណ្តឹងសារទុក្ខ ដែលជាសិទ្ធិដ៏សំខាន់ក្នុងការផ្តល់ឱកាសទៅឲ្យបុគ្គលដែលជាពិរុទ្ធជនបានធ្វើការសម្តែងក៏ដូចជាបានបញ្ជាក់ពីភាពពិតនៃការកើតឡើងនៃបទល្មើសព្រមទាំងស្វែងរកនូវភាពយុត្តិធម៌ចំពោះខ្លួនផងដែរ ដូចនេះនៅក្នុងនីតិវិធីបានកំណត់ជាច្រើនអំពីចំណុចទាំងនេះ ជាកូនសោយ៉ាងសំខាន់ក្នុងការការពារសិទ្ធិក៏ដូចជាភាពពិតរបស់ពិរុទ្ធជនទៅកាន់សង្គម។

### ១.១.សិទ្ធិធ្វើបណ្តឹងទាស់

ក្រោយពីសាលក្រមត្រូវបានប្រកាសជនជាប់ចោទ ដែលមិនសុខនឹងសេចក្តីសម្រេចរបស់តុលាការអាចប្តឹងទាស់បានកាលណាសាលក្រមនោះត្រូវបានសម្រេចដោយកំបាំងមុខពិរុទ្ធជន ច្បាប់បានផ្តល់សិទ្ធិឲ្យពិរុទ្ធជនធ្វើការប្តឹងទាស់ទៅនឹងសាលក្រមកំបាំងមុខនោះ[33]។ សាលក្រមកំបាំងមុខជាសាលក្រមមួយដែលត្រូវបានប្រកាសក្នុងពេលគ្មានវត្តមានរបស់ជនជាប់ចោទ ឬជនជាប់ចោទមិនបានចូលបង្ហាញខ្លួននៅពេលសវនាការ ហើយគ្មានភស្តុតាងតាងបង្ហាញឲ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ។ តាមន័យនេះប្រសិនបើជនជាប់ចោទអវត្តមាននាពេលសវនាការធ្វើការពិភាក្សាដេញដោល ហើយតុលាការពុំមានភស្តុតាងណាបញ្ជាក់ថា ជនជាប់ចោទបានទទួលដំណឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅទេ សាលក្រមដែលប្រកាសដោយតុលាការនោះជាសាលក្រមកំបាំងមុខ ទោះបីជានៅពេលសវនាការប្រកាសសាលក្រមជនជាប់ចោទមានវត្តមានក៏ដោយ។ ដោយឡែកប្រសិនបើជនជាប់ចោទ មិនមានវត្តមាននាពេលសវនាការដែលធ្វើការពិភាក្សាដេញដោលទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះសាលក្រមដែលប្រកាសនោះជាសាលក្រមចំពោះមុខ[34]។ ទោះបីជាសាលក្រមត្រូវបានប្រកាសកំបាំងមុខជនជាប់ចោទក៏ដោយ តែជនជាប់ចោទប្រាកដជាបានដឹងពីថ្ងៃដែលត្រូវប្រកាសសាលក្រម ព្រោះថានៅពេលសវនាការដែលធ្វើការពិភាក្សាដេញដោលប្រធានសវនាការបានជូនដំណឹងដល់ភាគីដែលមានវត្តមានពីថ្ងៃដែលត្រូវប្រកាសសាលក្រមរួចហើយ[35]។ បណ្តឹងទាស់ដែលធ្វើឡើងដោយពិរុទ្ធជនត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ឬចំពោះមុខព្រះរាជអាជ្ញា អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ឬប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលបានទទួល

[33] មាត្រា ៣៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[34] មាត្រា ៣៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[35] មាត្រា ៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ពាក្យប្ដឹងទាស់របស់ពិរុទ្ធជន កាលបានទទួលនៅបណ្ដឹងទាស់ព្រះរាជអាជ្ញាអង្គភាពនគរបាល ឬកងរាជអាវុធហត្ថត្រូវបញ្ជូនបណ្ដឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម[36]។ ម្យ៉ាងទៀតពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវីក្នុងការដាក់ពាក្យប្ដឹងទាស់ ប៉ុន្តែត្រូវមានលិខិតអនុញ្ញាតផងទើបបានពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិ បណ្ដឹងទាស់ត្រូវធ្វើក្នុងរយៈពេល **១៥** ថ្ងៃ ដោយគិតចាប់ពីថ្ងៃជូនដំណឹងអំពីសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ឲ្យពិរុទ្ធជនដោយផ្ទាល់ដៃ ឬគិតពីថ្ងៃពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនោះមិនបានប្រគល់ឲ្យពិរុទ្ធជននោះដោយផ្ទាល់ដៃ[37]។ បើជនជាប់ចោទប្ដឹងទាស់ហើយ តុលាការទទួលបណ្ដឹងនោះសំណុំរឿងរបស់ជនជាប់ចោទ និងត្រូវបានយកទៅជំនុំជម្រះនៅចំពោះមុខតុលាការដដែល ដោយចាត់ការដូចជាការជំនុំជម្រះលើកទីមួយដែរ ភាគីទាំងអស់ត្រូវបានកោះហៅតាមគំនិតផ្ដើមរបស់ព្រះរាជអាជ្ញា ក្នុងករណីដែលអ្នកប្ដឹងទាស់ត្រូវបានកោះហៅដោយត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ តុលាការប្រកាសថាបណ្ដឹងទាស់ទុកជាឯកសារឥតបានការ សាលក្រមដែលត្រូវបានគេប្ដឹងទាស់មិនអាចកែប្រែបានទេ សាលក្រមនោះត្រូវមានអនុភាពទាងស្រុងចំពោះភាគីទាំងអស់ ហើយអ្នកប្ដឹងទាស់អាចប្ដឹងឧទ្ធរណ៍បាននៅក្នុងលក្ខខណ្ឌដែលបានកំណត់[38]។

### ១.២.សិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍

សិទ្ធិធ្វើបណ្ដឹងឧទ្ធរណ៍ គឺជាបណ្ដឹងរបស់គូភាគីណាមួយដែលប្ដឹងសុំឲ្យកែប្រែសេចក្ដីសម្រេច ឬសាលក្រមរបស់តុលាការខេត្ត-ក្រុង ឬតុលាការយោធា។ សាលាឧទ្ធរណ៍សម្រេចសេចក្ដីដោយត្រួតពិនិត្យទៅលើអង្គហេតុ និងអង្គច្បាប់ដែលសាលាជម្រះក្ដីថ្នាក់ក្រោមបានស្រាវជ្រាវរកឃើញ និងបានអនុវត្តបណ្ដឹងឧទ្ធរណ៍អាចធ្វើទៅបានដោយព្រះរាជអាជ្ញានៃតុលាការជាន់ដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្ដឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី[39]។ បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី តែត្រូវមានលិខិតប្រគល់សិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍។ ប៉ុន្តែក្នុងករណីដែលពិរុទ្ធជនជាអនីតិជន ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល អាចតំណាងក្នុងការដាក់ពាក្យប្ដឹងឧទ្ធរណ៍បានដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិទេ[40]។ យោងមាត្រា **៣៨២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថាការប្ដឹង

[36] មាត្រា ៣៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[37] មាត្រា ៣៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38] មាត្រា ៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[39] មាត្រា ៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[40] មាត្រា ៣៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឧទ្ធរណ៍ទៅនឹងសាលក្រមកំបាំងមុខ មិនអាចធ្វើទៅបានទេដោយហេតុថាមាត្រានេះអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍តែអំពីសាលក្រមចំពោះមុខ និងសាលក្រមចាត់ទុកជាចំពោះមុខប៉ុណ្ណោះ[41]បន្ថែមពីលើនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌក៏អនុញ្ញាតឲ្យសាមីខ្លួនប្តឹងទាស់ទៅនឹងសាលដីកាចេញដោយកំបាំងមុខខ្លួនទៀតផង[42]។ បណ្តឹងឧទ្ធរណ៍អាចធ្វើឡើងក្នុងរយៈពេល ១ ខែ ចាប់ពីថ្ងៃដែលប្រកាសសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត និងប្តឹងឡើងដោយព្រះរាជអាជ្ញានៃសាលាដំបូង ហើយបណ្តឹងដែលធ្វើឡើងដោយអគ្គព្រះរាជអាជ្ញាអាចធ្វើឡើងក្នុងរយៈពេល ៣ ខែ ដោយផ្តើមគិតពីពេលដែលប្រកាសសាលក្រម[43]។ សាលាឧទ្ធរណ៍អាចប្រើប្រាស់នីតិវិធីសវនាការដូចគ្នាទៅនឹងនីតិវិធីដែលប្រើនៅក្នុងតុលាការខេត្ត-ក្រុងដែរ តែចំណុចដែលខុសគ្នានោះគឺរឿងក្តីត្រូវជំនុំជម្រះដោយចៅក្រម ៣ រូប ហៅថាក្រុមប្រឹក្សាជំនុំជម្រះ និងធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីជួយរកដំណោះស្រាយអំពីការខ្វះចន្លោះលើអង្គហេតុដែលរកឃើញដោយតុលាការជាន់ទាប។ សាលាឧទ្ធរណ៍មិនអាចបើកសវនាការលើបញ្ហា និងបទចោទដែលមិនបានប្តឹងឧទ្ធរណ៍បានទេ សាលាឧទ្ធរណ៍ក៏មានមានអំណាចក្នុងការបើកសវនាការលើបណ្តឹងឧទ្ធរណ៍ ដែលអយ្យការតុលាការខេត្ត-ក្រុង ឬតុលាការយោធាជាអ្នកប្តឹងឧទ្ធរណ៍ និងសេចក្តីសម្រេចទាំងឡាយរបស់ចៅក្រមនៅតុលាការទាំងនោះទាក់ទងទៅនឹងការឃុំខ្លួន ឬការឲ្យនៅក្រៅឃុំបណ្តោះអាសន្នលើកលែងការចោទប្រកាន់ដោយគ្មានមូលហេតុត្រឹមត្រូវសម្រាប់ធ្វើការចោទប្រកាន់នោះទេ។

### ១.៣.សិទ្ធិធ្វើបណ្តឹងសារទុក្ខ

បណ្តឹងសារទុក្ខ គឺជាពាក្យបណ្តឹងមួយដែលធ្វើឡើងដោយភាគីណាមួយ ដែលមិនសុខចិត្តទៅនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ នោះភាគីអាចធ្វើការប្តឹងសារទុក្ខទៅកាន់តុលាកាកំពូលបានដែលមានតែមួយគត់នៅក្នុងប្រទេសកម្ពុជា។ តុលាការកំពូលសម្រេចសេចក្តីតែលើអង្គច្បាប់ប៉ុណ្ណោះ មិនសម្រេចសេចក្តីលើអង្គហេតុទេមានន័យថា តុលាការកំពូលមិនពិនិត្យ ឬស៊ើរើអង្គហេតុដែលកំណត់ដោយសាលាឧទ្ធរណ៍រួចហើយទេ ប៉ុន្តែតុលាការកំពូលពិនិត្យមើលថា តើសាលាឧទ្ធរណ៍បានអនុវត្តច្បាប់ត្រឹមត្រូវដែរ ឬទេទៅតាមអង្គហេតុដែលបានរកឃើញនោះ។ បណ្តឹងសារទុក្ខអាចធ្វើឡើងប្រឆាំងនឹងសាដីកាសភាស៊ើបសួររឿងបត្យាប័ន ព្រមទាំងសាលដីកាដែលសម្រេចជាសមត្ថកិច្ចចុងក្រោយដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ តែនីតិវិធីនេះមិនអាចធ្វើបានទេចំពោះសាលដីកាចេញដោយសភាស៊ើបសួរ ដែលបង្គាប់ឲ្យបញ្ជូនជនជាប់ចោទទៅតុលាការជំនុំជម្រះនោះ[44] បណ្តឹងសារទុក្ខត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសាលដីកា

[41] មាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[42] មាត្រា ៤០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[43] មាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
[44] មាត្រា ៤១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍រៀបចំសំណុំរឿង ហើយបញ្ជូនសំណុំរឿងនេះទៅក្រឡាបញ្ជីតុលាការកំពូលក្នុងរយៈពេលដ៏ខ្លីបំផុត[45]។ បណ្ដឹងសារទុក្ខអាចធ្វើបានដោយ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជនជាប់ចោទ ឬពិរុទ្ធជនខ្លួនឯងផ្ទាល់ បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិបត្យប័នដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី បណ្ដឹង សាទុក្ខត្រូវធ្វើឡើងក្នុងរយៈពេល ១ ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ **១៥** ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍និង **៥** ថ្ងៃ ចំពោះមតិរបស់សភាស៊ើបសួរដែលបញ្ចេញក្នុងរឿងបត្យាប័ន[46]។ បណ្ដឹងសាទុក្ខអាចធ្វើទៅបានក្នុងករណីដែលមានមូលហេតុដូចខាងក្រោម៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ
- អសមត្ថកិច្ចនៃតុលាការ
- ការរំលោភអំណាច
- ការបំពានច្បាប់ ឬការអនុវត្តខុសច្បាប់
- ការបំពាន ឬភ្លេចទម្រង់ការដែលច្បាប់កំណត់ត្រូវទុកជាមោឃៈ
- ការមិនបានសម្រេចលើពាក្យប្ដឹងសុំរបស់អយ្យការ ឬភាគី កាលណាពាក្យប្ដឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់
- ការបំភ្លៃអង្គហេតុ
- គ្មានសំអាងហេតុ
- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្ដីសម្រេច [47]។

## ២. សិទ្ធិរបស់ទណ្ឌិត

ទណ្ឌិត ជាពាក្យមួយប្រើសម្រាប់ជនដែលតុលាការសម្រេចថាជាជនល្មើស ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានចោទប្រកាន់បានសម្រេច ដោយសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ជារួមគេហៅជននោះថា **អ្នកទោស** ឧទាហរណ៍៖ តុលាការឃុំឃាំងទណ្ឌិតដើម្បីអប់រំកែប្រែទណ្ឌិតឲ្យក្លាយជាមនុស្សល្អវិញ (ផ្ដោតទៅលើកម្មវិធីស្ដារនីតិសម្បទា)។ ការចូលជាស្ថាពរមាន **២** ប្រភេទ៖ ចូលជាស្ថាពរដោយពិរុទ្ធជនមិនធ្វើការប្ដឹងឧទ្ធរណ៍ ឬប្ដឹងសាទុក្ខលើសាសក្រមឬសាលាដីការបស់តុលាការ ដែលបានសម្រេចផ្តន្ទាទោសខ្លួនមានន័យថាជននោះសុខចិត្តទទួលយកសេចក្ដីសម្រេចផ្តន្ទាទោសរបស់តុលាការ និងការចូលជាស្ថាពរដោយ

[45] មាត្រា ៤២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[46] មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[47] មាត្រា ៤១៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការដំណើរការនីតិវិធីគ្រប់សាសាជម្រះក្តីទាំងបីថ្នាក់ គឺសាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ដែលជាសមត្ថកិច្ចជម្រះក្តីចុងក្រោយ។ នេះមានន័យថាទណ្ឌិត គឺជាជនដែលត្រូវបានអនុវត្តទោសនៅក្នុងពន្ធនាគារដែលរយៈពេល គឺអាស្រ័យទៅតាមអំណាចនៃការប្រកាសទោសដែលមាននៅក្នុងសាលក្រម។ ទោះបីជាទណ្ឌិតត្រូវបានបាត់បង់នូវសេរីភាពក្នុងកំឡុងពេលអនុវត្តទោសនោះក្តីក៏ការទទួលស្គាល់នូវសិទ្ធិរបស់ជននោះនៅតែត្រូវបានយកមកធ្វើការប្រត្តិបត្តិ និងគោរពតាមយ៉ាងតឹងរឹងដែលសិទ្ធិទាំងនោះនឹងមានបកស្រាយដូចមាននៅខាងក្រោមនេះ។

## ២.១.សិទ្ធិធ្វើបណ្តឹងសើរើ

បណ្តឹងសើរើ គឺជាផ្លូវតវ៉ាមួយប្រឆាំងនឹងសាលក្រម និងសាលដីកាដែលស្ថាពរ ហើយដែលមានអាជ្ញាអស់ជំនុំ[48]។ ការប្តឹងសើរើ គឺជាផ្លូវតវ៉ាពិសេសមួយហេតុនេះបណ្តឹងសើរើអាចអនុញ្ញាតបានតែក្នុងករណីដែលបានចែងដោយច្បាប់ប៉ុណ្ណោះ ផ្អែកតាមមាត្រា ៤៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បុគ្គលដែលអាចប្តឹងសើរើរឿងក្តី រួមមាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ទណ្ឌិត ឬ អ្នកតំណាងស្របច្បាប់ ប្រសិនបើទណ្ឌិតនេះជាអសមត្ថជន សហព័ន្ធ ឪពុកម្តាយ កូន និងជាទូទៅជនដែលមានប្រយោជន៍ខាងសម្ភារៈ[49]។ ម្យ៉ាងទៀតពាក្យប្តឹងសើរើ ត្រូវចុះក្នុងបញ្ជីដោយក្រឡាបញ្ជីនៃតុលាការកំពូល[50] ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់ពីរយៈពេលនៃការប្តឹងសើរើឡើយ។ ខុសប្លែកពីបណ្តឹងឧបាស្រ័យផ្សេងៗ បណ្តឹងសើរើត្រូវធ្វើឡើងលុះត្រាតែមានលក្ខខណ្ឌដូចខាងក្រោមនេះ៖

- កាលណាក្រោយពីការផ្តន្ទាទោសពីបទមនុស្សឃាត មានលេចតម្រុយយ៉ាងគ្រប់គ្រាន់ដែលអនុញ្ញាតឲ្យ គិតថាជនរងគ្រោះនោះនៅរស់រានមានជីវិតនៅឡើយ
- កាលណាជនជាប់ចោទពីរនាក់ត្រូវបានផ្តន្ទាទោស ចំពោះបទល្មើសដដែលនេះ ដោយការផ្តន្ទាទោសទាំងពីរនេះមិនចុះសម្រុងគ្នាទេ
- កាលណាសាក្សីណាមួយត្រូវបានផ្តន្ទាទោសពីបទល្មើស ធ្វើជាសាក្សីដោយក្លែងប្រឆាំងនឹងជនជាប់ចោទ
- កាលណាមានអង្គហេតុថ្មី លិខិត ឬភស្តុតាងថ្មីដែលនាំឱ្យគេសង្ស័យលើពិរុទ្ធភាពនៃទណ្ឌិត[51]។

[48] មាត្រា ៤៤៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49] មាត្រា ៤៤៦ ក្រមនីតិវិធីព្រហ្មទណនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[50] មាត្រា ៤៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51] មាត្រា ៤៤៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ២.២.សិទ្ធិទទួលបានផ្នែកថែទាំសុខភាព

ជាការពិតណាស់ជនជាប់ឃុំនៅក្នុងពន្ធនាគារ នៅតែមានសិទ្ធិមូលដ្ឋានក្នុងទទួលបានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយក៏មានសិទ្ធិទទួលបានការថែរក្សាសុខភាពតាមបទដ្ឋានមួយមានលក្ខណៈប្រហាក់ប្រហែល នឹងការផ្តល់សេវាសុខភាពដល់ប្រជាជនទូទៅដែរ។ ការសាងសង់ពន្ធនាគារត្រូវតែស្ថិតតាមបទបញ្ញត្តិច្បាប់ បានកំណត់ដែលត្រូវតែធ្វើឡើងផ្តល់នូវការទទួលបានខ្យល់ពន្លឺ និងមានភាពជាសុខភាពព្រមទាំងភាពអនាម័យ ច្បាប់ក៏បានបញ្ញត្តិឲ្យមានការទទួលបាននូវការប្រើប្រាស់អគ្គិសនីជាមួយនឹងទឹកស្អាតផងដែរ មិនតែប៉ុណ្ណោះទីកន្លែងសម្រាប់គោរពសាសនា កន្លែងលេងកីឡា បណ្ណាល័យ និងទីកន្លែងសម្រាប់ព្យាបាលជំងឺក៏ត្រូវតែធ្វើការសាងសង់ផងដែរ។ ដោយយោងតាម កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (មាត្រា ១២) ចែងថា៖ ***សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន***[52]***។*** ក្រៅពីសិទ្ធិជាមូលដ្ឋានទាំងអស់របស់មនុស្សជនជាប់ឃុំត្រូវទទួលបានកិច្ចធានាការពារបន្ថែមទៀតតាមស្ថានភាពជាក់ស្តែង នៅពេលមានការដកហូតសេរីភាពពីប្រជាពលរដ្ឋ ហើយរដ្ឋត្រូវទទួលខុសត្រូវមើលថែរក្សាសុខភាពរបស់ពួកគេទាំងនោះ ព្រមជាមួយនឹងលក្ខខណ្ឌនៃការឃុំឃាំង និងការព្យាបាលជនជាប់ឃុំម្នាក់ៗដែលអាចជាភាពចាំបាច់ដែលកើតចេញលក្ខខណ្ឌទាំងនោះ សុខភាពល្អមានសារៈសំខាន់ណាស់សម្រាប់មនុស្សគ្រប់រូបសុខភាពនេះជះឥទ្ធិពលលើអាកប្បកិរិយា និងសមត្ថភាពក្នុងការបំពេញមុខងារជាសមាជិករបស់សហគមន៍ សុខភាពល្អ មានសារៈសំខាន់ជាពិសេសក្នុងពន្ធនាគារដែលជាសហគមន៍មួយបិទជិត ជាធម្មតាការដាក់ពន្ធនាគារអាចបង្កផលប៉ះពាល់អវិជ្ជមានដល់សុខមាលភាពរបស់ជនជាប់ឃុំ ទាំងផ្លូវកាយ និងផ្លូវចិត្ត រដ្ឋបាលពន្ធនាគារ មិនត្រឹមតែផ្តល់ការថែទាំសុខភាពប៉ុណ្ណោះទេ ថែមទាំងបង្កើតលក្ខខណ្ឌដែលលើកកម្ពស់សុខមាលភាពទាំងជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ។ ជនជាប់ឃុំមិនគួរចាកចេញពីពន្ធនាគារក្នុងស្ថានភាពសុខភាពយ៉ាប់យ៉ឺនជាងពេលដែលពួកគេបានចូលមកនោះទេ លក្ខខណ្ឌតម្រូវនេះអនុវត្តគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅក្នុងពន្ធនាគារ ជាពិសេសលើការថែទាំសុខភាព។ ជារឿយៗជនជាប់ឃុំពេលចូលមកដល់ពន្ធនាគារតែងតែមានបញ្ហាសុខភាពជាប់មកជាមួយ ដោយសារភាពខ្វះខាតការរំលោភបំពាន ឬជីវិតរស់នៅរបស់ជនជាប់ឃុំពីមុនមកជាញឹកញាប់ជនជាប់ឃុំភាគច្រើនមានប្រវត្តិគ្រួសារក្រីក្រនៅក្នុងសង្គម ហើយបញ្ហាសុខភាពរបស់ពួកគេក៏អាចបង្ហាញតាមរយៈស្ថានភាពសុខភាពនេះដែរ។ ជនជាប់ឃុំនឹងនាំមកជាមួយនូវលក្ខខណ្ឌសុខភាពដែលមិនបានព្យាបាល ការញៀនថ្នាំ និងបញ្ហាសុខភាពផ្លូវចិត្តដោយមិនទាន់បានទទួលបានការព្យាបាល។ ជនជាប់ឃុំទាំងនេះអាចនឹងត្រូវការការគាំទ្រជាក់លាក់ណាមួយ ដូចគ្នានឹងជនជាប់ឃុំដែលមាន

[52] មាត្រា ១២ កតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

បញ្ហាសុខភាពផ្លូវចិត្តដទៃទៀត ពីព្រោះពួកគេទទួលរងការប៉ះពាល់យ៉ាងខ្លាំងដោយសារការជាប់ឃុំឃាំង នៅប្រទេសជាច្រើនជនជាប់ឃុំភាគច្រើនទទួលរងគ្រោះដោយសារជំងឺឆ្លងដូចជា៖ ជំងឺរបេង រលាកថ្លើម និងជំងឺអេដស៍/មេរោគអេដស៍។ រដ្ឋបាលពន្ធនាគារត្រូវទទួលខុសត្រូវចំពោះអ្នកទាំងនោះដែលចូលមកក្នុងពន្ធនាគារ ជាពិសេសជនជាប់ឃុំព្រមទាំងអ្នកដែលចូលមកពន្ធនាគារ រួមទាំងមន្ត្រី និងអ្នកមកសួរសុខទុក្ខដើម្បីបង្ការការឆ្លងជំងឺ។ ការបរាជ័យក្នុងការគ្រប់គ្រងលើលក្ខខណ្ឌទាំងនេះអាចមានន័យថា អាចក្លាយជាបញ្ហាសុខភាពសហគមន៍ ដោយសារតែទំនាក់ទំនងរវាងពន្ធនាគារ និងសង្គមទាំងមូលតាមរយៈមន្ត្រី អ្នកសួរសុខទុក្ខ និងតាមរយៈការដោះលែងជនជាប់ឃុំក្នុងយុត្តាធិការមួយចំនួនការកើនឡើងនូវការសម្រេចផ្តន្ទាទោសក្នុងចិរវេលាយូរអង្វែង និងមិនមានកាលកំណត់បង្ករឲ្យមានការកើនឡើងបញ្ហាសុខភាពទាក់ទងនឹងអាយុរបស់ជនជាប់ឃុំ។

**២.៣. សិទ្ធិទទួលបានសិក្សាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ការដកហូតសេរីភាពរបស់មនុស្ស គឺជាការដាក់ទណ្ឌកម្មដ៏ធ្ងន់ធ្ងរមួយ អត្ថន័យពិតប្រាកដនៃការដាក់ពន្ធនាគារ គឺជាការដកហូតជាចាំបាច់នូវសិទ្ធិនានា ដូចនេះការដកហូតសេរីភាពត្រូវធ្វើឡើងដោយអាជ្ញាធរតុលាការប៉ុណ្ណោះ ក្នុងកាលៈទេសៈដែលបានកំណត់យ៉ាងច្បាស់លាស់ និងនៅពេលគ្មានជម្រើសសមហេតុផលណាផ្សេងក្រៅពីនេះ បានបង្ហាញយ៉ាងច្បាស់ថាអាជ្ញាធរពន្ធនាគារមិនគួរព្យាយាមដាក់ទណ្ឌកម្មជនជាប់ឃុំបន្ថែមលើទណ្ឌកម្មដែលបានកំណត់ដោយតុលាការនោះទេ ដូចជាការប្រព្រឹត្តលើជនជាប់ឃុំដោយអមនុស្សធម៌ ឬការដាក់ទណ្ឌកម្មធ្ងន់ធ្ងរមិនសមហេតុផលជាដើម។ ផ្ទុយទៅវិញអាជ្ញាធរពន្ធនាគារគួរព្យាយាមឲ្យអស់លទ្ធភាពក្នុងការបង្កាភាពទ្រុឌទ្រោមខាងរាងកាយ និងស្មារតីរបស់ជនជាប់ឃុំដែលស្ថិតក្រោមការថែទាំរបស់ខ្លួនដូចគ្នាផងដែរច្បាប់ស្តីពីពន្ធនាគារដែលបានបញ្ញត្តិក្នុងមាត្រា ២ មានគោលបំណងធំគឺការអប់រំកែប្រែ ស្តារនីតិសម្បទាដើមម្បីឲ្យជនដែលនៅក្នុងឃុំអាចធ្វើសមាហរណកម្មទៅក្នុងសង្គមមនុស្សវិញ ហើយក្លាយជាបុគ្គលដែលមានចំណេះវិជ្ជា ដែលបានរៀននៅក្នុងកំឡុងពេលខ្លួនកំពុងជាប់ពន្ធនាគារ[53]។ ការប្រព្រឹត្តលើជនជាប់ឃុំដោយអំពើមនុស្សធម៌ និងសមរម្យពីសំណាក់អាជ្ញាធរពន្ធនាគារតែម្យ៉ាងគឺមិនគ្រប់គ្រាន់ឡើយ អាជ្ញាធរពន្ធនាគារត្រូវផ្តល់ឱកាសឲ្យជនជាប់ឃុំដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួនធ្វើការផ្លាស់ប្តូរ និងអភិវឌ្ឍខ្លួនបន្ថែមទៀតដើម្បីអាចធ្វើបែបនេះបានអាជ្ញាធរពន្ធនាគារត្រូវមានជំនាញ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងនាមជា មន្ត្រីពន្ធនាគារដែលស្របទៅនឹងបញ្ញត្តិនៃច្បាប់ស្តីពីពន្ធនាគារ។ ជាការពិតណាស់ពន្ធនាគារភាគច្រើនពោរពេញដោយមនុស្សមកពីក្រុមទន់ខ្សោយក្នុងសង្គម ជនជាប់ឃុំជាច្រើននាក់មកពីគ្រួសារមានជីវភាពក្រីក្រខ្លាំង និងគ្រួសារដែលបែកបាក់គ្នា ជនជាប់ឃុំ

[53] មាត្រា ២ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០២៦

ភាគច្រើនគ្មានការងារធ្វើ និងមានកម្រិតសិក្សាអប់រំការផ្លាស់ប្ដូរឆាកជីវិតរបស់មនុស្សដែលជួបភាពលំបាកបែប នេះមិនមែនជាការងាយស្រួលឡើយ ពន្ធនាគារគួរតែជាកន្លែងដែលសម្បូរទៅដោយកម្មវិធីទាក់ទងនឹង សកម្មភាពបែបស្ថាបនា និងជួយដល់ជនជាប់ឃុំក្នុងការធ្វើឲ្យស្ថានភាពរបស់ខ្លួនមានភាពប្រសើរឡើង។ ទោះបីជាពន្ធនាគារមានបទពិសោធន៍តិចតួចបំផុតក៏ដោយ ក៏ពន្ធនាគារមិនគួរបណ្ដោយឲ្យជនជាប់ឃុំរស់នៅ ក្នុងស្ថានភាពអាក្រក់ជាងពេលដែលពួកគេបានចាប់ផ្ដើមបំពីទោស ដែលផ្ទុយទៅវិញត្រូវជួយជនជាប់ឃុំក្នុងការ ថែរក្សា លើកកម្ពស់សុខភាពដំណើរការបញ្ញាស្មារតី និងសកម្មភាពសង្គមរបស់ពួកគេ។

## ២.៤. សិទ្ធិទទួលបានការសួរសុខទុកពីក្រុមគ្រួសារ និងមិត្តភក្តិ

អ្នកដែលត្រូវបញ្ជូនចូលក្នុងពន្ធនាគារ បាត់បង់សិទ្ធិដើរទៅណាមកណាដោយសេរី ប៉ុន្តែនៅមានសិទ្ធិឯទៀតក្នុងនាមជាមនុស្ស។ សិទ្ធិមួយក្នុងចំណោមសិទ្ធិដ៏សំខាន់ៗទាំងអស់នោះ គឺសិទ្ធិទាក់ទងជាមួយក្រុមគ្រួសាររបស់ខ្លួន ហើយសមាជិកគ្រួសាររបស់ជនជាប់ឃុំក៏មានសិទ្ធិជួបជាមួយជនជាប់ឃុំដែលជាប់ពន្ធនាគារដែរ សមាជិកគ្រួសារនៅមានសិទ្ធិទាក់ទងជាមួយឪពុកម្ដាយ កូនប្រុស កូនស្រី បងប្អូនប្រុស ឬបងប្អូនស្រីរបស់ខ្លួន ដែលជាប់ពន្ធនាគារ។ រដ្ឋបាលពន្ធនាគារមានភារកិច្ចធានារក្សា បន្តទំនាក់ទំនងទាំងនេះការខកខាន ឬការរារាំង មិនឲ្យមានការសួរសុខទុក្ខពីសំណាក់ក្រុមគ្រួសារ មិនគួរប្រើប្រាស់ជាមធ្យោបាយដាក់ទណ្ឌកម្មនោះទេទោះបី ស្ថិតក្នុងកាលៈទេសៈណាក៏ដោយ។ លិខិតុបករណ៍សំខាន់ៗស្ដីពីសិទ្ធិមនុស្សអន្តរជាតិចែងយ៉ាងច្បាស់ពីសិទ្ធិ ជាសកលទាក់ទងនឹងបញ្ហាទាំងនេះ មាត្រា ១២ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សចែងថា៖ ***គ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមអំពើចិត្តក្នុងជីវិតឯកជនគ្រួសារ ទីលំនៅ ការឆ្លើយឆ្លងរបស់ខ្លួនបានឡើយ***[54]។មាត្រា ២៣ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា៖ ***គ្រួសារជាអង្គភាពធម្មជាតិ និងជាអង្គភាពមូលដ្ឋានរបស់សង្គម ហើយគ្រួសារមានសិទ្ធិទទួលការការពារពីសង្គម និងរដ្ឋ***[55]។ ជនជាប់ឃុំទាំងអស់ក៏ទទួលបានសិទ្ធិទាំងនេះដែរ ក្នុងឆ្នាំ១៩៧៩ តុលាការអឺរ៉ុប ទទួលបន្ទុកសិទ្ធិមនុស្សបាន សម្រេចថា ជនជាប់ឃុំមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលជាប់ពន្ធនាគារបានទៀតផង ការរំពឹងទុក មួយគឺថាការចាត់ចែងដ៏ល្អបំផុតមួយ គួរតែអាចកើតមានដើម្បីធ្វើរក្សាឲ្យបាននូវទំនាក់ទំនងរវាងជនជាប់ឃុំ និង ក្រុមគ្រួសាររបស់ជនជាប់ឃុំ។ ការរំពឹងទុកនេះមិនមែនមានតែក្នុង សេចក្ដីថ្លែងការណ៍ស្ដីពីសិទ្ធិមានទំនាក់ ទំនងជាមួយនឹងជីវិតក្នុងគ្រួសារក្នុងលិខិតុបករណ៍អន្តរជាតិស្ដីពីសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែមាត្រា ១០ នៃ

[54] មាត្រា ១២ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស

[55] មាត្រា ២៣ កតិសញ្ញាអន្តរជាតិស្ដីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ[56]។ ការធានាឲ្យមានការជួបជាមួយក្រុមគ្រួសារ ត្រូវតែជាផ្នែកមួយនៃប្រព័ន្ធប្រព្រឹត្តមកលើជនជាប់ឃុំដោយមនុស្សធម៌ សារៈសំខាន់ក្នុងការថែរក្សាទំនាក់ទំនងជាមួយក្រុមគ្រួសារអាចជាលក្ខខណ្ឌមួយចំនួនរបស់អាជ្ញាធរពន្ធនាគារ។ ក្នុងបណ្តាប្រទេសមួយចំនួន ជនជាប់ឃុំត្រូវពឹងផ្អែកលើសមាជិកគ្រួសារ ដើម្បីផ្គត់ផ្គង់សម្លៀកបំពាក់ ម្ហូបអាហារ ថ្នាំសង្កូវ និងសម្ភារៈប្រើប្រាស់ចាំបាច់ផ្សេងៗ ដូច្នេះការដាក់ជនជាប់ឃុំក្នុងពន្ធនាគារនៅជិតស្រុកភូមិរបស់ខ្លួនគឺជាការសំខាន់ណាស់ ដើម្បីងាយស្រួលឲ្យសមាជិកគ្រួសារ និងមិត្តភក្តិគួរមានសិទ្ធិចូលសួរសុខទុក្ខជនជាប់ឃុំក្នុងពន្ធនាគារ។ ការសួរសុខទុក្ខទាំងនេះធ្វើឡើងជាលក្ខណៈធម្មតាបំផុតនៅពេលមានលក្ខខណ្ឌអំណោយផលការសួរសុខទុក្ខ គួរធ្វើឡើងជាលក្ខណៈឯកជន តាមដែលអាចធ្វើទៅបាន គ្រប់ពេលទាំងអស់គេមិនគួរភ្លេចគិតថា ការសួរសុខទុក្ខ ជាពិសេស ជាមួយសមាជិកគ្រួសារដែលជិតស្និទ្ធបំផុត មិនត្រូវចាត់ទុកជាបុព្វសិទ្ធិជាជាងសិទ្ធិមនុស្សជាមូលដ្ឋាននោះទេ ការរារាំងណាមួយ ឬលក្ខខណ្ឌនៃការសួរសុខទុក្ខចាំបាច់ត្រូវតែបង្ហាញពីហេតុផលសម្រាប់ករណីនីមួយៗ អាជ្ញធរពន្ធនាគារគួរបង្កើតបរិយាកាសសួរសុខទុក្ខឲ្យបានល្អជាអតិបរមាតាមស្ថានភាពអំណោយផលតាមដែលអាចធ្វើបានការប្រព្រឹត្តទៅលើក្រុមគ្រួសារ និងអ្នកមកសួរសុខទុក្ខពេលចូលមកដល់ពន្ធនាគារ គឺជាខ្នាតវាស់វែងដ៏ល្អមួយទៅលើកម្រិតនៃការគ្រប់គ្រងពន្ធនាគារល្អ វិធីនេះមានសារៈសំខាន់យ៉ាងខ្លាំងដល់ជនជាប់ឃុំ ហើយដូចនេះការប្រព្រឹត្តនេះអាចមានផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានលើបញ្ហាសន្តិសុខ និងស្ថិរភាពក្នុងពន្ធនាគារ ក្រៅពីការសួរសុខទុក្ខផ្ទាល់របស់ក្រុមគ្រួសារ ទម្រង់នៃការទាក់ទងផ្សេងៗទៀត ក៏មានភាព ចាំបាច់ផងដែរ។ ជនជាប់ឃុំគួរមានសិទ្ធិផ្ញើ និងទទួលសំបុត្រ ធ្វើការទាក់ទង ឬទទួលទូរស័ព្ទដោយសេរីតាមដែលអាចធ្វើបាន។

## ២.៥.សិទ្ធិទទួលបានការដោះលែងដោយមានលក្ខខណ្ឌ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ទណ្ឌិតអាចត្រូវបានដោះលែងបានមុនពេលកំណត់ឲ្យមានសេរីភាពឡើងវិញតែត្រូវមានលក្ខខណ្ឌចំពោះការដោះលែង។ អ្នកទោសត្រូវបានដោះលែងដោយមានលក្ខខណ្ឌ គឺសំដៅដល់អ្នកទោសដែលត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅក្នុងសង្គមវិញ និងត្រូវអនុវត្តតាមលក្ខខណ្ឌដែលតុលាការដាក់ឲ្យអនុវត្តលក្ខខណ្ឌនោះរួមមាន **ទី១** លក្ខខណ្ឌទាក់ទងនឹងកិរិយាមារយាទ **ទី២** លក្ខខណ្ឌទាក់ទងនឹងថេរវេលានៃការអនុវត្តទោសដែលត្រូវបានទទួលទោសរួចហើយ។

[56] មាត្រា ១០ កតិសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

### ២.៥.១.លក្ខខណ្ឌទាក់ទងនឹងកិរិយា មារយាទ

លក្ខខណ្ឌទាក់ទងនឹងកិរិយាមារយាទ ទណ្ឌិតត្រូវបង្ហាញឲ្យគេឃើញថាខ្លួនមានគំនិតមារយាទល្អនឹងមានការកែប្រែខ្លួនក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ជូនខ្លួនទៅក្នុងសង្គមវិញបាន[57]។ មានន័យថា ទណ្ឌិតត្រូវធ្វើសកម្មភាពផ្សេងៗជាអាទិ៍ ការរាងចាល ការដឹងកំហុស ការសម្តែងឆន្ទៈសោកស្តាយចំពោះអំពើរបស់ខ្លួន ជាដើមដែលឲ្យគេមើលឃើញថាខ្លួនពិតជាមានឆន្ទៈ និងលក្ខណៈគ្រប់គ្រាន់អាចចេញពីពន្ធនាគារដោយការដឹងកំហុស ចេះកែប្រែខ្លួនឡើងវិញ។

### ២.៥.២..លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃការអនុវត្តទោស

លក្ខខណ្ឌទាក់ទងនឹងថិរវេលានៃទោសដែលត្រូវបានទទួលរួចរាល់ហើយ ទណ្ឌិតដែលទទួលបានការដោះលែងដោយមានលក្ខខណ្ឌ តុលាការត្រូវពិនិត្យទៅលើការអនុវត្តទោស ថាតើទណ្ឌិតនោះអនុវត្តទោសបានយូរប៉ុនណាហើយ។ ការដោះលែងដោយមានលក្ខខណ្ឌអាចត្រូវផ្តល់ឲ្យដល់ទណ្ឌិតដែលទទួលរងទោសដាក់ពន្ធនាគារ៖

ក. ចំនួនពាក់កណ្តាលនៃទោសប្រសិនបើទោសនោះតិចជាង ឬស្មើ ១ឆ្នាំ

ខ. ចំនួនពីរភាគបី នៃទោសក្នុងករណីផ្សេងទៀត

គ. ទណ្ឌិតដែលត្រូវជាប់ពន្ធនាគារអស់មួយជីវិត អាចទទួលការដោះលែងដោយមាលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះទទួលទោសជាប់ពន្ធនាគារយ៉ាងតិចបំផុត២០ (ម្ភៃ) ឆ្នាំរួចមកហើយ[58]។

### ២.៥.៣.នីតិវិធីក្នុងការដោះលែងដោយមានលក្ខខណ្ឌ

ចំពោះនីតិវិធីនៃការសម្រេចដោះលែងដោយមានលក្ខខណ្ឌនេះត្រូវសម្រេច និងផ្តល់ឲ្យដោយប្រធានសាលាដំបូងនៃទីកន្លែងឃុំខ្លួន។ ប្រធានតុលាការនេះសម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។ គណៈកម្មការជាតិរួមមាន៖ សមាជិក២ (ពីរ) រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែល១ (មួយ) រូបជាប្រធាន និងប្រធានពន្ធនាគារ ឬតំណាងជាសមាជិក[59]។ ក្រោយពីបានទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាប់ដំបូងត្រូវបញ្ជូនទៅគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌនូវសំណុំឯកសាររួមមានជាអាទិ៍ នូវពាក្យសុំ សាលក្រម ឬសាលដីកាផ្តន្ទាទោស សាលក្រម ឬសាលដីកា(មួយ ឬច្រើន) ព្រឹត្តិបត្រលេខ១ នៃបញ្ជីថ្កោលទោស យោបល់ព្រះរាជអាជ្ញា និងគ្រប់លិខិត

[57] មាត្រា ៥១២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] មាត្រា ៥១៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59] មាត្រា ៥១៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទាំងអស់ដែលមានប្រយោជន៍ដើម្បីពិនិត្យ និងផ្តល់យោបល់។ បន្ទាប់ពីបានពិនិត្យរួចគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌបញ្ចេញយោបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត។ យោបល់នេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវផ្ញើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម[60]។ ប្រធានតុលាការជាន់ដំបូង មិនត្រូវជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌទេ បន្ទាប់ពីបានទទួលយោបល់ ពីគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌរួចមក ប្រធានសាលាដំបូង ត្រូវចេញសេចក្តីសម្រេចតាមដីកាដោយមានសំអាងហេតុ។ សេចក្តីសម្រេចរបស់ប្រធានតុលាការនេះអាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល **៥** ថ្ងៃ។ បណ្តឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញា នៃតុលាការសាមីតែប៉ុណ្ណោះ។ ប្រសិនបើមានការតវ៉ាសេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍ ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាដោយមានសំអាងហេតុ និងមិនអាចតវ៉ាបានឡើយ[61]។ សេចក្តីសម្រេចឲ្យដោះលែងដោយមានលក្ខខណ្ឌត្រូវកំណត់បែបបទនៃការអនុវត្ត និងលក្ខខណ្ឌនៃការដោះលែងទណ្ឌិត។ សេចក្តីសម្រេចនេះកំណត់រយៈពេលសាកល្បងដែលមិនអាចលើសពីចិរវេលានៃទោស ដែលនៅសល់មិនទាន់បានទទួលរងឡើយ[62]។ លើសពីនេះថ្មីៗនេះក្រសួងយុត្តិធម៌បានចេញប្រកាសស្តីពីបែបបទនៃការឃ្លាំមើលតាមដានការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញនៃទណ្ឌិត ដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ លេខ **០៩០ កយប្រក/២១** ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ផងដែរ។ ប្រសិនបើទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ បានបំពាននូវលក្ខខណ្ឌដូចដែលមានកំណត់នៅក្នុងសេចក្តីសម្រេចដោះលែងរបស់ខ្លួន ក្នុងករណីនេះប្រធានតុលាការជាន់ដំបូង អាចបង្គាប់ឲ្យដកហូតសេចក្តីសម្រេចរបស់ខ្លួនមកវិញបាន[63]។ មិនត្រឹមតែប៉ុណ្ណោះក្នុងករណីបន្ទាន់ ព្រះរាជអាជ្ញានៃតុលាការសាមីអាចបង្គាប់ឲ្យចាប់ខ្លួនទណ្ឌិតដែលបានដោះលែងនោះបាន ព្រះរាជអាជ្ញាត្រូវជូនដំណឹងទៅប្រធានសាលាដំបូងភ្លាម[64]។ ក្នុងករណីដកហូតការដោះលែងដោយមានលក្ខខណ្ឌទណ្ឌិតត្រូវទទួលទោសរបស់ខ្លួនដែលនៅសេសសល់ ។ រយៈពេលសេសសល់ ត្រូវគិតចាប់ពីពេល ដែលទណ្ឌិតទទួលសេចក្តីសម្រេចឱ្យដោះលែងដោយមានលក្ខខណ្ឌ។ ប្រសិនបើទណ្ឌិតត្រូវបានចាប់ខ្លួនឡើងវិញ រយៈពេលឃុំខ្លួនរហូតទល់នឹងសេចក្តីសម្រេចដកហូតការ

---

[60] មាត្រា ៥១៥ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[61] មាត្រា ៥១៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[62] មាត្រា ៥១៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[63] មាត្រា ៥១៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[64] មាត្រា ៥១៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវយកមកគិតក្នុងចិរវេលានៃទោសដែលនៅសេសសល់[65]។ ប្រសិនបើការដោះលែងដោយមានលក្ខខណ្ឌមិនត្រូវបានដកហូតក្នុងរយៈពេលសាកល្បងទេ ការដោះលែងក្លាយទៅជាស្ថាពរ ក្នុងករណីនេះទោសត្រូវចាត់ទុកថាបានទទួលតាំងពីថ្ងៃដោះលែងដោយមានលក្ខខណ្ឌមកម្ល៉េះ[66]។ សរុបមកការដោះលែងដោយមានលក្ខខណ្ឌ គឺជានីតិវិធីពិសេសមួយដែល មានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីពន្ធនាគារ និងប្រកាសស្តីពីបែបបទនៃការឃ្លាំមើលតាមដាន ការត្រួតពិនិត្យ និងការបញ្ចូលទៅក្នុងសង្គមវិញ នៃទណ្ឌិតដែលត្រូវបានដោះលែងដោយមានលក្ខខណ្ឌ លេខ **០៩០ កយប្រក/២១** ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ត្រូវបានយកមកអនុវត្តដើម្បីជួយសម្រួលដល់ទណ្ឌិតណា ដែលបានដឹងពីទោសកំហុសរបស់ខ្លួន ហើយមានឆន្ទៈកែប្រែខ្លួនឡើងវិញ ដោយបានអនុវត្តទោសនៅក្នុងពន្ធនាគារបានមួយរយៈរួចហើយ តាមលក្ខខណ្ឌនៃច្បាប់កំណត់ ឲ្យពួកគាត់បានជួបជុំគ្រួសារ ប្រកបមុខរបរ និងមានសិទ្ធិសេរីភាពអាចចូលរួមក្នុងសង្គមឡើងវិញបាន។

### ២.៦.សិទ្ធិទទួលបានការលើកលែងទោស និងបន្ធូរបន្ថយទោស

ការលើកលែងទោស និងបន្ធូរបន្ថយទោសគឺវិធានការមួយដើម្បីកាត់បន្ថយជនជាប់ឃុំដែលមានចំនួនច្រើនក្នុងពន្ធនាគារ និងជាការអនុគ្រោះចំពោះទណ្ឌិតណាដែលបានប្រព្រឹត្តល្អក្នុងពន្ធនាគារស្គាល់ពីទោសកំហុសរបស់ខ្លួនហើយចេះកែប្រែខ្លួនឡើងវិញ។ ដើម្បីលើកទឹកចិត្តដល់អ្នកទោសដែលបានកែប្រែខ្លួន កម្ពុជា មានគោលការណ៍បន្ធូរបន្ថយទោស និងលើកលែងទោសឲ្យអ្នកទោសចំនួន៥ដង ក្នុង១ឆ្នាំ រួមមាន ក្នុងពិធីបុណ្យចូលឆ្នាំខ្មែរ ក្នុងពិធីបុណ្យវិសាខបូជា ក្នុងពិធីបុណ្យឯករាជ្យជាតិ ក្នុងពិធីបុណ្យអុំទូក និង ក្នុងទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍[67]។ ការបន្ធូរបន្ថយទោស និងការលើកលែងទោស គឺជាការសម្រេចព្រះរាជហឫទ័យរបស់ព្រះមហាក្សត្រ ដោយមានសំណើពីនាយករដ្ឋមន្ត្រី ក្រោយនាយករដ្ឋមន្ត្រីទទួលបានសំណើនោះ ពីគណៈកម្មការជាតិទទួលបន្ទុកពិនិត្យការបន្ធូរបន្ថយទោសនិងការលើកលែងទោស។ អ្នកទោសដែលទទួលបានការបន្ធូរបន្ថយទោសពីព្រះមហាក្សត្រ គឺត្រូវបន្តជាប់ឃុំដដែល តែទោសជាប់ឃុំនោះ ត្រូវបានកាត់បន្ថយទោស ចំណែកអ្នកទោសដែលទទួលបានការលើកលែងទោសពីព្រះមហាក្សត្រ ត្រូវបានដោះលែងពីការឃុំឃាំង ហើយលែងមានឈ្មោះជាអ្នកទោសដែលត្រូវតុលាការ ឬអាជ្ញាធរតាមឃ្លាំមើលទៀតដែរ។ ការលើកលែងទោស និងបន្ធូរបន្ថយ

[65] មាត្រា ៥២០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[66] មាត្រា ៥២១ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[67] មាត្រា ៣ ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

ទោសក៏ជាវិធានការមួយសំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឲ្យខិតខំកសាងកែប្រែ គំនិតមាយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេល អនាគត។

### ២.៦.១.លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងលើកលែងទោស

ទណ្ឌិតដែលត្រូវទទួលបានការលើកលែងទោស និងការបន្ធូរបន្ថយទោសអាចអនុវត្តទៅបានតែចំពោះទណ្ឌិតដែលត្រូវបានផ្តន្ទាទោសដោយសាលក្រម ឬសាលដីកាស្ថាពរតែប៉ុណ្ណោះ[68] ការលើកលែងទោស និងបន្ធូរបន្ថយទោស អាចអនុវត្តទៅបានចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឲ្យក្លាយទៅជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរកម្មចូលរួមរស់ក្នុងសង្គម
- គោរពប្រតិបត្តិយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមសេចក្តីណែនាំផ្សេងទៀតរបស់ពន្ធនាគារ

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិត ដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត[69]។ ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌខាងលើនេះអាចទទួលបានការបន្ធូរបន្ថយទោសបានលុះត្រាតែ ទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់ ក្នុងករណីទណ្ឌិតដែលទទួលរងទោសដាក់ពន្ធនាគារអស់មួយជីវិត ទណ្ឌិតនោះត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន[70] ដោយរយៈនៃការបន្ធូរបន្ថយទោសត្រូវកំណត់ដូចខាងក្រោម៖

១. ទោសដាក់ពន្ធនាគារកំណត់ **១ (មួយ) ឆ្នាំ** ដល់ក្រោម **៥ (ប្រាំ) ឆ្នាំ** អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន **៣ (បី) ខែ**។

---

[68] មាត្រា ៤ ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[69] មាត្រា ៥ ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

[70] មាត្រា ៧ ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

២. ទោសដាក់ពន្ធនាគារកំណត់ **៥ (ប្រាំ) ឆ្នាំ** ដល់ក្រោម **១០ (ដប់) ឆ្នាំ** អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន **៦ (ប្រាំមួយ) ខែ** ឬ **៣ (បី) ខែ**។

៣. ទោសដាក់ពន្ធនាគារកំណត់ **១០ (ដប់) ឆ្នាំ** ដល់ក្រោម **២០ (ម្ភៃ) ឆ្នាំ** អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន **៩ (ប្រាំបួន) ខែ** ឬ **៦ (ប្រាំមួយ) ខែ** ឬ **៣ (បី) ខែ**។

៤. ទោសដាក់ពន្ធនាគារកំណត់ **២០ (ម្ភៃ) ឆ្នាំ** ដល់ក្រោម **៣០ (សាមសិប) ឆ្នាំ** អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន **១២ (ដប់ពី) ខែ** ឬ **៩ (ប្រាំបួន) ខែ** ឬ **៦ (ប្រាំមួយ) ខែ** ឬ **៣ (បី) ខែ**។

៥. ទោសដាក់ពន្ធនាគារមួយជីវិតអាចនឹងបន្ថយទោសលើកទី១ មកនៅត្រឹម**៣០ (សាមសិប) ឆ្នាំ**[71]។

### ២.៦.២.នីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

យោងតាមច្បាប់ស្តីពីពន្ធនាគារដែលប្រកាសឲ្យប្រើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ មាត្រា៧៤ ចែងថា អភិបាលនៃគណៈអភិបាលខេត្តរាជធានីត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន គណៈកម្មាធិការនេះត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសបញ្ជូនទៅ គណៈកម្មការថ្នាក់ជាតិតាមរយៈអគ្គនាយនៃអគ្គនាយកដ្ឋានពន្ធនាគារយ៉ាងយឺតបំផុត **៣០ ថ្ងៃ** មុនថ្ងៃកំណត់នៃពីធីបុណ្យនីមួយៗ

- **គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖**

| | |
|---|---|
| - អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | ប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត | អនុប្រធាន |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី-ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| - អនុប្រធានពន្ធនាគាររាជធានី-ខេត្ត ទទួលបន្ទុកអប់រំកែប្រែ | ជាសមាជិក |

អគណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតក្នុងរយៈពេលជាឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន គណៈកម្មការនេះត្រូវធ្វើបញ្ជី

[71] មាត្រា ៨ ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស ឆ្នាំ២០២១

ឈ្មោះទណ្ឌិតដែលមានលក្ខណៈសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសបញ្ជូនទៅ គណៈកម្មការថ្នាក់ជាតិយ៉ាងយឺតបំផុត ៣០ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ

➢ **គណៈកម្មការមានសមាសភាពដូចខាងក្រោម៖**

- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ ជាប្រធាន
- តំណាងអង្គការអយ្យការសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំកែប្រែសាមី ជាអនុប្រធាន
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាអនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- ប្រធាននាយកដ្ឋានអប់រំកែប្រែ ជាសមាជិក
- ប្រធាននាយកដ្ឋានប្រតិបត្តិ ជាសមាជិក
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀតតាមការចាំបាច់ ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[72]។

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសដែលបានផ្ញើមកពិនិត្យ និងវាយតម្លៃរួចហើយគណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រ សុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិតយ៉ាងយឺតបំផុត **១០ ថ្ងៃ** មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ

➢ **គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖**

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ ជាអនុប្រធានអចិន្ត្រៃយ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ជាអនុប្រធាន
- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ចំនួន១រូប ជាសមាជិក
- ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ ជាសមាជិក

[72] មាត្រា ៧៤ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

- តំណាងក្រសួងយុត្តិធម៌១រូប ជាសមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ ជាសមាជិក
- ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារចំនួន ០២រូប ជាសមាជិក
- គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។
- ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះត្រូវកំណត់ដោយអនុក្រឹត្យតាម សំណើរបស់ក្រសួងមហាផ្ទៃបន្ទាប់ពីមានការឯកភាពគ្នាពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ម្យ៉ាងវិញទៀតប្រមុខរាជរដ្ឋាភិបាលក្នុងករណីចំបាច់ក៏មានបុព្វសិទ្ធិ ធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឱ្យទណ្ឌិតប្រធានពន្ធនាគាររាជធានី-ខេត្តទទួលបន្ទុកប្រតិបត្តិជាសមាជិក នៅពេលណាក៏បានដែរដោយមិនចាំបាច់មានសំណើពីគណៈកម្មការណាមួយឡើយ[73]។

[73] មាត្រា ៧៥ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

# ជំពូកទី២

# ការអនុវត្តសិទ្ធិជនជាប់ចោទជាអនីតិជន វិធានការ និងនីតិអនុវត្តចំពោះអនីតិជន

# ជំពូកទី២
# ការអនុវត្តសិទ្ធិជនជាប់ចោទជាអនីតិជន វិធានការ និងនីតិវិធីអនុវត្តចំពោះអនីតិជន

## ផ្នែកទី១៖ សិទ្ធិជនជាប់ចោទជាអនីតិជន

អនីតិជនទាំងអស់ដែលរងនៅការចោទប្រកាន់ មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នាទៅនឹងនីតិជនផងដែរ។ បើទោះបីជាយ៉ាងនេះក្តីអនីតិជនក៏ទទួលបាននូវកិច្ចការពារបន្ថែមដោយសារមូលហេតុនៃអាយុ ភាពដឹងក្តី និងការអភិវឌ្ឍន៍ផ្នែកប្រាជ្ញារបស់ពួកគេ។ កតិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងយ៉ាងជាក់លាក់សម្រាប់ការប្រព្រឹត្តទៅលើអនីតិជននៅក្នុងដំណើរការកិច្ចនីតិវិធីព្រហ្មទណ្ឌ បញ្ញាត្តិទាំងនេះត្រូវរួមបញ្ចូលនូវនីតិវិធីដែលធ្វើឡើងដោយពិចារណាទៅលើអាយុរបស់កុមារ និងលើកកម្ពស់ការពារអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ ប្រទេសកម្ពុជាបានអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជន នៅក្នុងឆ្នាំ២០១៦ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌទាំងអស់ ជាក់ស្តែងការអនុវត្តសិទ្ធិរបស់អនីតិជនត្រូវតែអនុវត្តចាប់តាំងពីដំណាក់កាលដំបូងរហូតដល់ដំណាក់ការចេញសេចក្តីសម្រេចជាស្ថាពរ ឬរហូតដល់កុមារត្រូវបានដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ឬរហូតដល់ការអនុវត្តវិធានផ្សេងទៀតដូចជា វិធានការតាមដាន វិធានការអប់រំ វិធានការពារ និងវិធានការឧបត្ថម្ភ។

### ១.សិទ្ធិឯកជនភាព

ការជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌពាន់ព័ន្ធទៅនឹង នីតិជនត្រូវធ្វើឡើងជាសាធារណៈទូទៅដើម្បីឲ្យ សមស្របទៅតាមសិទ្ធិទទួលបានសវនាការជាសាធារណៈ ប៉ុន្តែចំពោះការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌទាក់ទងជាមួយនឹងអនីតិជនវិញ គឺត្រូវធ្វើឡើងជាអសាធារណៈ[74] ហើយត្រូវតែមានភាពរឹតត្បិតចំពោះសាធារណៈជនដែលចូលរួមនីតិវិធីជំនុំជម្រះក្តីនោះ និងរិតត្បិតចំពោះការធ្វើរបាយការណ៍ក្នុងគោលបំណងដើម្បីការពារអនីតិជនពីផលប៉ះពាល់ដែលអាចបង្កមកពីការផ្សព្វផ្សាយជាសាធារណៈ។ ការចូលរួមជាសាធារណៈអាចត្រូវបានរិតត្បិត ដើម្បីការពារដល់ភាពឯកជនរបស់អនីតិជនដោយតុលាការគួរគប្បីធ្វើការរៀបចំបន្ទប់សវនាការដាច់ដោយឡែកមួយក្នុងករណីដែលតុលាការមិនអាចរៀបចំបន្ទប់សវនាការមួយដាក់ដោយឡែកបាននោះទេ ដូច្នេះសាធារណៈជនលើកលែងតែឪពុកម្តាយ ឬអ្នកអាណាព្យាបាលតាមច្បាប់ មិនត្រូវបានអនុញ្ញាតឲ្យចូលរួមសវនាការដែល

[74] មាត្រា ៤៧ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ទាក់ទងជាមួយនឹងអនីតិជននោះទេ មិនត្រឹមតែប៉ុណ្ណោះរាល់ព័ត៌មានលម្អិតដែលទាក់ទងជាមួយនឹងអនីតិជន មិនត្រូវដាក់បង្ហាញជាសាធារណៈនោះទេ។

### ២. សិទ្ធិមិនផ្តល់ចម្លើយនៅពេលមាន ឬគ្មានវត្តមានមេធាវី

ជនជាប់ចោទជាអនីតិជនដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិក្នុងការរក្សាភាពស្ងៀមស្ងាត់ដោយមិនឆ្លើយតបទៅរាល់សំនួរទាំងអស់របស់តុលាការ បើទោះបីជាមាន ឬគ្មានវត្តមានរបស់មេធាវីក៏ដោយ។ នៅពេលជនជាប់ចោទរក្សាភាពនៅស្ងៀមមិនឆ្លើយតបទៅអ្វីដែលតុលាការបានចោទសួរក៏ដោយក៏តុលាការមិនអាចយកវាមកធ្វើក្នុងការវិនិច្ឆ័យសេចក្តីថាជនម្នាក់នោះមានទោស ឬគ្មានទោសនោះទេ។ភាពស្ងៀមស្ងាត់របស់ជនជាប់ចោទមានករណីខ្លះអាចរួមចំណែកដល់ការផ្តន្ទាទោសបាន ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ហើយជនជាប់ចោទមិនបានផ្តល់ការពន្យល់បន្ថែមទៀតទេ យ៉ាងណាមិញនៅក្នុងបរិបទនៃការកាត់ទោសជនជាប់ចោទអាចត្រូវបានស្តីបន្ទោសចំពោះភាពស្ងៀមស្ងាត់របស់គាត់ដែលថាគាត់មិនបានប្រែចិត្ត ឬសោកស្តាយចំពោះសកម្មភាពរបស់គាត់ ថាតើចៅក្រមយកសិទ្ធិប្រើប្រាស់ដើម្បីរក្សាភាពស្ងៀមស្ងាត់ដោយជនជាប់ចោទគិតពិចារណាអំពីការកាត់ទោសនោះទេ គឺវាអាស្រ័យលើការវាយតម្លៃផ្ទាល់ខ្លួនរបស់ចៅក្រមហើយដូច្នេះអាចខុសគ្នាចំពោះចៅក្រមនីមួយៗ។ ការប្រើសិទ្ធិដើម្បីនៅស្ងៀមអាចមានគុណសម្បត្តិសម្រាប់ជនជាប់ចោទវាជាការពិតដែលសិទ្ធិរបស់ជនចាប់ចោទក្នុងការនៅស្ងៀមត្រូវតែគោរព ទោះយ៉ាងណានៅពេលដាក់ពាក្យបណ្តឹងចៅក្រម អាចពិចារណាកាន់តែខ្លាំងឡើងនូវភាពស្ងៀមស្ងាត់របស់ជនជាប់ចោទចំពោះគុណវិបត្តិផ្ទាល់ខ្លួន។ តួយ៉ាងសិទ្ធិរបស់ជនជាប់ចោទក្នុងការរក្សាភាពស្ងៀមស្ងាត់ គឺត្រូវបានអនុវត្តជាប្រចាំដោយមានតួនាទីកាន់តែខ្លាំងឡើងនៅក្នុងនីតិវិធីព្រហ្មទណ្ឌ និងសារៈសំខាន់នៃជនរងគ្រោះការរស់នៅរបស់សាច់ញាតិ ឬសង្គមដោយមានចម្លើយច្បាស់លាស់ចំពោះសំណួរ ទោះជាក្នុងករណីរបស់អ្នកមានភាពវាងវៃក្នុងការប្រើសិទ្ធិ ដើម្បីរក្សាភាពស្ងៀមស្ងាត់ក្នុងអំឡុងពេលសវនាការប៉ូលីស ឬនៅក្នុងសវនាការក៏ដោយវាអាស្រ័យលើកាលៈទេសៈ នៃករណីនេះ ដូច្នេះវាសំខាន់ណាស់ដែលអ្នកត្រូវទាក់ទងមេធាវីព្រហ្មទណ្ឌមុនពេលសម្រេចចិត្តទាក់ទង នឹងសិទ្ធិនៅស្ងៀម។

### ៣.សិទ្ធិមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី

នៅក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌដែលមានជនជាប់ចោទជានីតិជន ជាគោលការណ៍គេអនុវត្តបានចំពោះគ្រប់ដំណាក់កាលនីតិវិធី បើទោះបីជាគ្មានការចូលរួមពីអាណាព្យាបាល ឬអ្នកមានអំណាចមេបាក៏ដោយ សំខាន់ឲ្យតែជននោះអាចកំណត់បានថាជានីតិជនដែលមានសមត្ថភាពគ្រប់គ្រាន់អាចធ្វើការតតាំងក្តី

តាមផ្លូវច្បាប់ដោយខ្លួនឯងបាន។ ដោយឡែកចំពោះជនជាប់ចោទជាអនីតិជនវិញដាច់ខាតត្រូវតែមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការនីតិវិធីទាំងអស់ ក្នុងន័យនេះផងដែរអ្នកតំណាងដែលច្បាប់បានកំណត់សំដៅទៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ[75]។ ដោយហេតុថាអនីតិជនជាជនមួយដែលពុំសូវមានការយល់ដឹង នឹងមានសមត្ថភាពក្នុងការតតាំងផ្នែកច្បាប់ដោយខ្លួនផ្ទាល់បាន ហេតុនេះហើយការចូលរួមពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់វាពិតជាមានសារៈសំខាន់ណាស់សម្រាប់ជនជាប់ចោទជាអនីតិជនផ្ទាល់ ដែលការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នេះអាចការពារអនីតិជននោះពីការគំរាមកំហែងពីសំណាក់មន្ត្រីនគរបាល និងមិនធ្វើឲ្យអនីតិជននោះមានភាពភ័យខ្លាចនៅក្នុងដំណាក់កាលជំនុំជម្រះជាដើម រាល់ការឃាត់ខ្លួនអនីតិជនគឺចាំបាច់ត្រូវជូនដំណឹងក៏ដូចជាព័ត៌មានទៅឪពុកម្ដាយ និងអ្នកតំណាងដែលច្បាប់កំណត់ ឬដល់អ្នកទទួលបន្ទុកភារកិច្ចលើអនីតិជននេះ[76] តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានដោយតម្រូវយ៉ាងណាឲ្យមានការចូលរួមពីសំណាក់អ្នកតំណាងដែលច្បាប់បានកំណត់ មួយវិញទៀតចំពោះការចោទប្រកាន់ ឬការសាកសួរផ្សេងៗនៅក្នុងដំណាក់កាលអយ្យការ ព្រមទាំងនៅក្នុងតំណាក់កាលចៅក្រមស៊ើបសួរ ក៏ត្រូវតែមាននូវវត្តមានរបស់អ្នកតំណាងដែលច្បាប់កំណត់ដែរ រីឯនៅក្នុងនីតិវិធីនៃការជំនុំជម្រះដែលកំឡុងពេលសវនាការ និងការប្រកាសសាលក្រមក៏ច្បាប់តម្រូវឲ្យមានវត្តមានអ្នកតំណាងនោះដែរ នេះយើងអាចកំណត់បានថាការចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់ពិតជាមានសារៈសំខាន់ណាស់ ហើយក៏ជាសិទ្ធិមួយដែលពុំគួរមើលរំលងហើយត្រូវអនុវត្តជាចាំបាច់ព្រោះថាសិទ្ធិកុមារពិតជាត្រូវមានការយកចិត្តទុកដាក់ណាស់នៅជុំវិញពិភពលោកក៏ដូចជានៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្នផងដែរ។

### ៤.សិទ្ធិទទួលបានសេវាថែទាំសុខភាព និងព្យាបាល

ជនជាប់ចោទជាអនីតិជនទាំងអស់មានសិទ្ធិទទួលបាន ការផ្ដល់សេវាថែទាំសុខភាពក្នុងអំឡុងពេលដែលជាប់ឃុំ គឺជាការទទួលខុសត្រូវរបស់រដ្ឋ ជនជាប់ចោទត្រូវទទួលបានការថែទាំសុខភាពតាមស្តង់ដាដូចគ្នានឹងសេវាសុខភាពនៅខាងក្រៅពន្ធនាផងដែរ មិនត្រឹមតែប៉ុណ្ណោះជនជាប់ចោទជាអនីតិជនទាំងអស់ត្រូវទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃ និងមិនរើសអើងដោយសារស្ថានភាពផ្លូវច្បាប់របស់ពួកគេ។ សេវាថែទាំសុខភាពត្រូវបានចាត់ចែង និងសហការជិតស្និតជាមួយប្រព័ន្ធសុខាភិបាលសាធារណៈទូទៅ និងធានាឲ្យមាននិរន្តរភាពនៃការព្យាបាលថែទាំរួមទាំង មេរោគអេដស៍ របេង និងជំងឺឆ្លងផ្សេងៗទៀត ក៏ដូចជាចំពោះរោគ

[75] មាត្រា ៤ កថាខណ្ឌទី៥ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[76] មាត្រា ១០០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ញៀនផងដែរ។ ពន្ធនាគារនីមួយៗត្រូវមានសេវាថែទាំសុខភាពដែលមានភារកិច្ចវាយតម្លៃផ្សព្វផ្សាយ ការពារ និង លើកកម្ពស់សុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តរបស់ជនជាប់ចោទដែលកំពុងស្ថិតនៅក្នុងការឃុំខ្លួនជាបណ្ដោះអាសន្ន ដោយយកចិត្តទុកដាក់ជាពិសេសចំពោះពួកគេដែលត្រូវការការថែទាំសុខភាពពិសេស ឬដែលមានបញ្ហាសុខភាពដែលរារាំងដល់ការស្ដារនីតិសម្បទាឡើងវិញ សេវាថែទាំសុខភាពត្រូវមានសមាសភាពជាក្រុមចម្រុះ និងមានគុណវុឌ្ឍគ្រប់គ្រាន់ក្នុងការព្យាបាលដោយឯករាជ្យ និងត្រូវមានជំនាញផ្នែកចិត្តវិទ្យា និងវិកលវិទ្យាពន្ធនាគារ ក៏ត្រូវមានទន្តពេទ្យដែលមានគុណវុឌ្ឍិសមស្របសម្រាប់ជនជាប់ឃុំម្នាក់ៗថែមទៀតផង។ ផ្នែកសេវាថែទាំសុខភាពត្រូវរៀបចំថែទាំឯកសារពេទ្យទៀងទាត់ថ្មីៗ និងមានការសម្ងាត់របស់ជនជាប់ឃុំម្នាក់ៗ ហើយជនជាប់ឃុំទាំងអស់អាចអនុញ្ញាតឲ្យចូលមើលឯកសាររបស់ពួកគេទៅតាមសំណើ។ ជនជាប់ឃុំអាចពឹងពាក់ឲ្យអ្នកទីបីចូលមើលឯកសាររបស់ខ្លួនបាន ឯកសារពេទ្យត្រូវបានផ្ទេរទៅផ្នែកសេវាថែទាំសុខភាពនៃស្ថាប័នទទួលនៅពេលមានការផ្ទេរជនជាប់ឃុំណាម្នាក់ ដោយត្រូវរក្សាការសម្ងាត់វេជ្ជសាស្ត្រ។ពន្ធនាគារទាំងអស់ត្រូវធានាការទទួលការទទួលភ្លាមៗនូវការថែទាំវេជ្ជសាស្ត្រ ក្នុងករណីបន្ទាន់ជនជាប់ឃុំដែលត្រូវការការព្យាបាលពិសេស ឬការវះកាត់ត្រូវបញ្ជូនទៅស្ថាប័នជំនាញ ឬទៅមន្ទីរពេទ្យទូទៅនៅខាងក្រៅ។ ក្នុងពន្ធនាគារមានមន្ទីរពេទ្យខ្លួនឯងត្រូវមានបុគ្គលិក និងបំពាក់បរិក្ខារគ្រប់គ្រាន់ដើម្បីព្យាបាលថែទាំជនជាប់ឃុំដែលត្រូវទទួលសេវាសុខាភិបាលមានតែអ្នកជំនាញការផ្នែកថែទាំងសុខភាពប៉ុណ្ណោះ ដែលអាចធ្វើការសម្រេចចិត្តទាក់ទង នឹងការព្យាបាលដោយមិនត្រូវបានបំពានដោយ ឬមិនអើពើពីមន្ត្រីពន្ធនាគារដែលមិនមែនជាមន្ត្រីពេទ្យឡើយ។

### ៥.សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់ចាប់បីអាយុ ១៨ឆ្នាំឡើងទៅ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិអាយុចាប់ពី ១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ[77]។ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌការឃុំខ្លួនអនីតិជនបណ្ដោះអាសន្នជាវិធានការចុងក្រោយ ដោយមុននឹងចៅក្រមស៊ើបសួរសម្រេចចិត្តឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជនត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែរប្រសិនបើមាន[78]។ ជាទូទៅការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើឡើងតាមរយៈគំនិតផ្ដើមពីចៅក្រមស៊ើបសួរ ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដោយយោងតាមការពិចារណា ការស្វែងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្ដែងនៃបទល្មើសដែលបាន ប្រព្រឹត្ត។

[77] មាត្រា ៧ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦

[78] មាត្រា ៣៩ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើឆ្នាំ ២០១៦

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ននោះគឺត្រូវធ្វើឡើងតាមរយៈ **ដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន** ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើអនីតិជន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់យ៉ាងឡែកពីគ្នា ឬលក្ខណៈនៃបទល្មើស **(បទមជ្ឈិម ឬបទឧក្រិដ្ឋ)**។ ចំពោះអនីតិជនអាយុចាប់ពី **១៤ (ដប់បួន)** ឆ្នាំដល់ក្រោម **១៨ (ដប់ប្រាំបី)** ឆ្នាំនឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋដែលថិរវេលាឃុំខ្លួន បណ្តោះអាសន្នមានដូចតទៅៈ

១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី **៤ (បួន) ខែ** បានទេ កាលណាអនីតិជននេះមានអាយុតិចជាង **១៦ (ដប់ប្រាំមួយ) ឆ្នាំ** ។

២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី **៦ (ប្រាំមួយ) ខែ** បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី **១៦ (ដប់ប្រាំមួយ) ឆ្នាំ** ដល់ក្រោម **១៨ (ដប់ប្រាំបី) ឆ្នាំ**[79]។

បើក្នុងករណីជាបទមជ្ឈិមវិញ ការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជនអាយុចាប់ពី **១៤ (ដប់បួន) ឆ្នាំ** ដល់ក្រោម **១៨ (ដប់ប្រាំបី)** ត្រូវបានកំណត់ដូចខាងក្រោមៈ

១. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី **២ (ពីរ) ខែ** បានទេ កាលណាអនីតិជននេះមានអាយុតិចជាង **១៦ (ដប់ប្រាំមួយ) ឆ្នាំ**។

២. ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី **៤ (បួន) ខែ** បានទេកាលណាអនីតិជននេះមានអាយុចាប់ពី **១៦ (ដប់ប្រាំមួយ) ឆ្នាំ** ដល់ក្រោម **១៨ (ដប់ប្រាំបី) ឆ្នាំ** ។

ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចទី **១** និងចំណុចទី **២** ខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ[80]។ ជនត្រូវចោទអាចដាក់ពាក្យស្នើសុំដោះលែងឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាទៅកាន់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលាដោយគំនិតផ្តួចផ្តើមរបស់ខ្លួន ចៅក្រមស៊ើបសួរដែលមានបំណងដោះលែងអនីតិជនឲ្យនៅក្រៅឃុំ ត្រូវជូនព័ត៌មានទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលខ្លីបំផុត។ ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាមដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ឬបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញានោះទេ ដោយចៅក្រមស៊ើបសួរត្រូវចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃហេតុការបន្ទាន់នេះនៅក្នុងដីការសម្រេចរបស់ខ្លួន[81]។

---

[79] មាត្រា ២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[80] មាត្រា ២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[81] មាត្រា ៤១ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៦.សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ

នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះព្រះរាជអាជ្ញា និងធ្វើការចោទប្រកាន់រួចបញ្ជូនជននោះទៅចៅក្រមស៊ើបសួរដើម្បីធ្វើកិច្ចស៊ើបសួរដាក់បន្ទុក ឬដោះបន្ទុក ហើយប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាអំពើដែលបានប្រព្រឹត្តជាបទឧក្រិដ្ឋ ឬបទមជ្ឈឹមបានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គម នោះចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបុគ្គលនោះដើម្បីបញ្ចប់ ឬបង្ការបទល្មើសកុំឲ្យកើតឡើងជាថ្មី និងកុំឲ្យប៉ះពាល់ដល់នីតិវិធីស៊ើបសួរ ប៉ុន្តែប្រសិនបើអំពើនោះបានបង្កព្យសនកម្មតិចតួចដល់សង្គមជាតិ ហើយមានមូលហេតុសមស្របតាមច្បាប់ ដែលមិនធ្វើឲ្យប៉ះពាល់ដល់នីតិវិធីស៊ើបសួរទេ នោះចៅក្រមស៊ើបសួរអាចសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ដោយស្ថិតក្នុងដំណាក់កាលស៊ើបសួរ។ ជាផ្នែកមួយនៃវិធានការនិរន្តរាយ ដើម្បីធានាសម្រួលដល់ដំណើរការនៃកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[82]។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ការត្រួតពិនិត្យតាមផ្លូវតុលាការមានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយឬច្រើនដែលរួមមានដូចជា៖

១. មិនត្រូវចេញក្រៅ ព្រំប្រទល់ដែនដីកំណត់ ដោយចៅក្រមស៊ើបសួរ។
២. មិនត្រូវផ្លាស់ប្តូរលំនៅឋាន ដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។
៣. មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រមស៊ើបសួរ។
៤. ត្រូវចូលមកបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
៥. ត្រូវឆ្លើយតបនឹងដីកាកោះហៅ ពី គ្រប់បុគ្គល ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។
៦. ត្រូវប្រគល់ជូន ដល់ការិយាល័យ ក្រឡាបញ្ជី គ្រប់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ។
៧. មិនត្រូវបើកបររថយន្ត។
៨. មិនត្រូវទទួល ឬជួបនឹងបុគ្គលមួយចំនួន ដែលកំណត់ចង្អុលបង្ហាញដោយចៅក្រម ស៊ើបសួរ ។
៩. ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកទៅលើធនធាន របស់ជនដែលនឹងត្រូវចោទ។

[82] មាត្រា ២២៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

១០. មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់។

១១. ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឲ្យស្ថិតក្នុងរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ ។

១២. មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ឬតាមសេចក្តីសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា[83]។ ដោយបញ្ជាក់អំពីកាតព្វកិច្ចដែលតម្រូវលើជនត្រូវចោទនៅក្នុងដីកាសម្រេច ហើយត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។ កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្តឹងតាមសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាសុំឲ្យដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមិនព្រមសម្រេចតាមការសុំទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធការសុំនេះក្នុងរយៈពេល **៥ (ប្រាំ) ថ្ងៃ**[84] ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល **៥ (ប្រាំ) ថ្ងៃ** ទេ ព្រះរាជអាជ្ញាអាចធ្វើបណ្តឹងទៅសភាស៊ើបសួរ(សាលាឧទ្ធរណ៍) សម្រេចជំនួសចៅក្រមស៊ើបសួរ។ ចំពោះការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអាចធ្វើការកែប្រែ ឬលុបចោលខ្លឹមសារនៃកាតព្វកិច្ច និងបញ្ចូលកាតព្វកិច្ចថ្មីបានតាម **០៣(បី)** លក្ខខណ្ឌគឺ **(១)** ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយឯកឯងដោយចៅក្រមស៊ើបសួរ **និង(២)** បណ្តឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា **និង(៣)** តាមរយៈបណ្តឹងសុំឲ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ[85]។ នៅក្នុងករណីដែលជនត្រូវចោទបានគេចវេសដោយចេតនាពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឲ្យឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នបាន ទោះបីជាទោសពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយហើយទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមាដែលបានកំណត់ ក៏ដោយកាលណាចៅក្រមស៊ើបសួរសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ។ ការឃុំខ្លួនបណ្តោះអាសន្នដែលសម្រេចតាមមូលហេតុខាង

[83] មាត្រា ២២៦ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[84] មាត្រា ២២៨ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[85] មាត្រា ២២៩ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

លើនេះមិនអាចឲ្យលើសពី **៤ (បួន) ខែ** ចំពោះនីតិជន និង **២ (ពីរ) ខែ** ចំពោះអនីតិជន ចំពោះអនីតិជនដែលមានអាយុតិចជាង **១៤ (ដប់បួន )ឆ្នាំ** មិនអាចដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ[86]។

### ៧.សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទា ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងការផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋល្អ និងមានប្រយោជន៍ដល់សង្គមជាតិ។ ដូចនេះអនីតិជនដែលជាប់ឃុំទាំងអស់មានសិទ្ធិជាមូលដ្ឋានដូចជាៈ

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់មធ្យោបាយគ្រប់ទម្រង់ផ្សេងៗសម្រាប់ធ្វើទារុណកម្មណ រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅដែលច្បាប់បានកំណត់អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជន ពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងៗទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន[87]។

---

[86] មាត្រា ២៣០ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[87] មាត្រា ៨០ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ផ្នែកទី២៖ វិធានការ និងនីតិវិធីក្នុងការរក្សាអនីតិជន

### ១.វិធានការអនុវត្តលើអនីតិជន

អនីតិជន ច្បាប់ត្រូវបានចាត់ទុកជាជនដែលមានអាយុក្រោម **១៨ ឆ្នាំ** មិនត្រឹមតែប៉ុណ្ណោះនៅក្នុង ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានកំណត់អំពីនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវបានកំណត់អាយុចាប់ពី **១៨ ឆ្នាំ** ឡើងទៅ[88]។ បើទោះបីជាច្បាប់បានកំណត់ថាអនីតិមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ អនីតិជនដែលបានប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដានវិធានការអប់រំ វិធានការការពារ និងវិធានកាឧមត្ថម្ភ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្ម ព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី **១៤ ឆ្នាំ** ឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[89]។ វិធានដែលអនុវត្តទៅលើអនីតិជនរួមមាន៖

១. ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលទទួលបន្ទុកអនីតិជន។

៣. ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥. ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ក្នុងករណីដាក់ឲ្យអនីតិជនស្ថិតក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន បុគ្គលនេះធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា បុគ្គលនោះត្រូវផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការនេះ[90]។

### ២.ការរក្សាទុកនូវអនីតិជន

អនីតិជនជាប្រភេទមនុស្សមួយដែលត្រូវបានការពារអំពីសិទ្ធិ និងយកចិត្តទុកដាក់បំផុតជាងនីតិជនដែលច្បាប់បានកំណត់ឲ្យបានពេញលេញបំផុតដូច្នេះរាល់អនីតិជនដែលត្រូវបានឃុំឃាំង និងដកហូតសិទ្ធិសេរីភាពមួយចំនួន និងត្រូវធ្វើក្នុងលក្ខខណ្ឌដែលយកចិត្តទុកដាក់បំផុតដែលស្របទៅតាមឋានៈ អាយុ បុគ្គលិកលក្ខណៈ ភេទ ប្រភេទនៃបទល្មើស បញ្ហាសុខភាព សតិស្មារតី រាងកាយ អនីតិជនទាំងអស់ដែលជាប់ឃុំឃាំងត្រូវ

[88] មាត្រា ៣៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[89] មាត្រា ៣៩ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

[90] មាត្រា ៤១ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

បំបែកចេញពីមនុស្សពេញវ័យ ដោយលើកលែងតែជាសមាជិកគ្រួសារតែមួយ។ ដោយយោងមាត្រា ៨២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងថា ត្រូវរក្សាអនីតិជននៅក្នុងមណ្ឌលនីតិសម្បទាដូចខាងក្រោម៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នាតាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិក សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា ។
- នៅក្នុងអាគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជំងឺឆ្លង ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ **១៨ឆ្នាំ** ក្នុងពេលបាន និងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាបន្តរហូតដល់អាយុក្រោម **២៤ឆ្នាំ**។ នៅពេលទណ្ឌិតឈានចូលអាយុ **២៤ឆ្នាំ** ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន។ បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិតត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[91]។

### ៣.ការចុះបញ្ជីឈ្មោះអនីតិជន

ការចុះបញ្ជីឈ្មោះអនីតិជនត្រូវដាក់ដាច់ដោយឡែកពីនីតិជន និងត្រូវបានយកចិត្តទុកដាក់ជាពិសេសដល់ការគ្រប់គ្រងទៅលើអនីតិជន គ្រប់មណ្ឌលយុវនីតិសម្បទាត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជនព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព[92]។ ការចុះបញ្ជីឈ្មោះអនីតិជនគឺវាពិតជាមានសារប្រយោជន៍មួយងាយស្រួលក្នុងការគ្រប់គ្រង អនីតិជន ក្នុងពន្ធនាគារ ព្រោះការចុះបញ្ជីនេះអាចឱ្យដឹងពីព័ត៌មានលម្អិតរបស់អនីតិជនដូចជា អត្តសញ្ញាណរបស់អនីតិជន ព័ត៌មានអំពីសុខភាពរាងកាយ និងសតិស្មារតីដែលបានដឹងរួមមានការប្រព្រឹត្តគ្រឿងញៀន ឬសុរា។ គ្រប់មណ្ឌល យុវនីតិសម្បទាត្រូវមានបញ្ជី នីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជនព្រមទាំងបំពេញព័ត៌មានទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព បញ្ជីនិងនីតិវិធីដោយឡែកនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ គ្រប់ជនជាប់ចោទជាអនីតិជនទាំងអស់ត្រូវមានកំណត់ត្រាពេញលេញអំពីព័ត៌មានរបស់អនីតិជននោះ ដែលក្នុងនោះរួមមាន៖

ក. ព័ត៌មានអំពីអត្តសញ្ញាណរបស់អនីតិជន

[91] មាត្រា ៨២ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[92] មាត្រា ៧៨ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ខ. ហេតុការណ៍ និងហេតុផលសម្រាប់ការឃុំឃាំង និងអាជ្ញាធរឃុំឃាំង

គ. ថ្ងៃ និងម៉ោងទទួល ផ្ទេរ និងដោះលែង

ឃ. លិខិតជូនដំណឹងដល់ឪពុកម្តាយ និងអាណាព្យាបាលនៅរាល់ពេលទទួល ផ្ទេរ ឬដោះលែង អនីតិជនក្នុងការគ្រប់គ្រង់របស់គេនៅពេលឃុំឃាំង។

ង. ពិនិត្យអំពីបញ្ហាសុខភាព រាងកាយ និងស្មារតី ដែលបានដឹងរួមមានការប្រព្រឹត្ត និងប្រើប្រាស់គ្រឿងញៀន ឬសុរាដែរទេ។

## ៤.ការបែងចែង និងគ្រប់គ្រង់អនីតិជននៅក្នុងមណ្ឌលនីតិសម្បទា

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទា និងបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយជាជនសុចរិតដែលមានប្រយោជន៍ដល់សង្គម ដូច្នេះការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាត្រូវបែងចែកឲ្យដាច់ពីគ្នារវាងអនីតិជនដែលត្រូវឃុំខ្លួនជាបណ្តោះអាសន្នអនីតិជនដែលត្រូវទទទួលកម្មវិធីស្តារនីតិសម្បទា និងផ្នែកម្រាប់ត្រៀមដោះលែង។ ដោយយោងតាមមាត្រា **៧៧** ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងថា អនីតិជនត្រូវបានបែងចែកជា **៣** ផ្នែកដាច់ដោយឡែកពីគ្នា៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន។
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា។
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ដែលត្រូវជាប់ឃុំត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[93]

## ៥.ការថែទាំអនីតិជនក្នុងមណ្ឌលនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលយុវនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចជា៖

- ការការពារ ការថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាក់ពីការងារ
- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប

[93] មាត្រា ៧៧ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងជនជាប់ឃុំជាអនីតិជន ព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពីការភាពផ្នែកកាយសម្បទា ឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងៗទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឱ្យមានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនិងជួយអនីតិជនក្នុងការអភិវឌ្ឍសក្តានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយឱ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង[94]។

## ផ្នែកទី៣.សិទ្ធិទទួលបានការដោះលែង ការផ្តល់ ការមាននីតិសម្បទាឡើងវិញ

បន្ទាប់ពីអនីតិជនបានអនុវត្តទោសនៅក្នុងពន្ធនាគារ ឬបានទទួលរងទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទាចប់សព្វគ្រប់ហើយនោះ ឬអាជ្ញាយុកាលនៃទោសត្រូវបានផុតច្បាប់បានផ្តល់ឲ្យអនីតិជននោះនូវការដោះលែងដោយមានលក្ខខណ្ឌ និងការផ្តល់ការស្តារនីតិសម្បទាឡើងវិញចំពោះអនីតិជនដែលបានប្រព្រឹត្តបទល្មើស ។

### ១.ការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌ អាចត្រូវបានផ្តល់ឲ្យអនីតិជនដែលទទួលរងទោសក្នុងមណ្ឌលនីតិសម្បទា ដើម្បីលើកឡើងឲ្យមានការដោះលែងដោយមានលក្ខខណ្ឌចំពោះអនីតិជនអាចយកមកអនុវត្តបានច្បាប់បានកំណត់ដោយឲ្យបុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌរួមមាន ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ ប្រធានមណ្ឌលឃុំនីតិសម្បទាភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ បេសកម្មការទូត ឬកុងស៊ុលបរទេស ក្នុងករណី អនីតិជនជាជនបរទេស[95]។ លើសពីនេះទៅទៀតគ្រប់ទណ្ឌិតជាអនីតិជនដែលទទួលរងទោសដាក់ពន្ធនាគារ អាចត្រូវបានដោះលេងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបង្ហាញឲ្យឃើញថា ខ្លួនមានការកែប្រែគំនិត និងមានកិរិមារយាទល្អក្នុងអំឡុងពេលដែលជាប់ឃុំអាចបញ្ជូនទៅក្នុងសង្គមវិញបាន ការដោះលែងដោយមានលក្ខខណ្ឌអាចផ្តល់ឲ្យទណ្ឌិតជាអនីតិជន ដែលទទួលរងទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទាដូចខាងក្រោម

១. ទណ្ឌិតវាអនីតិជនបានទទួលទោសចំនួនមួយភាគបីនៃទោសរបស់ខ្លួន ដែលតុលាការបានផ្តន្ទាទោស ប្រសិនបើទោសតិចជាង ឬស្មើ **១ (មួយ) ឆ្នាំ**

២. ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត[96]។

[94] មាត្រា ៨១ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[95] មាត្រា ៧៣ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[96] មាត្រា ៧២ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ២.នីតិវិធីក្នុងការដោះលែងដោយមានលក្ខខណ្ឌ

ការដោះលែងដោយមានលក្ខខណ្ឌនេះ ត្រូវផ្តល់ដោយប្រធានតុលាការជាន់ដំបូង ប្រធានតុលាការនេះសម្រេចក្រោយពីបានទទួលយោបល់ពីគណៈកម្មការជាតិដែលត្រូវប្រជុំនៅក្រសួងយុត្តិធម៌។ គណៈកម្មការជាតិរួមមាន៖ សមាជិក **២ (ពីរ) រូប** ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែល **១ (មួយ)** រូបជាប្រធាន និងប្រធានពន្ធនាគារ ឬតំណាងជាសមាជិក។ ក្រោយពីបានទទួលពាក្យសុំដោះលែងដោយមានលក្ខខណ្ឌ ប្រធានតុលាការជាប់ដំបូង ត្រូវបញ្ជូនទៅគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌនូវសំណុំឯកសាររួមមានជាអាទិ៍ នូវពាក្យសុំ សាលក្រម ឬសាលដីកាផ្តន្ទាទោស សាលក្រម ឬសាលដីកា (មួយ ឬច្រើន) ព្រឹត្តិបត្រលេខ១ នៃបញ្ជីថ្កោលទោស យោបល់ព្រះរាជអាជ្ញា និងគ្រប់លិខិតទាំងអស់ដែលមានប្រយោជន៍ដើម្បីពិនិត្យ និងផ្តល់យោបល់។ បន្ទាប់ពីបានពិនិត្យរួចគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌ បញ្ចេញយោបល់របស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត។ យោបល់នេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវធ្វើជូនទៅប្រធានតុលាការជាន់ដំបូងភ្លាម។ ប្រធានតុលាការជាន់ដំបូងមិនត្រូវជាប់ជំពាក់នឹងយោបល់របស់គណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌទេ បន្ទាប់ពីបានទទួលយោបល់ពីគណៈកម្មការជាតិដោះលែងដោយមានលក្ខខណ្ឌរួចមកប្រធានសាលាដំបូង ត្រូវចេញសេចក្តីសម្រេចតាមដីកាដោយមានសំអាងហេតុ។ សេចក្តីសម្រេចរបស់ប្រធានតុលាការនេះអាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល **៥ ថ្ងៃ**។ បណ្តឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញា នៃតុលាការសាមីតែប៉ុណ្ណោះ។ ប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តទេ រហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍។ ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាដោយមានសំអាងហេតុ និងមិនអាចតវ៉ាបានឡើយ។

## ៣.ការផ្តល់ និងការមាននីតិសម្បទាឡើងវិញ

បន្ទាប់ពីអនីតិជនបានអនុវត្តទោសចប់សព្វគ្រប់ហើយ ឬនៅពេលដែលអាជ្ញាយុកាលនៃទោសត្រូវបានផុតរលត់ច្បាប់បានកំណត់ឲ្យមានការស្តារនីតិសម្បទាឡើងវិញចំពោះអនីតិជន ដែលក្នុងនោះរួមមាន ការផ្តល់នីតិសម្បទាឡើងវិញដោយតុលាការ និងការផ្តល់នីតិសម្បទាឡើងវិញដោយពេញលក្ខណៈច្បាប់។

- ***<u>ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ</u>***

ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការអាចត្រូវបានផ្តល់ឲ្យ ឬមិនផ្តល់ឲ្យដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ដោយយោងតាមច្បាប់ស្តីពីយុតិធម៌អនីតិជនមាត្រា **៧៤** បានចែងថា ពាក្យសុំឲ្យមានការផ្តល់ នីតិសម្បទាឡើងវិញ អាចដាក់ចូលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យ បានដោយទណ្ឌិតជាអនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់។ អាចដាក់ពាក្យស្នើសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការបាន លុះត្រាតែពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាផុតរយពេលដូចតទៅ៖

– ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

– ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម

– ១ (មួយ) ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល[97]។ លើសពីនេះតោទៀតការមិនបង់ប្រាក់ពិន័យ ប្រាក់ពាក់ពន្ធនឹងនីតិវិធី ឬសំណងនៃការខូចខាតវាមិនមែនជាឧបសគ្គក្នុងការឲ្យមាននីតិសម្បទាឡើងវិញចំពោះអនីតិជននោះទេ ប្រសិនបើទណ្ឌិតចាអនីតិជននោះមានភស្តុតាងបានបង្ហាញឲ្យឃើញថាខ្លួនស្ថិតនៅភាពអសាធនី[98]។ ទណ្ឌិតជាអនីតិជន ឬមេធាវី ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដីដោយត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅតាំងពីពេលដែលខ្លួនបានដោះលែងឲ្យមានសេរីភាពវិញ[99] បន្ទាប់ពីព្រះរាជអាជ្ញាបានទទួលពាក្យសុំរួចហើយ ព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាបជាមួយតៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[100]។

- **<u>ការមាននីតិសម្បទាឡើងវិញដោយពេលលក្ខណៈច្បាប់</u>**

យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងថា ការមាននីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់នៅពេលផុតរយៈពេលកំណត់ដូចខាងក្រោម

– ៣ (បី) ឆ្នាំ ចំពោះបទឧក្រិដ្ឋ

– ១ (មួយ) ឆ្នាំ ចំពោះបទមជ្ឈិម

– ៣ (បី) ខែ ចំពោះបទលហុ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវផុតអាជ្ញាយុកាល[101]។ ដូចនេះអនីតិជនដែលទទួលបាននីតិសម្បទាឡើងវិញ ត្រូវលុបលាងចោលទោសទណ្ឌកម្មទាំងអស់ ហើយត្រូវបានគេលុបឈ្មោះចេញពីបញ្ជីថ្កោលទោសកំណត់ហេតុ និងសំណុំរឿងដែលទាក់ទងជាមួយអនីតិជនត្រូវទុកជាការសម្ងាត់។

[97] មាត្រា ៧៤ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[98] មាត្រា៥៣៦ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[99] មាត្រា៥៣៧ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[100] មាត្រា៥៣៨ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[101] មាត្រា ៧៥ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# ជំពូកទី៣
# ផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិជនជាប់ចោទ

# ជំពូកទី៣

# ផលប៉ះពាល់ក្នុងការមិនគោរពសិទ្ធិជនជាប់ចោទ

សិទ្ធិគឺជាតម្រូវការចំបាច់មួយ ដែលមនុស្សម្នាក់ត្រូវការឲ្យមានជាចំបាច់ដើម្បីប្រើប្រាស់ក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងគ្រប់ស្ថានភាពទាំងអស់។ នៅក្នុងព្រះរាជាណាចក្រកម្ពុជា សិទ្ធិត្រូវបានបញ្ញត្តិការពារដោយបទដ្ឋានគតិយុត្តិជាច្រើនដែលក្នុងនោះមានទាំងបទដ្ឋានគតិយុត្តជាតិ និងបទដ្ឋានគតិយុត្តិអន្តរជាតិផងដែរ មិនតែបុណ្ណោះសូម្បីតែនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាបទបញ្ញត្តិកំពូលក៏បានចែងនូវមាត្រាជាច្រើនដែលបានធ្វើការការពារសិទ្ធិទៅកាន់ប្រជាពលរដ្ឋក៏ដូចជាបុគ្គលម្នាក់ៗ ដោយប្រើប្រាស់សិទ្ធិនោះឲ្យស្របទៅតាមច្បាប់។ ក៏ប៉ុន្តែបើទោះបីជាមាននូវបទដ្ឋានគតិយុត្តស្ដីអំពីសិទ្ធិជាច្រើនហើយក្ដីបើគ្មានការចូលរួមអនុវត្តទេនោះភាពអយុត្តិធម៌ងាយអាចនឹងកើតឡើងខ្លាំងណាស់ តួយ៉ាងបើក្រឡេកទៅកាន់នៅក្នុង វិស័យច្បាប់ដែលស្ដីអំពីសិទ្ធិការពារជនទាំងឡាយនៅពេលប្រព្រឹត្តបទល្មើសវិញ បុគ្គលម្នាក់ៗត្រូវតែមានសិទ្ធិ មិនថាជននោះស្ថិតនៅក្នុងស្ថានភាពជាជនសង្ស័យ ជនល្មើស ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន ឬទណ្ឌិតក្តីក៏ច្បាប់ត្រូវតែការពារចំពោះបុគ្គលទាំងនោះមឲ្យស្របទៅតាមការបញ្ញត្តិច្បាប់។ ការចូលរួមពីសំណាក់អ្នកអនុវត្តច្បាប់ព្រមទាំងស្ថាប័នទាំងឡាយនៅក្នុងប្រទេសពិតជាមានសារៈសំខាន់ណាស់ ព្រោះថាបើមានតែច្បាប់ហើយមិនមានការអនុវត្តនោះក៏ច្បាប់នោះពុំមានអត្ថន័យអ្វីដែរ ព្រមទាំងជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់បុគ្គល ក្រុមគ្រួសារ និងសង្គមថែមទៀតផង បញ្ហាទាំងអស់នេះយើងនឹងលើកយកមកបកស្រាយនៅក្នុងអត្ថបទខាងក្រោម។

## ១.មិនទទួលបាននូវភាពយុត្តិធម៌

ជាការពិតណាស់ សិទ្ធិត្រូវបានស្គាល់ថាគឺជាចំណុចផ្ដើមនៃឫសគល់នៃយុត្តិធម៌ ដូច្នេះការអនុវត្តសិទ្ធិពេញលេញជាកាតព្វកិច្ចចាំបាច់ដែលច្បាប់ព្រមទាំងអ្នកអនុវត្តច្បាប់ត្រូវតែអនុវត្ត និងការពារឲ្យបានខ្ជាប់ខ្ជួន។ ព្រោះនៅក្នុងដំណាក់កាលនីមួយៗ នៃនីតិវិធីច្បាប់រួមទាំងបទដ្ឋានគតិយុត្តិជាច្រើនបានបញ្ញត្តិដោយផ្ដល់សិទ្ធិឲ្យប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ស្របទៅតាមមាត្រា ៣១ នៃរដ្ឋធន្មនុញ្ញ[102] ប្រជាពលរដ្ឋទាំងអស់ត្រូវមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដែលក្នុងនោះមានន័យថាជនគ្រប់រូបក្នុងប្រទេសកម្ពុជាត្រូវតែទទួលបានដំណោះស្រាយ និងយុត្តិធម៌យ៉ាងពេញលេញចំពោះមុខច្បាប់ហើយនៅក្នុងមាត្រានោះក៏បញ្ជាក់បន្ថែមនូវការអនុញ្ញាតឲ្យជនគ្រប់ប្រើប្រាស់នូវសិទ្ធិផ្ទាល់ខ្លួនផងដែរ។ ជាក់ស្ដែងជនជាប់ចោទដែលបន្តនីតិវិធីនៅ

[102] មាត្រា ៣១ រដ្ឋធម្មនុញ្ញ នៃព្រះរាជណាចក្រកម្ពុជា ១៩៩៣

ក្នុងដំណាក់កាលស៊ើបសួររហូតដល់ដំណាក់ជំនុំជម្រះ និងទទួលការអនុវត្តទោស ប្រសិនបើកំឡុងពេលនោះការអនុវត្តសិទ្ធិណាមួយត្រូវបានរំលង ឬបំពាននោះភាពអាក់អួលនៅក្នុងវិស័យយុត្តិធម៌ក៏កើតមានឡើងហើយក៏ជាបញ្ហាដ៏ធំដែលជះឥទ្ធិពលទៅជនដែលរងការចោទប្រកាន់ផងដែរ ឧទាហរណ៍ដូចជាសិទ្ធិ សន្មត់ថាគ្មានទោសដែលស្របទៅនឹងច្បាប់កំពូលកម្ពុជាគឺ រដ្ឋធម្មនុញ្ញត្រង់មាត្រា **៣៨** ដែលបានធានានូវភាពគ្មានទោសរបស់ជនជាប់ចោទទាំងអស់រហូតមានសេចក្តីសម្រេចមួយ ដែលចេញដោយបញ្ជាក់ថាជននោះពិតជាមានទោស ដែលចំណុចនេះអាចបញ្ជាក់បានថាជនជាប់ចោទ គឺជាជនមួយដែលត្រូវតែចាត់ទុកថាពុំមានទោសដោយក្នុងកំឡុងមុនពេលសាលក្រមចូលជាស្ថាពរ គេត្រូវរកភាពពិតនៃរឿងក្តីមកបញ្ជាក់នៅក្នុងសាលក្រម ឬសាលដីកាសិនទើបអាចចាត់ទុកថាជាននោះមានទោស ឬបានប្រព្រឹត្តនៅបទល្មើសពិតមែន[103]។ ករណីនេះបើសិនជានៅក្នុងកំឡុងពេលនោះគាត់ពុំបានទទួលបានសិទ្ធិនោះទេការប៉ះពាល់ គឺអាចនឹងជះ ឥទ្ធិពលខ្លាំងទៅកាន់បុគ្គលដែលជាជនជាប់ចោទនោះ តួយ៉ាងដូចជាការឃុំខ្លួននៅក្នុងច្បាប់ស្តីពីពន្ធនាគារមាត្រា **២៦** ក៏បានការពារនូវជនដែលមានឋានៈជាជនជាប់ចោទនេះ គឺត្រូវដាក់ដោយឡែកពីទណ្ឌិត[104] ប្រសិនពុំទទួលបានការអនុវត្តបែបនេះទេនោះវានឹងនាំឲ្យមានការបំពាននូវ សិទ្ធិសន្មត់ថាគ្មានទោសកើតឡើង។ ដូចគ្នាផងដែរ នៅពេលដែលដល់កាលបរិច្ឆេទឲ្យនាំជនជាប់ចោទទៅកាន់សវនាការនោះការប្រើប្រាស់ឯកសណ្ឋាន គឺជារឿងមួយដែលចាំបាច់ប្រសិនបើជននោះត្រូវបានប្រើប្រាស់ឯកសណ្ឋានដូចទណ្ឌិត ដែលនោះជាការសន្មត់ថាគ្មានទោសក៏ត្រូវបានរំលោភបំពានផងដែរ ព្រោះថានីតិវិធីនៃការជុំនុំជម្រះត្រូវធ្វើជាសារធារណៈបើជាប់ចោទបានប្រើប្រាស់ឯកសណ្ឋានដូចទណ្ឌិតនោះវាហាក់ដូចជាជននោះគឺជាអ្នកមានទោសរួចទៅហើយ។

### ២.ខាតបង់ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ

ក្នុងឃាត់ខ្លួន ការចាប់ខ្លួន ការឃុំខ្លួនសុទ្ធតែជានីតិវិធីដែលនាំឲ្យបុគ្គលម្នាក់បាត់បង់នូវសេរីភាពរបស់ខ្លួនហើយនៅពេលបុគ្គលនោះបានជាប់ពាក្យព័ន្ធនាំឲ្យបាត់បង់សេរីភាពខ្លួននោះ តើជីវភាពប្រកបរបរប្រចាំថ្ងៃខាតបង់ឬទេ? កត្តានេះហើយទើបការអនុវត្តច្បាប់នៅក្នុងនីតិវិធីនីមួយៗ ត្រូវតែផ្តល់សិទ្ធិទៅកាន់បុគ្គលដែលជាជនជាប់ចោទឲ្យបានគ្រប់សិទ្ធិដែលបុគ្គលនោះមាន ព្រោះថាវាជារឿងមួយដែលគួរឲ្យព្រួយបារម្ភណាស់នៅពេលដែលបុគ្គលម្នាក់កំពុងធ្វើការសិក្សា ឬរកស៊ីជួញដូរផ្សេងៗសម្រាប់ជីវភាពប្រចាំថ្ងៃហើយត្រូវបានខកខាន ឬបាត់បង់ក្នុងរយៈពេលនោះ តើការខាតបង់នោះមានទំហំប៉ុនណាហើយអ្នកណាជាអ្នកទទួលខុសត្រូវ? នៅពេលដែលការ

[103] មាត្រា ៣៨ រដ្ឋធម្មនុញ្ញ នៃព្រះរាជណាចក្រកម្ពុជា ១៩៩៣

[104] មាត្រា ២៦ ច្បាប់ស្តីពីពន្ធនាគារ ឆ្នាំ២០១១

រកឃើញថាគាត់គ្មានកំហុសត្រូវបានរំលោភបំពានសិទ្ធិ ហេតុនេះហើយក្នុងការអនុវត្តសិទ្ធិមុននឹងសម្រេចថាធ្វើការដកហូតសរីភាពពីនរណាម្នាក់ពិតជាសំខាន់ណាស់ ដែលត្រូវតែតម្រូវឲ្យអ្នកអនុវត្តត្រូវតែគោរពតាមបទដ្ឋានគតិយុត្តិជាចាំបាច់។ ជាក់ស្តែងដូចជានីតិវិធីឃុំខ្លួនបណ្តោះអាសន្ន ដែលជាគោលការណ៍ប្រសិនបើជនណាម្នាក់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌដែលបានកំណត់នោះ គឺត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន ដែលបានន័យថាត្រូវបានបាត់បង់សេរីភាពរហូតនីតិវិធីជំនុំជម្រះមកដល់ ដូចនេះថាក្នុងកំឡុងពេលនោះតើជននេះត្រូវខាតបង់ប៉ុណ្ណាចំពោះជីវភាពរស់នៅប្រចាំថ្ងៃរបស់គាត់ ម្យ៉ាងទៀតបើសិនការអនុវត្តសិទ្ធិរបស់គាត់នៅក្នុងកំឡុងពេលនោះត្រូវបានបំពាន តើផលប៉ះពាល់នោះនឹងមានទំហំកាន់តែធំ ហើយជះឥទ្ធិពលទៅកាន់គ្រួសារទៀតផង។

## ៣.បាត់បង់សេរីភាព

សេរីភាព គឺជាសិទ្ធិមួយដែលធំធេងណាស់ក្នុងជីវិតមនុស្សម្នាក់ៗហើយការបំពេញកិច្ចការស្ទើតែគ្រប់បែបយ៉ាងក្នុងជីវិតមនុស្ស គឺត្រូវការសេរីភាពក្នុងការបំពេញនូវកិច្ចការរបស់ខ្លួន ដូចនេះប្រសិនបើជនម្នាក់ត្រូវបានបាត់បង់នូវសិទ្ធិសេរីភាពវាពិតជាមានផលពិបាកណាស់ក្នុងការប្រើប្រាស់ជីវិតខ្លួន។ នៅក្នុងប្រទេសកម្ពុជា សិទ្ធិសេរីភាពត្រូវបានធានាដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ប្រទេសកម្ពុជា ដែលផ្តល់សិទ្ធិសេរីភាពយ៉ាងពេញលេញទៅដល់បុគ្គលគ្រប់រូប។ ប៉ុន្តែនៅក្នុងការអនុវត្តច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជាចំពោះជនណាដែលប្រព្រឹត្តបទល្មើស នោះក៏ត្រូវតែតម្រូវឲ្យមានការដកហូតសិទ្ធិសេរីភាពមួយចំនួនរបស់ជនទាំងនោះផងដែរ។ ទន្ទឹមនឹងនេះនៅក្នុងការអនុវត្តទោសជាទណ្ឌកម្ម ដែលបុគ្គលជាទណ្ឌិតត្រូវទទួលខុសត្រូវវាស្របទៅនឹងគោលណ៍គំនិតនៃការបញ្ញត្តិទាក់ទងនឹងមូលទោសនៅក្នុងក្រមព្រហ្មទណ្ឌផងដែរ ជាទូទៅមូលទោសជាទោសមួយត្រូវបានសម្រេចដាក់ពន្ធនាគារ ឬពិន័យជាប្រាក់ទៅលើជនទាំងឡាយដែលត្រូវបានប្រកាសសាលក្រមដោយចៅក្រមដោយថាជននោះពិតជាបានប្រព្រិត្តបទល្មើស ហើយចំពោះការដាក់ទណ្ឌកម្មដោយការដកហូតសេរីភាពជាទូទៅត្រូវបានប្រើប្រាស់ទៅតាមលំដាប់ថ្នាក់នៃបទល្មើសដែលអាចជាបទឧក្រិដ្ឋ ឬមជ្ឈិមជាដើម។ យ៉ាងណាមិញការដាក់ទណ្ឌកម្មបែបនេះ គឺជាកត្តាចម្បងក្នុងការអនុញ្ញាតឲ្យជនដែលត្រូវទទួលទណ្ឌ កម្មនោះបានអនុវត្តនូវសិទ្ធិខ្លួននៅមុនពេលដែលខ្លួនបានទទួលកាដកហូតនូវសិទ្ធិសេរីភាពនោះ ព្រោះថានៅមុនការជំនុំជម្រះជនទាំងនោះគម្បីទទួលបាននូវ សិទ្ធិការពារពេញលេញឲ្យសមស្របទៅនឹងការអនុវត្តនៅក្នុងដំណាក់កាលនីតិវិធី ដោយហេតុក្រោយពេលដែលសាលក្រមចូលជាស្ថាពររួចគាត់នឹងត្រូវបានបាត់បង់ទាំង ស្រុងនូវសេរីភាពនៅក្នុងការប្រើប្រាស់ជីវិតនៅក្នុងសង្គមរបស់គាត់។

### ៤.ទទួលនូវបញ្ហាផ្លូវចិត្ត និងរូបរាងកាយ

កម្ពុជាបច្ចុប្បន្នបានធ្វើការលុបចោលទាំងស្រុងនូវការប្រើប្រាស់អំពើហិង្សា និងការធ្វើទារុណចំពោះជនជាប់ចោទ ឬក៏ជាទណ្ឌិត។ ការប្រើប្រាស់អំពើបែបនេះ គឺពិតជាមានភាពប៉ះពាល់យ៉ាងខ្លាំងទៅកាន់បូរណ ភាពរូបរាងកាយរបស់បុគ្គលដែលមានឋានៈជាជនដែលត្រូវបានឃុំខ្លួន។ ព្រោះថាកាលដែលត្រូវបានធ្វើនូវទារុណ ឬក៏ការប៉ះពាល់ផ្សេងៗនៃរូបរាងកាយដែលមានរូបភាពជាអំពើហិង្សានោះ វាក៏អាចឈានទៅដល់ការប៉ះទង្គិចផ្នែកផ្លូវចិត្តផងដែរ ព្រមទាំងអាចធ្វើឲ្យជនទាំងនោះប្រឈមបញ្ហាមិនប្រក្រតីនៃសតិអារម្មណ៍នាពេលខាងមុខទៀតផង ។ ឧទាហរណ៍ ជនជាប់ឃុំម្នាក់ដែលទទួលរងការរំលោភបំពានក្នុងពន្ធនាគារ មានសិទ្ធិទទួលបានការការពារពីច្បាប់ព្រហ្មទណ្ឌដូចគ្នានឹងអ្នកទទួលរងការរំលោភបំពាននៅក្នុងទីសាធារណៈដែរ ពន្ធនាគារទាំងអស់គួរអនុវត្តជាទូទៅនៅពេលកើតមាន ឬមានការរំពឹងថានឹងកើតមានបទល្មើសធ្ងន់ធ្ងរដែលទាមទារឲ្យមានប្រព័ន្ធអង្កេតមួយដែលមានលក្ខណៈស្រដៀងគ្នានឹងប្រព័ន្ធអង្កេតប្រើប្រាស់ក្នុងសង្គមទូទៅ។ ក្នុងយុត្តាធិការមួយចំនួន ចៅក្រមឬអយ្យការ ត្រូវបានតតាំងឲ្យអនុវត្តតួនាទីនេះក្នុងពន្ធនាគារ ដោយឡែកក្នុងយុត្តាធិការមួយផ្សេងទៀត រដ្ឋអាជ្ញាឬនគរបាលស៊ីវិលទទួលបានព័ត៌មាន និងទទួលបានឱកាសសំរាប់ធ្វើការស៊ើបអង្កេតហាក់ដូចជាការអនុវត្តចំពោះបទល្មើសដែលបានកើតឡើងនៅក្រៅពន្ធនាគារអញ្ចឹងពេលខ្លះ ពន្ធនាការអាចកើតមានបទល្មើសធ្ងន់ធ្ងរដែលមិនចាំបាច់មានការស៊ើបអង្កេតពីសំណាក់អាជ្ញាធរស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ។ ឧទាហរណ៍នៃករណីនេះអាច នៅពេលដែលជាប់ឃុំម្នាក់ ត្រូវបានគេរកឃើញមានថ្នាំញៀនតិចតួចជាប់នឹងខ្លួនសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឬនៅពេលមានការបង្កបួសស្នាមកើតឡើងដែលមិនបង្កឲ្យអ្នកណាម្នាក់មានរបួសធ្ងន់ធ្ងរ។ ផ្ទុយទៅវិញនៅពេលមានការបង្កបួសស្នាមដោយសារអាវុធ ឬធ្វើឲ្យមានរបួសស្នាមរហូតដល់បាក់ឆ្អឹង ឬអវយវៈណាមួយបញ្ហានេះជាធម្មតាត្រូវមានអន្តរាគមន៍ក្នុងការស៊ើបអង្កេតពីរដ្ឋអាជ្ញា ឬនគរបាល។ មធ្យោបាយមួយក្នុងការដោះស្រាយបញ្ហាទាំងនេះ គឺអាជ្ញាធរពន្ធនាគារ និងអាជ្ញាធរស៊ើបអង្កេតគួរមានការឯកភាពគ្នាលើគោលនយោបាយមួយពាក់ព័ន្ធនឹងបទល្មើសណាមួយ ដែលតម្រូវឲ្យមានអន្តរាគមន៍ស៊ើបអង្កេតពីរដ្ឋអាជ្ញា ឬនរគបាល។ម្យ៉ាងទៀតការធានានូវការហាមឃាត់ចំពោះការប្រើប្រាស់អំពើហិង្សានេះក៏ត្រូវបានច្បាប់ដែលទាក់ទងរួមមានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាច្បាប់ស្តីពីពន្ធនាគារ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស។

### ៥.ប៉ះពាល់ដល់កិត្តិយសគ្រួសារ

វាជារឿងដែលពិបាកក្នុងការបង្កាចំពោះការទាប់ស្កាត់នូវការមើលងាយពីសង្គមទៅកាន់គ្រួសារ ដែលមានសមាជិកខ្លួនដែលបានប្រព្រឹត្តបទល្មើស។ ព្រោះថានៅពេលដែលសង្គមគ្រួសារបានទទួលនូវករណីដូច

ដែលបានលើកឡើងនោះកត្តាចម្បង គឺមជ្ឈដ្ឋានជុំវិញនឹងវាយតម្លៃមិនត្រឹមតែបុគ្គលអ្នកប្រព្រឹត្តប៉ុណ្ណោះទេតែអាចនឹងគ្របដណ្តប់ទៅកាន់គ្រួសារផងដែរ កិត្តយសគ្រួសារគឺសំខាន់ណាស់ហេតុនេះការការពារនូវអត្តសញ្ញាណរបស់ជនដែលជាអ្នកប្រព្រឹត្តបទល្មើសនោះគឺសំខាន់ណាស់ ព្រោះថាដរាបបុគ្គលម្នាក់ពុំទាន់ទទួលបាននូវសេចក្តីសម្រេចនោះ គឺយើងពុំអាចចាត់ទុកថាបុគ្គលនោះមានទោស ឬបានប្រព្រឹត្តបានឡើយលុះត្រាតែឆ្លងកាត់នូវនីតិវិធីជំនុំជម្រះដែលមានសាលក្រមត្រឹមត្រូវ និងយុត្តិធម៌ទើបអាចចាត់ទុកថាបុគ្គលនោះបានប្រព្រឹត្តនូវបទល្មើស។

### ៦.បែកបាក់គ្រួសារ និងបាត់បង់ប្រាក់ចំណូល

នៅពេលដែលជនម្នាក់បានប្រព្រឹត្តនូវបទល្មើសហើយ ត្រូវបានបាត់បង់នូវសេរីភាពខ្លួននោះជាបញ្ហាចោទដល់សំខាន់ដែលជះឥទ្ធិពលទៅគ្រួសារ ការបែកបាក់ជារឿងមួយដែលប្រឈមព្រោះការដកហូតសេរីភាពត្រូវអនុវត្តទោសនៅក្នុងពន្ធនាគារដែលជាហេតុនាំឱ្យជននោះត្រូវចាកចេញពីគ្រួសារ។ ដូចគ្នាផងដែរប្រសិន បើជនដែលត្រូវបានទទួលការដកហូតសេរីភាពនោះជាឪពុកឬម្តាយ ឬក៏ទាំងពីរនាក់ជួបករណីនេះនោះកូនៗដែលនៅក្នុងបន្ទុកនឹងក្លាយជាមនុស្សកំព្រាខ្វះភាពកក់ក្តៅ ព្រមទាំងពុំទទួលបាននូវការអប់រំពេញលេញដែលអាចជាបញ្ហាសម្រាប់អនាគតទៀតផង។ គួបផ្សំនឹងនោះប្រសិនបើជនដែលគេដកហូតសេរីភាពនោះជាអ្នកដែលរកប្រភពចំណូលប្រចាំថ្ងៃឲ្យគ្រួសារនោះបញ្ហានឹងប៉ះពាល់កាន់តែខ្លាំង ដោយហេតុថានៅក្នុងគ្រួសារនីមួយៗពុំអាចខ្វះចំណូលប្រចាំថ្ងៃបានឡើយ ព្រោះនៅក្នុងគ្រួសារត្រូវការចំណូលមកផ្គត់ផ្គង់ជាចាំបាច់មួយផ្នែកទៀតប្រសិនបើប្រភពចំណូលត្រូវបានបាត់បង់ ហើយបំណុលពុំទាន់ត្រូវបានដោះរួចនៅឡើយការបាត់បង់នូវទ្រព្យសម្បត្តនឹងកើតមាន។ ចំពោះបុគ្គលដែលជានិស្សិត ឬជាអ្នកដែលកំពុងសិក្សាបញ្ហាធំគឺបាត់បង់នូវឱកាសក្នុងការសិក្សាដែលនាំឲ្យជីវភាពនាពេលខាងមុខក៏ត្រូវជួបប្រទះជាមួយភាពលំបាកដោយមិនអាចមានជំនាញសម្រាប់ខ្លួនច្បាស់លាស់។ ការលើកឡើងទាំងនេះគឺជាផលលំបាកដែលបានមកពីការអនុវត្តសិទ្ធិពុំពេញលេញនៅក្នុងនីតិវិធីជាក់ស្តែងដូចជា ការបិទសិទ្ធិពុំឲ្យបង្ហាញនូវភស្តុបញ្ជាក់ដែលជាភាពអយុត្តិធម៌មួយនៅក្នុងការទទួលការការពារដោយច្បាប់។

### ៧.ទទួលបាននូវការរើសអើង

គ្រួសារដែលមានសមាជិករបស់ខ្លួនត្រូវបានជាប់ចោទពីបទល្មើសផ្សេងៗ នាពេលបច្ចុប្បន្នត្រូវបានប្រឈមជាច្រើនរូបចំពោះការរើសអើងដូចជា ការរើសអើងនៅក្នុងការងារ មុខរបរ និងដោយផ្តល់ភាពអនុគ្រោះទាបដោយសារចរិតលក្ខណៈជាក់លាក់ មូលហេតុនៃការរើសអើងគឺដោយសារតែការភ័យខ្លាចចំពោះបុគ្គលដែល

ចេញពីសង្គមនៃគ្រួសារនោះ ដែលជាហេតុដែលនាំឱ្យក្រុមគ្រួសារអ្នកដែលជាជនជាប់ចោទនោះពិបាកក្នុងការចូលទៅក្នុងសង្គម។ ចរិកលក្ខណៈការរើសអើងនេះក៏អាចអូសបន្លាយដែលទទួលតាមការអប់រំទៅកាន់កុមារនាំឱ្យកុមារបង្កើតការរើសអើសរវាងគ្នានឹងគ្នាដែលនេះក៏ជាបញ្ហាចំពោះកូនៗផងដែរ។ ការរើសអើងត្រូវបានហាមឃាត់និងប្រឆាំង ដោយច្បាប់រដ្ឋធម្មនុញ្ញ ព្រមទាំងបទដ្ឋានគតិយុត្តជាច្រើនដែលមានទាំងច្បាប់ជាតិនិងអន្តរជាតិដែលក្នុងនោះមានចែងជាច្រើនចំពោះបញ្ហារើសអើងនេះ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តីបរិបទនិងផ្នត់គំនិតរបស់មនុស្សពុំអាចហាមឃាត់បាននោះទេ គឺតែងតែគិតទៅកាន់ចំណុចអវិជ្ជមានរបស់បុគ្គលណាម្នាក់ៗដែលជាកត្តានាំឱ្យពុំមានភាពស្មើគ្នានៅក្នុងសង្គម។ ដូចនេះក្នុងនាមជាអ្នកអនុវត្តច្បាប់ម្នាក់គម្បីគាំពារនូវអ្វីដែលជាសិទ្ធិ ជាផលប្រយោជន៍ទៅកាន់ជនជាប់ចោទទាំងឡាយដើម្បីបញ្ជាសបាននូវអវិជ្ជមានបែបនេះទៅកាន់សង្គម និងទៅកាន់អនាគតផងដែរ។ម្បីបញ្ជាសបាននូវអវិជ្ជមានបែបនេះទៅកាន់សង្គម និងទៅកាន់អនាគតផងដែរ។

## ៨.ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះប្រទេសជាតិ

ការធានានូវការគោរពសិទ្ធិដែលស្របទៅនឹងគោលណ៍បំណងនៃលិទ្ធិប្រជាធិបតេយ្យ គឺត្រូវបានទទួលស្គាល់ដោយពិភពលោក និងអនុវត្តយ៉ាងមុតមាំនៅក្នុងបណ្តាប្រទេសមួយចំនួន។ ដោយឡែកចំពោះប្រទេសកម្ពុជាវិញការគោរពសិទ្ធិក៏មានភាពសមប្រកបផងដែរក៏ប៉ុន្តែ ក៏នៅមានចន្លោះខ្វះខាតមួយចំនួនផងដែរ ដែលវាជាកត្តាដ៏សំខាន់មួយយើងទាំងអស់គ្នាគួរយកចិត្តទុក្ខដាក់។ តួយ៉ាងដូចជាការគោរពសិទ្ធិរបស់ជនជាប់ចោទ នេះជាបញ្ហាដែលសិទ្ធិរបស់ជនទាំងនោះ គឺអាចមានភាពងាយស្រួលក្នុងការរំលោភបំពានជាខ្លាំង ហេតុនេះហើយជាកត្តាដែលនាំឲ្យមានការអនុវត្តផ្ទុយអំពីច្បាប់និងបទដ្ឋានគតិយុត្តិទាំងឡាយ រួមទាំងការធានាដោយអង្គការពិភពលោក នឹងបណ្តាប្រទេសមួយចំនួនដែលមានទំនាក់ទំនងស្និតរមួតជាមួយប្រទេសកម្ពុជា។ ដូចនេះនៅក្នុងករណីដែលគេឃើញថាការអនុវត្តសិទ្ធិត្រូវបានបំពាននោះវានឹងនាំឲ្យវិស័យសេដ្ឋកិច្ច ព្រមទាំងវិស័យជាច្រើនទៀតដែលមានទាក់ទងនឹងប្រទេសដទៃ ដែលជាដៃគូសហការនោះ គេនឹងមានភាពភ័យខ្លាចចំពោះទង្វើទាំងនោះ។ម្យ៉ាងទៀតនៅក្នុងការចុះផ្សាយពីចំណុចអវិជ្ជមានផ្សេងៗ ក៏ហាក់មានភាពទូលំទូលាយណាស់នៅក្នុងប្រព័ន្ធបណ្តាញសង្គមបច្ចុប្បន្នដែលនេះ គឺជាបញ្ហាប្រឈមមួយទៀតដែលជះឥទ្ធិពលយ៉ាងខ្លាំងទៅកាន់មុខមាត់ប្រទេសជាតិ មិនតែប៉ុណ្ណោះសូម្បីតែការផ្សារភ្ជាប់នូវវិស័យអភិវឌ្ឍផ្សេងៗ ដែលជាជំនួយមកកាន់ប្រទេស នោះក៏មានផលប៉ះពាល់ដែលអាចនាំឲ្យមានការផ្អាកនូវការផ្តល់ជំនួយជាដើម។ មួយវិញទៀតចំពោះបញ្ហាអនុវត្តសិទ្ធិដែលមានភាពមិនពេញលេញបែបនេះ ក៏ជះឥទ្ធិពលខ្លាំងដល់ការប្រកបរបរផ្សេងៗរបស់ប្រជាពលរដ្ឋនៅក្នុងបណ្តាលតំបន់ទេសចរណ៍ដែលមានភ្ញៀវទេសចរណ៍អន្តរជាតិ ដោយហេតុថាការព្រួយបារម្មណ៍ និងខ្លាចអរាទៅនឹងការ

អនុវត្តច្បាប់ដោយរំលោភបំពានក្នុងហេតុផលនេះប្រសិនបើមានការល្មើសច្បាប់ពីសំណាក់ជនបរទេស ការអនុវត្តសិទ្ធិដែលមាននៅក្នុងច្បាប់នីតិវិធីមិនត្រូវបានបំពេញ ហើយពត៌មានបានលេចដោយការចុះផ្សាយពត៌មានពីបណ្ដាស្ថាប័នអន្តរជាតិ នោះជាហេតុមួយដែលនាំឲ្យកិត្តយសប្រទេសធ្លាក់អន់ថយក្រោមពាក្យរិះគន់ពីអន្តរជាតិផងដែរ។ ដូចនេះយើងឃើញថាការយកចិត្តទុកដាក់ទៅកាន់ការគោរពសិទ្ធិវាជារឿងមួយដែលប្រទេសត្រូវយកចិត្តទុកដាក់ខ្លាំងណាស់ ព្រោះសិទ្ធិជាអ្វីៗដែលមនុស្សយើង ម្នាក់ៗមានតាំងពីពេលចាប់កំណើត ហើយវាសំខាន់ណាស់ចំពោះមនុស្សម្នាក់ៗដែលប្រើប្រាស់ជីវិតរស់នៅក្នុងសង្គមបច្ចុប្បន្ន ជាពិសេសនោះចំពោះជនជាប់ចោទ ដែលកំពុងស្ថិតនៅក្នុងការឃុំឃាំងនៅពន្ធនាគារវិញដែលត្រូវបាត់បងសេរីភាពហើយរងទុក្ខ ហើយពុំមានសមត្ថភាពក្នុងការប្រើប្រាស់សិទ្ធិពេញលេញដូចមនុស្សទូទៅឡើយសួរថា ប្រសិនបើសិទ្ធិពួកគេត្រូវបានបំពាននោះថែមទៀតនោះតើនឹងប្រឈមផលលំបាកក៏ដូចជាជះផលអវិជ្ជមានបែបណាខ្លះទៅកាន់ពួកគេ។

## ៩.បាត់បង់តម្លៃនៃច្បាប់ការពារសិទ្ធិ និងការចុះខ្សោយការអនុវត្តច្បាប់នៅក្នុងប្រទេសកម្ពុជា

ជនជាប់ចោទត្រូវបានផ្តល់សិទ្ធិដោយច្បាប់ និងបទដ្ឋានគតិយុត្តជាច្រើនដែលបានបញ្ញត្តិការពារសិទ្ធិដល់ជនទាំងនោះដែលក្នុងនោះរួមមាន ច្បាប់រដ្ឋធម្មនុញ្ញប្រទេសកម្ពុជា សេចក្ដីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិសញ្ញាអន្តរជាតិស្តីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិសញ្ញាអន្តរជាតិស្តីសិទ្ធិសង្គម និងសិទ្ធិវប្បធម៌ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌកម្ពុជា ច្បាប់ស្ដីពីពន្ធនាគារ។ ដែលច្បាប់ទាំងនេះសុទ្ធតែបានប្រើប្រាស់ និងទទួលស្គាល់ដោយប្រទេសកម្ពុជានៅក្នុងវិស័យនៃការផ្តល់យុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ ជាការពិតច្បាប់នីមួយៗគឺជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងក្នុងការតាក់តែង និងកែច្នៃរបស់ថ្នាក់ដឹកនាំ ដើម្បីឲ្យវិស័យយុត្តិធម៌កម្ពុជាមានការអភិវឌ្ឍន៍ក៏ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺស្ថាប័នដែលអនុវត្តច្បាប់ជាអ្នកប្រើប្រាស់ច្បាប់ទៅកាន់ប្រជាពលរដ្ឋ និងនៅជិតជនដែលបានប្រព្រឹត្តបទល្មើសបំផុតដូចនេះកត្តាដែលគួរព្រួយបារម្មណ៍មួយទៀតនោះ គឺការអនុវត្តប្រសិនបើការអនុវត្តមានចន្លោះ ឬមានការរំលោភបំពានសិទ្ធិដល់ជនដែលបានប្រព្រឹត្តបទល្មើស នោះច្បាប់ក៏អាចនឹងមានការខ្សត់ខ្សោយថយចុះនូវគុណតម្លៃ ការគោរពប្រត្តិបត្តិចំពោះច្បាប់ក៏កាន់តែមានការធ្លាក់ចុះផងដែរ។ មួយវិញទៀតនៅពេលដែលច្បាប់បញ្ញត្តិយ៉ាងច្បាស់ក៏ប៉ុន្តែពុំអនុវត្តឲ្យសមស្របនោះវាហាក់ដូចជាច្បាប់ដែលបានបញ្ញត្តិមកនោះ គ្រាន់តែជាក្រដាស់និងតួអក្សរដែលពុំមានអ្នកអើពើឡើយ ហេតុនេះហើយគុណតម្លៃនៃច្បាប់ក៏កាន់តែបាត់បង់ហើយការ អនុវត្តក៏កាន់តែចុះថយទៅ។ ជាក់ស្តែងដូចជាការលើកឡើងនៅក្នុងជំពូកទី១ អំពីសិទ្ធិទាំងឡាយដែលជនជាប់ចោទត្រូវទទួល ប្រសិនបើ

មានសិទ្ធិណាមួយត្រូវបានបំពាន តើនឹងមានបញ្ហាអ្វីខ្លះដែលនាំឲ្យជះឥទ្ធិពលអាក្រក់ដល់តម្លៃនៃច្បាប់។ ការបំពាននូវសិទ្ធិលើរូបរាងកាយទាំងនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីមិនថា ដំណាកាល់ឃាត់ខ្លួនសួរចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬការនាំទៅធ្វើការសាកសួរនៅក្នុងដំណាក់កាលអយ្យការ ព្រមទាំងនីតិនៃការឃុំខ្លួនជាបណ្ដោះអាសន្ន ក្នុងដំណាក់កាលចៅក្រមស៊ើបសួរផងដែរ ការហាមឃាត់ក្នុងការធ្វើទារុណកម្មត្រូវបានហាមឃាត់ដោយបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ ក៏យើងអាចសង្កេតតាមសារពត៌មាន ឬបណ្ដាញសង្គមផ្សេង ដែលមានរូបភាព និងសកម្មភាពក្នុងការប្រើប្រាស់អំពើហិង្សាពីសំណាក់អ្នកអនុវត្តច្បាប់ដែលសកម្មភាពទាំងនោះបានចែកចាយចេញទៅមិនថាក្នុងប្រទេសឬក្រៅប្រទេសដែលជាមូលហេតុមួយ ដែលគួរឲ្យព្រួយបារម្ភណ៍ពីគុណតម្លៃនៃច្បាប់នៅក្នុងប្រទេសយើង។

### ១០.ប្រជាពលរដ្ឋលែងជឿជាក់នៅលើប្រព័ន្ធតុលាការ

ស្ថាប័នតុលាការជាស្ថាប័នមួយដែលបង្កើតឡើងសម្រាប់ដោះស្រាយបញ្ហាវិវាទ និងរឿងក្ដីទាំងឡាយណាដែលកើតឡើងក្នុងប្រទេសកម្ពុជាផ្ទាល់ ដូច្នេះហើយទើបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងជាក់ច្បាស់អំពី ឯករាជ្យភាពរបស់អំណាចតុលាការ ដែលអំណាចតុលាការជាអំណាចឯករាជ្យ[105] ដើម្បីធានាឲ្យបាននូវ ភាពមិនលម្អៀង ការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ។ តែជាក់ស្ដែងនៅក្នុងពេលបច្ចុប្បន្នស្ថាប័នតុលាការពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញនៅភាពមិនលម្អៀង ការការពារសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋបានបានពេលលេញនៅឡើយទេ តួយ៉ាងក្នុងករណីបទល្មើសព្រហ្មទណ្ឌមួយចំនួនបានកើតឡើង តុលាការពុំបានផ្ដល់សិទ្ធិគ្រប់គ្រាន់ទៅឲ្យជនដែលត្រូវរងនូវការចោទប្រកាន់នោះទេ ក្នុងស្ថានភាពនេះហើយជាហេតុដែលធ្វើឲ្យប្រជាពលរដ្ឋខ្មែរលែងមានភាពជឿជាក់ និងទំនុកចិត្តទៅលើប្រព័ន្ធតុលាការអាចនាំឲ្យមានមតិសង្ស័យ និងក្ដីបារម្ភថាតុលាការជាស្ថាប័នមួយដែលមិនអាចដោះស្រាយបញ្ហាជម្លោះ និងរឿងក្ដីនានាជូនប្រជាពលរដ្ឋបានដោយយុត្តិធម៌។ ជានិច្ចកាលនីតិវិធីជាមូលដ្ឋានមិនទាន់អនុវត្តបានត្រឹមត្រូវនៅឡើយទេជាក់ស្ដែងទាក់ទងជាមួយការឃុំខ្លួនបណ្ដោះអាសន្នតែងតែកើតមានឡើង ចំពោះនីតិជនក្ដី អនីតិជនក្ដីដោយពុំមានគិតពិចារណាល្អិតល្អន់ និងស្វែងរកភស្តុតាងឲ្យបានគ្រប់គ្រាន់សម្រាបើការឃុំខ្លួននោះទេ នៅក្នុងច្បាប់ស្ដីពីយុត្តិធម៌អនីតិជនបានចែងថា ការឃុំខ្លួនអនីតិជនជាវិធានការចុងក្រោយបង្អស់[106]។ យ៉ាងណាក្ដីប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃមានការរីកចម្រើនគួរឲ្យកោតសរសើរពិតមែន ដែលរាជរដ្ឋាភិបាលកម្ពុជាក្រសួង

[105] មាត្រា ១២៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[106] មាត្រា ៣៩ ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

យុត្តិធម៌ ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានព្យាយាមកសាងនិងសម្របសម្រួលឲ្យមានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ការប្រឡងប្រជែង និងអប់រំដល់អ្នកជំនាន់ថ្មីប្រកប ដោយគុណភាព សមត្ថភាព និងសមត្ថភាពខាងវិជ្ជាជីវៈក្តី ក៏នៅក្នុងករណីមួយចំនួន កិត្យានុភាពរបស់ប្រព័ន្ធតុលាការមានការធ្លាក់ចុះ ដោយបុគ្គលមួយចំនួនដែលគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ដែលនាំឲ្យមានការចោទប្រកាន់ទៅលើប្រព័ន្ធតុលាការទាំងមូលថាមានការទទួលសំណូកប្រព្រឹត្តអំពើពុករលួយ ហេតុផលទាំងអស់នេះហើយដែលធ្វើឲ្យប្រជាពលរដ្ឋលែងមានភាពជឿជាក់ទៅលើប្រព័ន្ធតុលាការ ដោយយល់ឃើញថាតុលាការពុំអាចផ្តល់យុត្តិធម៌ឲ្យខ្លួនបាន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបមក យោងតាមការបកស្រាយប្រធានបទខាងលើ យើងឃើញថាតាមគោលការណ៍ច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ច្បាប់ស្តីពីពន្ធនាគារ ក៏ដូចជាច្បាប់អន្តរជាតិជាច្រើនទៀតបានផ្តល់នូវសិទ្ធិជាច្រើន ចាប់តាំងបីដំណាក់កាលនៃការចាប់ខ្លួនដំបូងរហូតដល់ដំណាក់កាលជំនុំជម្រះដោយច្បាប់ទាំងនោះបានថែងយ៉ាងយកចិត្តទុកដាក់អំពីសិទ្ធិជនជាប់ចោទ។ ជនជាប់ចោទទាំងអស់ ដែលត្រូវបានរងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌមួយត្រូវបានច្បាប់គាំពារឲ្យទទួលបាននូវសិទ្ធិមួយចំនួនដើម្បីការពារខ្លួនទៅតាមផ្លូវច្បាប់ និងការពារការពីរំលោភបំពានសិទ្ធិរបស់ពួកគេ ដោយប្រការណាមួយដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពក្នុងរយៈពេលនៃការឃុំខ្លួន។ ជនជាប់ជាប់ក៏ដូចជាបុគ្គលទូទៅដែរសុទ្ធតែត្រូវទទួលបានការការពារដោយច្បាប់ និងមានសិទ្ធិនៅក្នុងការរស់រានមានជីវិត ប៉ុន្តែគ្រាន់តែគ្មានសិទ្ធិសេរីភាពនៅក្នុងការដើរហើរទេ ពោលគឺសិទ្ធិមួយចំនួនធំត្រូវបានហាមឃាត់ដូចជា សិទ្ធិនៅក្នុងការធ្វើអាជីវកម្ម សិទ្ធិក្នុងការបញ្ចេញមតិជាដើម។ បើទោះបីជាសិទ្ធិរបស់ជនជាប់ចោទមួយចំនួនត្រូវបានច្បាប់ដកហូតជាបណ្តោះអាសន្នមែន ប៉ុន្តែក្នុងអំឡុងពេលដែលជនជាប់ចោទស្ថិតនៅក្នុងពន្ធនាគារក៏ត្រូវបានទទួលការការពារផ្នែកច្បាប់ អំពីសិទ្ធិរបស់ពួកគេផងដែរ។ ជាពិសេសជនជាប់ចោទជាស្ត្រីទន់ខ្សោយស្ត្រីដែលមានទារកនៅក្នុងផ្ទៃជនជាប់ឃុំដែលមានអាយុច្រើន មានសុខភាពទន់ខ្សោយ ឬមានជម្ងឺប្រចាំកាយជាដើមសុទ្ធតែត្រូវទទួលបានការយកចិត្តទុកដាក់ ក្នុងករណីប្រសិនបើច្បាប់មិនបានការពារសិទ្ធិទៅលើជនជាប់ចោទទាំងនោះទេ បុគ្គលទាំងនោះអាចងាយប្រឈមនិងការរំលោភបំពានសិទ្ធិ និងការរើសអើងសិទ្ធិយ៉ាងធ្ងន់ធ្ងរក្នុងអំឡុងពេលជាប់ឃុំ។ សរុបជាមួយមកចំពោះសិទ្ធិរបស់ជនជាប់ចោទជាផ្នែកមួយដែលសំខាន់របស់ជនដែលត្រូវបានតុលាការចេញសេចក្តីសម្រេចផ្តន្ទាទោសជាប់ពន្ធនាគារជាស្ថាពរ និងជនដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ជនជាប់ជាប់ទាំងអស់គឺមានសិទ្ធិទទួលបានការការពារសិទ្ធិមនុស្សគ្រប់កាលៈទេស និងគ្រប់ពេលវេលាដោយមិនប្រកាន់ភេទ ពណ៌សម្បុរ សាសនា ភាសា ជាតិសាសន៍ និងនិន្នាការនយោបាយអ្វីឡើង បើសិនពុំមានច្បាប់ការពារទៅលើជនទាំងនោះទេពួកគេទាំងនោះអាច និងត្រូវប្រឈមមុខខ្លាំងនឹងការរំលោភបំពានសិទ្ធិមនុស្សខ្លាំងដូចនៅសម័យកម្ពុជាប្រជាធិបតេយ្យនោះជាដើម ដែលមានការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដោយមិនមានច្បាប់ ឬអង្គការណាមួយអាចជួយការពារបានឡើយ។ សរុបមកទោះបីជាច្បាប់បានបញ្ញាតិផ្តល់ឲ្យជនជាប់ចោទនូងសិទ្ធិមួយចំនួននៅក្នុងរឿងព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែក្នុងគោលបំណងការធានាឲ្យបាននូវការអនុវត្តសិទ្ធិប្រព្រឹត្តិទៅដោយរលូន និងមិនមានករណីបំពាន **សិទ្ធិរបស់ជនចាប់ចោទ** ណាមួយត្រូវបានកើតឡើងក្នុងពេលដំណើរការវាពិតជាមិនអាចទៅរួចនោះទេ បច្ចុប្បន្នយើងឃើញថាការអនុវត្តនូវ **សិទ្ធិរបស់ជនជាប់ចោទ** នៅក្នុងរឿងក្តីព្រហ្មទណ្ឌហាក់នៅមានចម្លោះខ្វះខាត់ នឹងនៅមានភាពទន់ខ្សោយជាខ្លាំង ដោយសារតែនៅមានករណីមួយចំនួនមានការធ្វើ

ទារុណកម្ម ឬក៏អំពើហិង្សាទៅលើជនទាំងនោះ ឬការបង្ខំឲ្យឆ្លើយសារភាពជាដើម។ ដូចនេះជនជាប់ចោទទាំងអស់នោះនៅពេលដែលត្រូវបានមន្ត្រីនគរបាលឃាត់ខ្លួនត្រូវស្វែងរកមេធាវីមកការពារខ្លួនភ្លាម ដើម្បីធានាបាននូវសិទ្ធិរបស់ខ្លួនដែលមិនត្រូវបានអ្នកដទៃបំពាន។ ជាការពិតណាស់ប្រសិនបើការអនុវត្តមនុស្សប្រព្រឹត្តទៅបានយ៉ាងល្អនោះ ដោយគួបផ្សំជាមួយនឹងការមិនប្រព្រឹត្តនូវអំពើពុករលួយទៀតនោះ នោះប្រទេសកម្ពុជានឹងឈានទៅជាប្រទេសមួយដែលមាននីតិរដ្ឋពេញលេញ។

# អនុសាសន៍

# អនុសាសន៍

ដើម្បីចូលរួមចំណែកធ្វើឲ្យសារណារបស់យើងខ្ញុំ កាន់តែល្អ និងរឹតតែមានប្រសិទ្ធភាពខ្ពស់ឡើង ហើយអាចយកទៅអនុវត្តបាន យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- ពង្រឹងវិស័យអប់រំ ក្នុងគោលបំណងឲ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែខ្ស់អំពីច្បាប់ ហើយខ្លាចក្នុងការប្រព្រឹត្តនៅអំពើខុសច្បាប់ ក្នុងគោលបំណងដើម្បីកាត់បន្ថយនូវការប្រព្រឹត្តបទល្មើសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ធ្វើការផ្សព្វផ្សាយអំពីច្បាប់ អំពីសិទ្ធិ និងជាពិសេសក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ច្បាប់ស្តីពីពន្ធនាគារ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិសញ្ញាសអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាន នឹងច្បាប់ដទៃជាច្រើនទៀត ទៅដល់មន្ត្រីអ្នកអនុវត្តច្បាប់ អាជ្ញាធរមានសមត្ថកិច្ច ក៏ដូចជាប្រចាពលរដ្ឋចាដើម ដើម្បីចូលរួមឲ្យមានការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព។
- មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែលុបបំបាត់ចោលនូវអំពើពុករលួយ ដើម្បីធ្វើឲ្យមានការស៊ើបអង្កេតប្រព្រឹត្តទៅដោយភាពយុត្តិធម៌។
- មេធាវីការពារជនក្រីក្រ ក្នុងនាមជាអ្នកវិជ្ជាជីវៈច្បាប់ ត្រូវតែធានាឲ្យបាននូវការការពារសិទ្ធិរបស់ជនជាប់ចោទប្រកបដោយប្រសិទ្ធិភាព នៅពេលដែលខ្លួនបានទទួលការពារសិទ្ធិរបស់ជនជាប់ចោទហើយនោះ។
- ក្រសួងយុត្តិធម៌ គប្បីជួយសម្រួល និងផ្តល់ជាអនុសាសន៍ឲ្យបានច្រើនពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្នទៅលើជនជាប់ចោទ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ព្រោះកន្លមកស្ទើតែគ្រប់សំណុំរឿងទាំងអស់នៅដំណាក់កាលចៅក្រមស៊ើបសួរ តែងតែមានការឃុំខ្លួនបណ្តោះអាសន្ន ដែលជាហេតុធ្វើឲ្យមានការកកស្ទះសំណុំរឿង ជនជាប់ឃុំមានចំនួនច្រើននៅក្នុងពន្ធនាគារ។
- ប្រជាពលរដ្ឋមិនត្រូវយកអំណាចទឹកប្រាក់ ទៅសូកប៉ាន់ដល់អាជ្ញាធរមានសមត្ថកិច្ចនានា ដើម្បីជាមធ្យោបាយគេចខ្លួនបីការទទួលខុសត្រូវព្រហ្មទណ្ឌ ព្រោះវាបានបង្កឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។
- ស្ថាប័នតុលាការត្រូវតែចៀសឲ្យផុតពីការប្រព្រឹត្តនូវអំពើពុលរលួយ ដើម្បីកសាងនីតិរដ្ឋឲ្យមានប្រសិទ្ធភាពតទៅមុខទៀត ក៏ដូចជាការកាត់បន្ថយភាពអយុត្តិធម៌នៅក្នុងសង្គម។

# ឯកសារយោង

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត

### ក.អំពីរដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា សភាធម្មនុញ្ញអនុម័តថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

### ខ.អំពីក្រម

- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជណាចក្រកម្ពុជា ឆ្នាំ២០០៩

### គ.អំពីច្បាប់

- ច្បាប់ស្តីពីពន្ធនាគារ
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- ច្បាប់លក្ខន្តិកៈទីក្រុងរួមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះរាជអាជ្ញា

### ឃ.អំពីអនុសញ្ញា និងកតិកាសញ្ញា

- អនុសញ្ញាស្តីពីសិទ្ធកុមារ
- កតិសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- កតិសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិវប្បធម៌
- សេចក្តីប្រកាសជាសលកស្តីពីសិទ្ធិមនុស្ស

### ង.អំពីព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស ឆ្នាំ២០២១

### ច.អំពីសៀវភៅ

- សៀវភៅមុគ្គទេសក៍ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
- សេចក្តីពន្យល់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អវតក និងអន្តរជាតិសម្រាំង ឆ្នា២០១៤
- នីតិវិធីព្រហ្មទណ្ឌ រៀបរៀងដោយ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី សាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣។
- យុទ្ធសាស្ត្រគ្រប់គ្រងពន្ធនាគារតាមគោលការណ៍សិទ្ធិមនុស្ស

- វិធានអង្គការសហប្រជាជាតិស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តទៅលើជនជាប់ឃុំ (វិធាននៃលសាន់ ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# រដ្ឋធម្មនុញ្ញ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា



## ជំពូកទី ៣
## អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១**.-

*ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។*

*ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។*

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិត មិនត្រូវឲ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរ មិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឲ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរ ត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឲ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

**ជំពូកទី ៣**

**សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ**

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រងមិនឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរ មានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារសំណងជួសជុលការខូចខាត ដែលបណ្ដាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការធ្វើដំណើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ។ ប្រជាពលរដ្ឋខ្មែរ អាចចេញទៅតាំងទីលំនៅនៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន ។

ការរក្សាសិទ្ធិមិនឲ្យរំលោភលើលំនៅឋាន និងអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទ ត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារ វត្ថុ និងលើរូបបុគ្គល ត្រូវធ្វើឲ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្ដាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្ដាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.** -

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិ អំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់ ។

បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្ដីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឲ្យមានការបញ្ឈប់នារីពីការងារដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមាន

ការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឲ្យនារី ជាពិសេសនារីនៅជនបទ ដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឲ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតាដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ ជាពិសេស សិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឲ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩**.-

ប្រជាពលរដ្ឋខ្មែរគ្រប់រូប ត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិ ត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០**.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន ។

# ឧបសម្ព័ន្ធទី២

# ច្បាប់

# ស្ដីពី

# ពន្ធនាគារ

ROYAUME DU CAMBODGE
ROYAL

# ជំពូកទី ៧
# ការអប់រំ កែប្រែ ការបណ្តុះបណ្តាលវិជ្ជាជីវៈ
# និង ការស្តារនីតិសម្បទាទណ្ឌិត

**មាត្រា ៦៦.-**

ទណ្ឌិតត្រូវបានចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីអប់រំច្បាប់និងសីលធម៌សង្គម ដែលបានរៀបចំឡើងនៅតាមពន្ធនាគារ ។

**មាត្រា ៦៧.-**

ទណ្ឌិតត្រូវបានផ្តល់មធ្យោបាយដើម្បីចូលរួមកម្មវិធីសិក្សាចំណេះទូទៅ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ។

កម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈនៅក្នុងពន្ធនាគារ ត្រូវបានធ្វើសមាហរណកម្មជាមួយប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ជាតិ ។

ទណ្ឌិតជាអនីតិជនត្រូវបានយកចិត្តទុកដាក់ដោយឡែក ទាក់ទងនឹងតម្រូវការសិក្សាអប់រំ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារនីតិសម្បទា និងសមាហរណកម្មដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងអប់រំ យុវជន និងកីឡា ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវសហការជាមួយក្រសួងមហាផ្ទៃរៀបចំកម្មវិធី និងដំណើរការអនុវត្តកម្មវិធីសិក្សាអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិតនៅក្នុងពន្ធនាគារ ។

**មាត្រា ៦៨.-**

ទណ្ឌិតដែលមានកម្រិតសន្តិសុខទាប ហើយត្រូវបានវាយតម្លៃថា មានសមត្ថភាពកាយសម្បទា ត្រូវបានចាត់តាំងឲ្យធ្វើការងារពលកម្មប្រចាំថ្ងៃនៅក្នុងពន្ធនាគារ ឬការងារជាអត្ថប្រយោជន៍សម្រាប់សហគមន៍ និងផលប្រយោជន៍សាធារណៈ ឬចាត់តាំងឲ្យចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៦៩.-**

កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានរៀបចំឡើងនៅតាមពន្ធនាគារនីមួយៗ ដើម្បីផ្តល់ឱកាសឲ្យទណ្ឌិតមានសមត្ថភាពប្រកបមុខរបរចិញ្ចឹមជីវិត នៅពេលធ្វើសមាហរណកម្មចូលក្នុងសហគមន៍វិញ ។

**មាត្រា ៧០.-**

ទណ្ឌិតដែលចូលរួមក្នុងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវបានបំពាក់សម្ភារៈ និងឧបករណ៍ការពារសុវត្ថិភាពការងារ ក្នុងពេលបំពេញការងារ ។

**មាត្រា ៧១.-**

បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ មានសិទ្ធិចុះកិច្ចសន្យាជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គល ឬអង្គការជាតិ អន្តរជាតិដើម្បីបង្កើតការងារ

ROYAUME DU CAMBODGE

សម្រាប់កម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ និងមានសិទ្ធិចុះកិច្ចសន្យាលក់ផលិតផល ឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ។

**មាត្រា ៧២.-**

ការគ្រប់គ្រង និងការប្រើប្រាស់ប្រាក់ចំណូលដែលបានមកពីកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីគ្រប់គ្រងកម្មវិធីឧស្សាហកម្ម សិប្បកម្ម កសិកម្មពន្ធនាគារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៣.-**

មុនផុតរយៈពេលទទួលរងទោស ៦ (ប្រាំមួយ) ខែ ទណ្ឌិតត្រូវបានទទួលកម្មវិធីសមាហរណកម្មដែលរៀបចំដោយពន្ធនាគារ ដើម្បីឲ្យគេក្លាយជាពលរដ្ឋអាចរស់នៅក្នុងសង្គមជាតិនិងសហគមន៍មូលដ្ឋានបានល្អ ។

## ជំពូកទី ៨
## ការបន្ធូរបន្ថយទោស ការលើកលែងទោស និង ការដោះលែងទណ្ឌិត

**មាត្រា ៧៤.-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតគណៈកម្មការមួយដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅក្នុងពន្ធនាគារដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះ ត្រូវធ្វើបញ្ជីទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ តាមរយៈអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ជាប្រធាន
- តំណាងអង្គការអយ្យការអមសាលាដំបូងរាជធានី ខេត្ត ជាអនុប្រធាន
- ប្រធានក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគាររាជធានី ខេត្ត ជាអនុប្រធានអចិន្ត្រៃយ៍
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកអប់រំកែប្រែ ជាសមាជិក
- អនុប្រធានពន្ធនាគាររាជធានី ខេត្តទទួលបន្ទុកប្រតិបត្តិ ជាសមាជិក

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត ក្នុងរយៈពេលជាប់ឃុំនៅតាមមណ្ឌលអប់រំកែប្រែដែលស្ថិតក្នុងការគ្រប់គ្រងរបស់ខ្លួន ។ គណៈកម្មការនេះត្រូវធ្វើបញ្ជីឈ្មោះទណ្ឌិតដែលមានលក្ខណសម្បត្តិអាចស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស បញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ យ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពន្ធនាគារ | ជាប្រធាន |
| - តំណាងអង្គការអយ្យការអមសាលាដំបូងដែលមានសមត្ថកិច្ចលើមណ្ឌលអប់រំ កែប្រែសាមី | ជាអនុប្រធាន |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាអនុប្រធាន |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធាននាយកដ្ឋានអប់រំកែប្រែ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានប្រតិបត្តិ | ជាសមាជិក |
| - ប្រធានក្រុមការងារប្រឡងប្រណាំងនៃមណ្ឌលអប់រំកែប្រែនីមួយៗ | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៥.-**

រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មការថ្នាក់ជាតិមួយ ដើម្បីពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលបានផ្ញើមកពីគណៈកម្មការរាជធានី ខេត្ត និងពីគណៈកម្មការក្រសួងមហាផ្ទៃ ។ ក្រោយពីបានពិនិត្យវាយតម្លៃរួចហើយ គណៈកម្មការនេះត្រូវធ្វើបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃ មុនថ្ងៃកំណត់នៃពិធីបុណ្យនីមួយៗ ។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាប្រធាន |
| - រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកពន្ធនាគារ | ជាអនុប្រធានអចិន្ត្រៃយ៍ |
| - អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ជាអនុប្រធាន |
| - តំណាងក្រុមប្រឹក្សាអ្នកច្បាប់ ចំនួន ០១ រូប | ជាសមាជិក |
| - ប្រធានក្រុមប្រឹក្សានីតិកម្មនៃក្រសួងមហាផ្ទៃ | ជាសមាជិក |
| - តំណាងក្រសួងយុត្តិធម៌ ចំនួន០១ រូប | ជាសមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ | ជាសមាជិក |
| - ប្រធាននាយកដ្ឋានជំនាញនៃអគ្គនាយកដ្ឋានពន្ធនាគារ ចំនួន ០២ រូប | ជាសមាជិក |

គណៈកម្មការនេះអាចមានសមាសភាពមួយចំនួនទៀត តាមការចាំបាច់ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៧៦.-

លក្ខណសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំង សំដៅជំរុញលើកទឹកចិត្តដល់ទណ្ឌិតម្នាក់ៗឲ្យខិតខំកសាងកែប្រែគំនិតមារយាទ ក្លាយជាពលរដ្ឋល្អដើម្បីធ្វើសមាហរណកម្មបញ្ចូលទៅក្នុងសង្គមជាតិវិញបាននៅពេលអនាគត ត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែមិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា ៧៥ នៃច្បាប់នេះ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ ។

## មាត្រា ៧៧.-

ក្នុងករណីចាំបាច់ ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន ។

## មាត្រា ៧៨.-

ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោសនិងការលើកលែងទោសត្រូវកំណត់ដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE

**មាត្រា ៧៩.-**

គ្រប់ទណ្ឌិតដែលត្រូវទទួលទោសពន្ធនាគារមួយ ឬ ច្រើន អាចត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថា ខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន ។

លក្ខខណ្ឌ និងបែបបទនៃការអនុវត្តការដោះលែងដោយមានលក្ខខណ្ឌក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨០.-**

ប្រធានពន្ធនាគារត្រូវធ្វើការដោះលែងជនជាប់ឃុំ ក្រោយពីបានទទួលលិខិតសម្រេចពីអាជ្ញាធរតុលាការ ។ ជាគោលការណ៍ ទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យ ឬថ្ងៃឈប់សម្រាកផ្សេងទៀតដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់ ត្រូវតែដោះលែងឲ្យមានសេរីភាពវិញ នៅមុនថ្ងៃឈប់សម្រាកនោះ ស្របតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

# ឧបសម្ព័ន្ធទី៣

## ព្រះរាជក្រម

នស/រកម/០៧១៦/០០៩

## យើង

### ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
### សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
### ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
### ខេមរាស្ត្រពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ នាសម័យប្រជុំសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ជំពូកទី ១៣
## ការបង្កើត និងសមត្ថកិច្ចគ្រប់គ្រងមណ្ឌលយុវនីតិសម្បទា

### មាត្រា ៧៦.- ការបង្កើតមណ្ឌលយុវនីតិសម្បទា

ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន ។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

### មាត្រា ៧៧.- ការបែងចែកការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

ការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្ដារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

របបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### មាត្រា ៧៨.- បញ្ជីឈ្មោះអនីតិជន

គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព ។

បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

# ជំពូកទី ១៤
# វិធានការទាក់ទងនឹងការឃុំខ្លួនអនីតិជន

## មាត្រា ៧៩.- គោលបំណងនៃការឃុំខ្លួន

ការឃុំខ្លួនអនីតិជនធ្វើឡើងក្នុងគោលបំណងស្តារនីតិសម្បទា ជាអាទិ៍ ការបណ្តុះបណ្តាលការពារ ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយទៅជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។

មន្ត្រីមណ្ឌលយុវនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

## មាត្រា ៨០.- សិទ្ធិជាមូលដ្ឋានរបស់អនីតិជនដែលជាប់ឃុំ

អនីតិជនដែលជាប់ឃុំទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយកំណើអាហារ និងពលកម្មដោយបង្ខំ
- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្តីថ្លៃថ្នូររបស់អនីតិជន
- សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- សិទ្ធិផ្តល់ដំណឹងអំពីកាឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជំងឺ ឬរបួស និងផ្តល់ដំណឹងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ
- សិទ្ធិទទួលបានយន្តការបណ្តឹងប្រកបដោយប្រសិទ្ធភាព និងរក្សាការសម្ងាត់ទាក់ទងនឹងលក្ខខណ្ឌ និងការប្រព្រឹត្តមកលើខ្លួនក្នុងពេលឃុំខ្លួន
- សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តជាធរមាន ។

## មាត្រា ៨១.- សេវាសម្រាប់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកមណ្ឌលយុវនីតិសម្បទាទាំងអស់ ត្រូវផ្តល់សេវាដល់អនីតិជនដែលកំពុងជាប់ឃុំដូចខាងក្រោមនេះ ៖

- ការពារ ថែទាំ និងផ្តល់រាល់តម្រូវការចាំបាច់ផ្ទាល់ខ្លួនដោយស្របតាមបុគ្គលិកលក្ខណៈ ជំនឿ សាសនា ភេទ និងអាយុរបស់អនីតិជន
- ស្នាក់នៅជាក្រុម ឬជាឯកត្តបុគ្គល
- សិក្សាអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សិល្បៈ កីឡា កម្សាន្ត និងសម្រាកពីការងារ

- សុខភាពផ្លូវកាយនិងផ្លូវចិត្តសមស្រប
- ពិនិត្យវាយតម្លៃសុខភាពដោយមន្ទីរពេទ្យ ។ ត្រូវកត់បញ្ចូលទៅក្នុងសំណុំរឿងអនីតិជន ជាប់ឃុំនៃព័ត៌មានអំពីរបួសស្នាម ជំងឺផ្លូវចិត្ត ពិការភាពផ្នែកកាយសម្បទា ឬព័ត៌មាន ពាក់ព័ន្ធផ្សេងទៀត
- សេវាផ្សេងទៀតដែលលើកស្ទួយសុខភាពនិងមោទនភាពចំពោះខ្លួនឯង លើកទឹកចិត្តឲ្យ មានគំនិតទទួលខុសត្រូវ លើកទឹកចិត្តឲ្យមានអាកប្បកិរិយា និងជំនាញដែលនឹងជួយ អនីតិជនក្នុងការអភិវឌ្ឍសក្ដានុពលរបស់ខ្លួនក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម និងជួយ ឲ្យពួកគេវិលត្រឡប់មកក្នុងសង្គមវិញបន្ទាប់ពីបានដោះលែង ។

## មាត្រា ៨២.– ការរក្សាអនីតិជន

ត្រូវរក្សាអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាដូចខាងក្រោមនេះ ៖

- អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- នៅក្នុងអគារជាប់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។ អនីតិជនភេទស្រីត្រូវស្ថិត នៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា
- នៅក្នុងអគារជាប់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់ អនីតិជនដែលមានជំងឺឆ្លង ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន និងកំពុងអនុវត្ត ទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិសម្បទាបន្ត រហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ។ នៅពេលទណ្ឌិតឈានចូលអាយុគ្រប់ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរទៅអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន ។

បែបបទនិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរ ក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## មាត្រា ៨៣.– ចំណាត់ថ្នាក់សន្តិសុខនៅក្នុងមណ្ឌលយុវនីតិសម្បទា

ចំណាត់ថ្នាក់សន្តិសុខសម្រាប់អនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវស្ថិតក្នុងចំណាត់ ថ្នាក់ទាបបំផុត និងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៨៤.- ភ្នាក់ងារក្នុងមណ្ឌលឃុំឃាំងអនីតិជន

ភ្នាក់ងារទាំងអស់ដែលធ្វើការជាមួយអនីតិជននៅក្នុងមណ្ឌលឃុំឃាំងអនីតិជន ជាអាទិ៍ មន្ត្រីមណ្ឌលឃុំឃាំងអនីតិជន ភ្នាក់ងារសង្គមកិច្ច អ្នកជំនាញផ្នែកអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អ្នកពិគ្រោះយោបល់ និងបំណិនជីវិត និងអ្នកចិត្តសាស្ត្រ ឬគ្រូពេទ្យព្យាបាលជំងឺផ្លូវចិត្ត ត្រូវតែទទួលបាននូវការបណ្តុះ បណ្តាលត្រឹមត្រូវអំពីចិត្តសាស្ត្រកុមារ សុខុមាលភាពកុមារ និងបទដ្ឋានអន្តរជាតិស្តីពីសិទ្ធិកុមារ និងការប្រព្រឹត្តមកលើអនីតិជនដែលត្រូវបានដកហូតសេរីភាព ។

មន្ត្រី ឬបុគ្គលិកមណ្ឌលឃុំឃាំងអនីតិជន មិនត្រូវប្រើ ឬបញ្ជាជនដែលកំពុងជាប់ឃុំឲ្យដាក់វិន័យទៅលើអនីតិជន ឬធ្វើកិច្ចការជំនួសខ្លួនឡើយ ។

## មាត្រា ៨៥.- ការធ្វើអធិការកិច្ចមណ្ឌលឃុំឃាំងអនីតិជន

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលឃុំឃាំងអនីតិជន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។

យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនកិច្ចមណ្ឌលឃុំឃាំងអនីតិជនានាបានគ្រប់ពេលវេលា ។

# ឧបសម្ព័ន្ធទី៤

ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

## ស្តីពី

នស/រកត/០១២១/០៧០

## ការបន្ធូរបន្ថយទោស និងការលើកលែងទោស

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**ត្រាស់បង្គាប់**
**ជំពូកទី១**
**បទប្បញ្ញត្តិទូទៅ**

មាត្រា១.-

ព្រះរាជក្រឹត្យនេះកំណត់អំពីពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះឱ្យចូលទៅរួមរស់ក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌។

មាត្រា២.-

ព្រះរាជក្រឹត្យនេះមានវិសាលភាពគ្របដណ្ដប់ទៅលើការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិតទាំងអស់ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា និងចំពោះទណ្ឌិតដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារដោយតុលាការនៃបរទេស ប៉ុន្តែ ត្រូវបានបញ្ជូនមកឱ្យអនុវត្តទោសនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមការព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបរទេសនោះ។

ព្រះរាជក្រឹត្យនេះមិនអនុវត្តចំពោះការលើកលែងទោសឱ្យទណ្ឌិត ដូចមានបញ្ញត្តិក្នុងមាត្រា ៧៧ នៃច្បាប់ស្ដីពីពន្ធនាគារឡើយ។

## ជំពូកទី២

## ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោស

មាត្រា៣.-

ពិធីបុណ្យដែលអាចស្នើសុំការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ត្រូវកំណត់ ៥ (ប្រាំ) ដង ក្នុងមួយឆ្នាំ ដូចតទៅ៖

១-ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍។

២-ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ។

៣-ពិធីបុណ្យវិសាខបូជា។

៤-ពិធីបុណ្យឯករាជ្យជាតិ។

៥-ព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងសំពះព្រះខែ អកអំបុក។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើផងដែរក្នុងពិធីបុណ្យ ឬព្រឹត្តិការណ៍ធំៗរបស់ជាតិ។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពិធីបុណ្យនីមួយៗខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នា។

## ជំពូកទី៣

## លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

### ផ្នែកទី១

### លក្ខខណ្ឌទូទៅនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក[illegible]លបានការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាសិទ្ធិរបស់ទណ្ឌិតនោះទេ [illegible]លបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ អាចទទួលបានការ[illegible] ជាការបន្ធូរបន្ថយទោស ឬជាការលើកលែងទោសបាន។

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តបានតែចំពោះទណ្ឌិតដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារដោយសាលក្រម ឬសាលដីកាស្ថាពរប៉ុណ្ណោះ។

មាត្រា៥..

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តចំពោះទណ្ឌិតដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមារយាទឱ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំដទៃទៀត
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀងទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវ តាមសេចក្ដីណែនាំផ្សេងទៀតរបស់ពន្ធនាគារ។

ប្រធានពន្ធនាគារត្រូវធ្វើការវាយតម្លៃ និងបញ្ជាក់អំពីការបំពេញលក្ខខណ្ឌខាងលើរបស់ទណ្ឌិតដែលត្រូវបញ្ចូលឈ្មោះក្នុងបញ្ជីទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងវាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិត។

មាត្រា៦..

ការបន្ធូរបន្ថយទោស និងការលើកលែងទោស អាចអនុវត្តផងដែរក្នុងហេតុផលមនុស្សធម៌ចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។

ប្រធានពន្ធនាគារត្រូវធ្វើការបញ្ជាក់អំពីការបំពេញលក្ខខណ្ឌតាមស្ថានភាពនីមួយៗរបស់ទណ្ឌិតដូចមានចែងក្នុងកថាខណ្ឌខាងលើ ដើម្បីរៀបចំបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំទៅគណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ។

## ផ្នែកទី២

## លក្ខខណ្ឌដោយឡែកនៃការបន្ធូរបន្ថយទោស

មាត្រា៧..

ទណ្ឌិតដែលបានបំពេញលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា៥ នៃព្រះរាជក្រឹត្យនេះ អាចទទួលការបន្ធូរបន្ថយទោសបាន លុះត្រាតែទណ្ឌិតនោះបានទទួលរងទោស ១/៣ (មួយភាគបី) នៃទោសដាក់ពន្ធនាគារដែលតុលាការបានកំណត់។

ចំពោះទោសដាក់ពន្ធនាគារមួយជីវិត ទណ្ឌិតត្រូវទទួលរងទោស ១០ (ដប់) ឆ្នាំជាមុនសិន។

រយៈពេលនៃការបន្ធូរបន្ថយទោសត្រូវកំណត់ ដូចខាងក្រោម៖

១- ទោសដាក់ពន្ធនាគារកំណត់ពី ១ (មួយ) ឆ្នាំ ដល់ក្រោម ៥ (ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារចំនួន ៣ (បី) ខែ។

ទោស និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស យ៉ាងយឺតបំផុត ៣០ (សាមសិប)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យនេះ។

គំរូបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ត្រូវកំណត់ដោយគណៈកម្មការថ្នាក់ជាតិ។

### មាត្រា១២.-

ទណ្ឌិតដែលយល់ឃើញថា ខ្លួនបានបំពេញលក្ខខណ្ឌក្នុងការស្នើសុំបន្ធូរបន្ថយទោស ឬលើកលែងទោស ប៉ុន្តែ មិនត្រូវបានប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួន សាមីខ្លួន ឬអ្នកតំណាងស្របច្បាប់មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការថ្នាក់ជាតិ ដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។ ពាក្យបណ្តឹងតវ៉ានេះ ត្រូវដាក់នៅគណៈកម្មការថ្នាក់ជាតិ ដោយផ្ទាល់ ឬតាមរយៈប្រធានពន្ធនាគារ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ានេះ ប្រធានពន្ធនាគារត្រូវបញ្ជូនពាក្យប្តឹងនេះ មកគណៈកម្មការថ្នាក់ជាតិ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ពាក់ព័ន្ធនឹងការអនុវត្តទោសរបស់ទណ្ឌិតនោះ។

### មាត្រា១៣.-

គណៈកម្មការថ្នាក់ជាតិ ត្រូវប្រជុំពិនិត្យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស និងរៀបចំបែបបទជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដើម្បីដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត យ៉ាងយឺតបំផុត ១០ (ដប់)ថ្ងៃមុនថ្ងៃកំណត់ដូចមានចែងក្នុងមាត្រា៣ នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## ការអនុវត្តព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស

### មាត្រា១៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវរៀបចំសំណៅចែកផ្សាយជូនក្រសួងយុត្តិធម៌ដើម្បីចាត់ចែងអនុវត្ត ក្រោយពីបានទទួលព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស។

### មាត្រា១៥.-

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងលើកលែងទោស ទៅព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច ដើម្បីអនុវត្ត។

### មាត្រា១៦.-

ចំពោះទណ្ឌិតដែលត្រូវបានលើកលែងទោសដោយព្រះរាជក្រឹត្យ នឹងត្រូវដោះលែងឱ្យមាន[illegible]ភាព ដោយប្រធានពន្ធនាគារ បន្ទាប់ពីទទួលបានដីកាបង្គាប់ឱ្យដោះលែងទណ្ឌិតរបស់[illegible]អាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី ខេត្តដែលមានសមត្ថកិច្ច។

[illegible]ដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ លើកលែងឱ្យទណ្ឌិតនោះរួចផុតពីការអនុវត្ត[illegible]ប្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ។ ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង

រាជធានី ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយព្រះរាជក្រឹត្យបន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោស។

**មាត្រា១៧.-**

ការបន្ធូរបន្ថយទោស និងការលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយទោស និងលើកលែងទោសនោះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

ក្រឹត្យលេខ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៩.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ អង្គារ ១៤កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១២ ខែ មករា ឆ្នាំ២០២១

នសរ.០១២១.០៣២

**បានប្រថាប់ព្រះរាជលញ្ឆករហើយ**

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមនីតិវិធីព្រហ្មទណ្ឌ
# នៃ
# ព្រះរាជាណាចក្រកម្ពុជា



ឆ្នាំ ២០០៧

ក្រសួងយុត្តិធម៌

Ministère de la Justice

មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតម្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.** - បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.** - ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ជំពូកទី ៣
## ការឃាត់ខ្លួន

**មាត្រា ៩៦.** - ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

**មាត្រា ៩៧.** – កំណត់ហេតុស្តីពីការឃាត់ខ្លួន

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្តីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ ដោយមានចុះសេចក្តីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតស្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៨.** – ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ គាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

**មាត្រា ៩៩.** – ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះ សមស្របនឹងការឃាត់ខ្លួនដែរឬទេ ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យ

សមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ ។

ប្រសិនបើការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីជាតិទាំងមូល ។ ប៉ុន្តែ ចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ។

ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីប្រតិបត្តិការរបស់ខ្លួននេះ ។

**មាត្រា ១៣១.** – ដីកាចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរអាចសុំឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ១៣២.** – ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៣.** – ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងចិរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាង

សមត្ថកិច្ចដែនដីនៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាអំពីការចុះទៅពិនិត្យនេះ ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាអាចរួមដំណើរជាមួយចៅក្រមស៊ើបសួរនេះ ។

ប្រសិនបើការចាំបាច់នៃការស៊ើបសួរតម្រូវ នោះចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងជាមួយក្រឡាបញ្ជី នៅលើវិសាលភាពដែនដីជាតិទាំងមូល ។ ប៉ុន្តែ ចៅក្រមត្រូវជូនដំណឹងជាមុនដល់ព្រះរាជអាជ្ញាអមតុលាការជាន់ដំបូង នៅក្នុងដែនដីដែលខ្លួនធ្វើដំណើរទៅកាន់នោះ ។

ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្ដីពីប្រតិបត្តិការរបស់ខ្លួននេះ ។

**មាត្រា ១៣១.** - ដីកាចាត់ឱ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរអាចសុំឱ្យចៅក្រមផ្សេង ឬមន្ត្រីនគរបាលយុត្តិធម៌ ឬអង្គភាពនគរបាលយុត្តិធម៌ បំពេញកិច្ចខ្លះតាមដីកាចាត់ឱ្យស៊ើបសួរជំនួស នៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។

**មាត្រា ១៣២.** - ការស្នើសុំឱ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ។ ដីកានេះត្រូវមានសំអាងហេតុ ហើយត្រូវតែជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងថិរវេលាយ៉ាងឆាប់បំផុត ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្ដឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ១៣៣.** - ការស្នើសុំឱ្យបំពេញកិច្ចដោយជនត្រូវចោទ

នៅគ្រប់ពេលវេលានៃការស៊ើបសួរ ជនត្រូវចោទអាចសុំឱ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែង ។ ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះត្រូវចេញដីកាបដិសេធនៅក្នុងថិរវេលា ១ (មួយ) ខែ បន្ទាប់ពីពេលទទួលពាក្យសុំ ។ ដីកានេះត្រូវតែមានសំអាង

ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ១ (មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់ ។

**មាត្រា ២១១.** – ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចថាពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ ។ កាលណាជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្ដីរបស់ខ្លួន ។

ចៅក្រមស៊ើបសួរពន្យារការឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនេះ ។ ដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ ។

**មាត្រា ២១២.** – សេចក្ដីសម្រេចទាក់ទងនឹងអនីតិជនមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ

អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវឃុំខ្លួនបណ្ដោះអាសន្នទេ ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដីសម្រេចរបស់តុលាការ ។

**មាត្រា ២១៣.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជន មានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

**មាត្រា ២១៤.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជន មានអាយុ

ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និង ត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណា អនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណា អនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវ លើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

**មាត្រា ២០៥.** - ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រម ស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញា ពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ចៅក្រមស៊ើបសួរ សម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិន រង់ចាំយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

**មាត្រា ២០៦.** - ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញា អាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ ។

**មាត្រា ២០៧.** - ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រម ស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅ

ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និង ត្រូវចោទប្រកាន់ពីបទមជ្ឈិម ចិរវេលាឃុំខ្លួនបណ្តោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណា អនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណា អនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

**មាត្រា ២១៥.** – ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន ។

**មាត្រា ២១៦.** – ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ ។

**មាត្រា ២១៧.** – ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្តល់យោបល់ និងបញ្ជូនសំណុំរឿងទៅ

ចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ

ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និង ត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្ដោះអាសន្នមានដូចតទៅ :

១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណា អនីតិជននេះមានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។

២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណា អនីតិជននេះមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នតាមចំណុចទី ១ និងចំណុចទី ២ ខាងលើនេះ មិនត្រូវ លើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ ។

**មាត្រា ២០៥.** - ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា ។

កាលណាចៅក្រមស៊ើបសួរមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ។ ព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។

ក្នុងករណីបន្ទាន់ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ។ ចៅក្រមស៊ើបសួរត្រូវចង្អុលប្រាប់មូលហេតុនៃការបន្ទាន់នេះ នៅក្នុងដីកាសម្រេចរបស់ខ្លួន ។

**មាត្រា ២០៦.** - ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញាអាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញា អាចប្ដឹងសុំតាមរយៈពាក្យសុំទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ ។

**មាត្រា ២០៧.** - ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងរបស់ជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនោះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីផ្ដល់យោបល់ និងបញ្ជូនសំណុំរឿងទៅ

ស៊ីទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

ដីកាដែលសម្រេចមិនព្រមធ្វើតាមបណ្ដឹងសុំរបស់ព្រះរាជអាជ្ញា ត្រូវតែមានសំអាងហេតុ ។

**មាត្រា ២២៩.** - បណ្ដឹងសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ

ជនត្រូវចោទអាចធ្វើពាក្យសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា ។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យសុំនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ និងជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ ។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ។ ដីកាសម្រេចនេះត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ ។

កាលណាមានពាក្យសុំឱ្យលើកលែង ឬឱ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបានធ្វើជាថ្មីមុនពេលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំពីមុននោះ រយៈពេល ៥ (ប្រាំ) ថ្ងៃ នេះ ត្រូវចាប់ផ្ដើមគិតពីពេលចេញសេចក្ដីសម្រេចលើពាក្យសុំពីមុន ។ ដីកាដែលសម្រេចមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមានសំអាងហេតុ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នេះទេ ជនត្រូវចោទអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២៣០.** - ការគេចវេះរបស់ជនត្រូវចោទពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើជនត្រូវចោទគេចវេះដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរអាចសម្រេចឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ទោះបីទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងដោយមាត្រា ២០៨ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ) ដល់មាត្រា ២១០ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជារអាទិ៍) មាត្រា ២១៣ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ) និងមាត្រា ២១៤ (ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិមទាក់ទងនឹងអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ) នៃក្រមនេះ ក៏ដោយ ។

កាលណាចៅក្រមស៊ើបសួរសម្រេច ថានឹងឃុំខ្លួនបណ្ដោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ ។ ប្រសិនបើជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវជូនមតិយោបល់ការពារក្ដីរបស់ខ្លួន ។